ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍លើកទី២ និង ទី៣ របស់កម្ពុជា

# ស្តីពី

# ការអនុវត្តអនុសញ្ញាសិទ្ធិកុមារ

## ឆ្នាំ២០០០ ដល់ ២០០៧

រៀបចំដោយ: ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# មាតិកា


ទំព័រ

I. **សេចក្តីផ្តើម** ---------- ១

ក- សេចក្តីផ្តើម ---------- ១

ខ- ទិដ្ឋភាពរួម ---------- ១

១- លក្ខណៈប្រជាសាស្ត្រ ---------- ១

២- សេដ្ឋកិច្ច ---------- ២

៣-ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ---------- ៤

៤- អនុសញ្ញាស្តីពីសិទ្ធិកុមារ និងផែនការសកម្មភាពជាតិសម្រាប់កុមារ ---------- ៥

គ- ដំណើរការធ្វើសេចក្តីព្រាងរបាយការណ៍ ---------- ៦

II. **វិធានការទូទៅដើម្បីអនុវត្តអនុសញ្ញា** ---------- ៦

ក- អំពីច្បាប់ ---------- ៦

ខ-ការសម្របសម្រួល ---------- ១០

គ- ការពិនិត្យតាមដាន ---------- ១១

ឃ-ការប្រមូលទិន្នន័យ ---------- ១១

ង- ការបែងចែកថវិកា ---------- ១៣

ច- ការផ្សព្វផ្សាយ និងការយល់ដឹងអំពីអនុសញ្ញា ---------- ១៣

ឆ- ការហ្វឹកហ្វឺនដល់អ្នកជំនាញ ---------- ១៥

III. **និយមន័យកុមារ** ---------- ១៦

ក- បញ្ចូលនិយមន័យកុមារទៅក្នុងច្បាប់ ---------- ១៦

ខ- អនុវត្តន៍អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍ ---------- ១៧

IV. **គោលការណ៍ទូទៅ** ---------- ១៧

ក- ការមិនរើសអើង ---------- ១៧

ខ- ឧត្តមប្រយោជន៍របស់កុមារ ---------- ១៩

គ-សិទ្ធិរស់រានមានជីវិត និងអភិវឌ្ឍន៍ ---------- ១៩

ឃ- គោរពនូវយោបល់របស់កុមារ ---------- ១៩

V. **សិទ្ធិ និងសេរីភាព** ---------- ១៩

ក- ការចុះបញ្ជីកំណើត ---- ១៩
ខ- សញ្ជាតិ ---- ២០
គ- ការថែរក្សាអត្តសញ្ញាណ ---- ២០
ឃ-សិទ្ធិចូលរួមរបស់កុមារ ---- ២១
ង- សេរីភាពក្នុងការសម្តែងមតិ ---- ២២
ច- សេរីភាពផ្នែកគំនិត មនសិកា និងសាសនា ---- ២២
ឆ- សេរីភាពក្នុងការបង្កើតសមាគម ---- ២២
ជ- ការការពារជីវិតឯកជន ---- ២៣
ឈ- សិទ្ធិទទួលបានព័ត៌មានសមស្រប ---- ២៣
ញ- សិទ្ធិរួចផុតពីអំពើទារុណកម្ម ការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ ---- ២៤

**VI. បរិយាកាសគ្រួសារ និង កិច្ចថែទាំជំនួស** ---- ២៤
ក- ការណែនាំរបស់មាតាបិតា ---- ២៤
ខ- ការទទួលខុសត្រូវរបស់មាតាបិតា ---- ២៥
គ- ការបំបែកពីមាតាបិតា ---- ២៥
ឃ-ការជួបជុំគ្រួសារឡើងវិញ ---- ២៥
ង- ការបញ្ជូនកុមារដោយខុសច្បាប់ និងការមិនវិលត្រឡប់របស់កុមារ ---- ២៦
ច- ការជំរុញឱ្យមានការថែទាំកុមារ ---- ២៦
ឆ- កុមារឃ្លាតចេញពីមជ្ឈដ្ឋានគ្រួសារ ---- ២៦
ជ- សុំកូន ---- ៣០
ឈ- ការត្រួតពិនិត្យជាទៀងទាត់លើការថែរក្សាកុមារ ---- ៣២
ញ- ការបំពារបំពាន និងការមិនយកចិត្តទុកដាក់ចំពោះកុមារ ---- ៣២

**VII. សុខភាពមូលដ្ឋាន និងសុខុមាលភាព** ---- ៣៤
ក- សិទ្ធិរស់រាន និងការអភិវឌ្ឍន៍ ---- ៣៤
១- ការកាត់បន្ថយមរណភាពកុមារ ---- ៣៦
២- សុខភាពរបស់ម្តាយ ---- ៣៧
៣- ការថែទាំសុខភាពបឋម ---- ៣៧
៤- កម្មវិធីអាហារូបត្ថម្ភ ---- ៣៨
៥- សមាហរណកម្មការទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារ ---- ៤០

ខ- មេរោគអេដស៍/ជំងឺអេដស៍ ---- ៤១
គ- កុមារពិការ ---- ៤២
ឃ- សិទ្ធិក្នុងការទទួលការថែទាំសុខភាព ---- ៤៤
ង- សុខភាពកុមារវ័យជំទង់ ---- ៤៧
ច- សន្តិសុខសង្គម សេវាថែទាំកុមារ និងមណ្ឌលថែទាំ ---- ៥០
ឆ- កម្រិតជីវភាពរស់នៅ ---- ៥០

**VIII. ការអប់រំ ការលំហែ និង សកម្មភាព ផ្នែកវប្បធម៌** ---- ៥១

ក- ការងារអប់រំ ---- ៥១
១- ការធានាឱ្យទទួលបានសេវាអប់រំប្រកបដោយសមធម៌ ---- ៥១
១.១- ការអប់រំនៅមត្តេយ្យសាលា ---- ៥៣
១.២- ការអប់រំនៅបឋមសិក្សា ---- ៥៥
១.៣- ការអប់រំនៅមធ្យមសិក្សាបឋមភូមិ ---- ៥៦
១.៤- ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ ---- ៥៧
១.៥- ការងារអប់រំក្រៅប្រព័ន្ធ ---- ៥៨
១.៦- បុគ្គលិកសិក្សា និងការអភិវឌ្ឍគ្រូបង្រៀន ---- ៥៩
១.៧- ការផ្គត់ផ្គង់សៀវភៅសិក្សា ---- ៥៩
១.៨- ការអភិវឌ្ឍកន្លែងសិក្សា ---- ៦០
១.៩- ថវិកា ---- ៦០
២- ការរីកចម្រើន និងផលប៉ះពាល់លើយេនឌ័រ ---- ៦០
២.១-ផលប៉ះពាល់លើកុមារក្រីក្រ ជួបការលំបាក និងកុមារជនជាតិភាគតិច ---- ៦១
ខ- សកម្មភាពបណ្តុះបណ្តាល និងវប្បធម៌ ---- ៦៣
១- ការងារកីឡា ---- ៦៣
២- ការងារសិល្បៈ ---- ៦៣
៣- ការលំបាក ---- ៦៣

**IX. វិធានការការពារពិសេស** ---- ៦៤

ក- កុមារក្នុងស្ថានភាពគ្រោះថ្នាក់ ---- ៦៤
១- កុមារភៀសខ្លួន ---- ៦៤
២- កុមារស្ថិតក្នុងជម្លោះប្រដាប់អាវុធ ---- ៦៥

៣- សកម្មភាពកំចាត់មីន ---------- ៦៥

ខ- យុត្តិធម៌អនីតិជន ---------- ៦៦

១- ការគ្រប់គ្រងកិច្ចការយុត្តិធម៌អនីតិជន ---------- ៦៦

២- កុមារដែលត្រូវបានគេដកសិទ្ធិសេរីភាព ---------- ៦៨

៣- ការដាក់ទោសទណ្ឌលើកុមារ ---------- ៦៩

គ- កុមារដែលស្ថិតនៅក្រោមការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ---------- ៦៩

១- ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ---------- ៦៩

២- ថ្នាំញៀន ---------- ៧២

៣- ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ---------- ៧៥

៣.១- ការពិនិត្យឡើងវិញ និងការអនុវត្តច្បាប់ ---------- ៧៥

៣.២- ការទប់ស្កាត់ និងការបណ្តុះបណ្តាល ---------- ៧៨

៣.៣- ការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើទេសចរណ៍ ---------- ៨១

៣.៤- ការថែទាំជំនួស និងសមាហរណកម្មជនរងគ្រោះ ---------- ៨២

៣.៥- កាបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ---------- ៨៣

៣.៦- កិច្ចសហប្រតិបត្តិការ ---------- ៨៣

៣.៧- លទ្ធផលនៃការប៉ាន់ប្រមាណលើការអនុវត្តផែនការជាតិ ---------- ៨៥

**X. ការផ្សព្វផ្សាយរបាយការណ៍ដំបូង** ---------- ៨៧

# I. សេចក្ដីផ្ដើម

## ក. សេចក្ដីផ្ដើម

១- កម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ របាយការណ៍ដំបូងរបស់កម្ពុជាស្ដីពីការអនុវត្តសិទ្ធិកុមារ ត្រូវបានដាក់ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប ពិនិត្យនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧។ នៅខែឧសភា ឆ្នាំ២០០០ កម្ពុជាបានដាក់ជូននូវចម្លើយតបនឹងសំណួរចំនួនម្ភៃរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអ.ស.ប។ ទន្ទឹមនេះដែរ គណៈប្រតិភូជាន់ខ្ពស់របស់កម្ពុជាក៏បានអញ្ជើញចូលរួមក្នុងអង្គប្រជុំលើកទី២៤ របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ នៅទីក្រុងហ្សឺណែវ។ បន្ទាប់ពីការពិនិត្យពិចារណាលើរបាយការណ៍របស់កម្ពុជាឆ្លើយតបនឹងម្ភៃសំណួរ ព្រមទាំងការជជែកជាមួយគណៈប្រតិភូកម្ពុជារួចមក នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០០ គណៈកម្មាធិការសិទ្ធិកុមារ នៃអ.ស.ប បានចេញនូវសេចក្ដីសង្កេតចុងក្រោយ ដោយបានផ្ដល់អនុសាសន៍មួយចំនួនដើម្បីការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

២- អនុលោមតាមមាត្រា៤៤នៃអនុសញ្ញា កម្ពុជាមានកាតព្វកិច្ចបញ្ជូនរបាយការណ៍ស្ដីពីការអនុវត្តសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប ដោយផ្អែកទៅលើការអនុវត្តអនុសាសន៍ទាំងឡាយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប។ ឯកសារនេះជារបាយការណ៍លើកទី២ និងទី៣ ដែលបរិយាយពីស្ថានភាពរបស់កុមារពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧។

## ខ. ទិដ្ឋភាពរួម

### ១. លក្ខណៈប្រជាសាស្ត្រ

៣- ប្រជាជនកម្ពុជាបានកើនពី១២.៦លាន ក្នុងឆ្នាំ២០០០ ដល់១៤.៤លាន ក្នុងឆ្នាំ២០០៧[១] ដោយមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ១,៨១%[២]។ នៅឆ្នាំ២០០៧ កុមារអាយុក្រោម១៨ឆ្នាំមានប្រហែល៤៣,៩% នៃចំនួនប្រជាជនសរុប។ ក្នុងរយៈពេលនេះ ការបង្កើតកូនបានចុះថយគួរឱ្យកត់សម្គាល់ អត្រាបង្កើតកូនសរុបបានថយពីកុមារ៥,៣នាក់ ក្នុងឆ្នាំ១៩៩៨ មក ៤នាក់ក្នុងឆ្នាំ២០០០ និង៣,៤នាក់ ក្នុងឆ្នាំ២០០៥[៣]។ អត្រាមរណៈរបស់ទារកបានថយចុះពី៩៥ នៅឆ្នាំ២០០០ មកត្រឹម៦៦ នៅឆ្នាំ២០០៥ ក្នុង១០០០កំណើត ហើយអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំបានថយចុះពី១២៤ មកត្រឹម៨៣ ក្នុង១០០០កំណើត[៤]។ ដើម្បីឱ្យអត្រាមរណៈរបស់ទារក និងកុមារថយចុះទៀតទាមទារ

---

[១] របាយការណ៍កែសម្រួលទី១ នៃគម្រោងប្រជាជន សម្រាប់រយៈពេល ១៩៩៨-២០២០ (វិទ្យាស្ថានស្ថិតិជាតិឆ្នាំ២០០៤)។

[២] អង្កេតចន្លោះជំរឿន២០០៤ (វិទ្យាស្ថានស្ថិតិជាតិ) ទំព័រ៩។

[៣] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០០៥។

[៤] របាយការណ៍វឌ្ឍនភាព ឆ្នាំ២០០៦ ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ទំព័រ៦។

ការធ្វើឱ្យប្រសើរឡើងថែមទៀតនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងការទទួលបានកាន់តែប្រសើរនូវការថែទាំសុខភាព និងសេវាកម្មសង្គមផ្សេងៗទៀត។ រហូតមកដល់ឆ្នាំ២០០៤ ប្រជាជនរស់នៅតំបន់ជនបទមានចំនួន៨៥% និងនៅក្នុងទីប្រជុំជនមានចំនួន១៥%។ ដង់ស៊ីតេប្រជាជនជាមធ្យមគឺ៧៤នាក់ក្នុងមួយគីឡូម៉ែតការ៉េ។ អាយុកាលជាមធ្យមរបស់ប្រជាពលរដ្ឋកម្ពុជា គឺ៦៤,១៤ឆ្នាំ សម្រាប់ស្ត្រី និង៥៧,៨៧ឆ្នាំ សម្រាប់បុរស[៥]។

## ២. សេដ្ឋកិច្ច

៤- តាំងពីឆ្នាំ១៩៩៩មក កម្ពុជាបានចាប់ផ្តើមធ្វើឱ្យមានការរីកចម្រើនជាច្រើន ក្នុងការអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សំដៅឈានទៅសម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកំណើនសមធម៌យូរអង្វែង។ ក្របខ័ណ្ឌការងារបានផ្តោតជាសំខាន់ទៅលើការធ្វើឱ្យមាននិរន្តរភាពលើម៉ាក្រូសេដ្ឋកិច្ច ពង្រឹងគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារអនុវត្តវិធានការកែទម្រង់ហិរញ្ញវត្ថុ ដើម្បីធានាឱ្យមានការចាត់ចែងបានសមស្របនូវទ្រព្យសម្បត្តិសាធារណៈ និងបង្កើនការវិនិយោគសាធារណៈនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ។ កម្ពុជាបានធ្វើឱ្យមានការប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងការពង្រឹងស្ថិរភាពសេដ្ឋកិច្ចនយោបាយ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍អន្តរជាតិ។

៥- ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦ ផលិតផលសរុបក្នុងស្រុកបានកើនជាមធ្យម៩,៤%ក្នុងមួយឆ្នាំ។ ដោយឡែក ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ កំណើនផលិតផលសរុបក្នុងស្រុកមានសន្ទុះខ្ពស់ ក្នុងអត្រាជាមធ្យម១១,៤% ក្នុងមួយឆ្នាំ ជាពិសេស នៅឆ្នាំ២០០៥អត្រាកំណើនផលិតផលសរុបក្នុងស្រុកមានកម្រិតខ្ពស់រហូតដល់១៣,៥% ហើយនៅឆ្នាំ២០០៦សម្រេចបាន១០,៨%[៦]។ ដោយឡែក នៅក្នុងឆ្នាំ២០០៧ កំណើនផលិតផលសរុបក្នុងស្រុកសម្រេចបាន ៩,៦% ធៀបនឹងការព្យាករណ៍ដើមឆ្នាំដែលមានតែ៦,៥%។ ចំណូលសម្រាប់មនុស្សម្នាក់ៗជាមធ្យមបានកើនឡើងពី២៨៨ដុល្លានៅឆ្នាំ២០០០ ដល់៥១៣ដុល្លា ឆ្នាំ២០០៦[៧] និង៥៨៩ដុល្លាក្នុងឆ្នាំ២០០៧។ ភាពក្រីក្ររបស់ប្រជាជនកម្ពុជាត្រូវបានកាត់បន្ថយពី៤៧% នៅឆ្នាំ១៩៩៤ មកនៅ៣៤,៦៧% នៅឆ្នាំ២០០៤ ហើយតាមការវាយតម្លៃជាបឋមភាពក្រីក្របានថយចុះមកត្រឹម៣១%នៅឆ្នាំ២០០៧ ដោយសម្រេចគោលដៅកាត់បន្ថយភាពក្រីក្របានជាមធ្យមជាង១% ក្នុងមួយឆ្នាំ ស្របតាមទិសដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។ អាំងឌីកាទ័រមិនមែនជាចំណូល (Non-Income Indicator) ដូចជាភាពជាកម្មសិទ្ធិលើអតិថិជន គុណភាពផ្ទះសម្បែង សាលារៀន បង្ហាញថាកម្រិតជីវភាពរស់នៅរបស់ប្រជាជន រាប់បញ្ចូលទាំងប្រជាជនក្រីក្រផង មានភាពប្រសើរឡើងក្នុងរយៈពេលរបាយការណ៍នេះ ក៏ប៉ុន្តែកំណើនក្នុងកម្រិតជីវភាពច្រើនមានតែនៅក្នុងទីក្រុង និងក្នុងចំណោមអ្នកមាន។ អ្នកក្រីក្របំផុតដែលធ្លាក់ក្រោមបន្ទាត់ក្រីក្រ ទទួលបានកំណើនយឺតជាងអ្នកក្រីក្រធម្មតា។ ប្រជាជនក្រីក្ររស់នៅក្នុងតំបន់ជនបទដាច់ស្រយាល៩១%

---

[៥] របាយការណ៍វឌ្ឍនភាពឆ្នាំ២០០៦ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ - ទំព័រ vii ។

[៦] គណនេយ្យជាតិកម្ពុជាឆ្នាំ១៩៩៣-២០០៦ (វិទ្យាស្ថានស្ថិតិជាតិឆ្នាំ២០០៧) - ទំព័រ១។

[៧] របាយការណ៍វឌ្ឍនភាពឆ្នាំ២០០៦ - ទំព័រ៥។

អាចប្រើប្រាស់ផ្លូវ និងទទួលសេវាកម្មចម្បងៗនៅឆ្នាំ២០០៤។ គម្រោងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់រយៈពេល ៥ឆ្នាំ ទទួលស្គាល់នូវភាពចាំបាច់ក្នុងការដោះស្រាយភាពក្រីក្រនៅជនបទ ហើយផ្តល់អាទិភាពទៅលើការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់អ្នកក្រីក្រនៅជនបទ។

៦- វិស័យកសិកម្មមានកំណើនជាមធ្យមក្នុងឆ្នាំ២០០៦ ដោយមានកំណើន៥.៥% គិតតាមថ្លៃថេរឆ្នាំ២០០០។ ក្នុងកំឡុងនេះ កំណើនដែលគួរឱ្យកត់សម្គាល់មាន១០,៥% នៅឆ្នាំ២០០៣ និង១៥,៧% នៅឆ្នាំ២០០៥[៨] ។ កសិកម្មតំណាងឱ្យ ១/៣នៃផលិតផលសរុបរួមរបស់កម្ពុជា ហើយផ្តល់កម្លាំងការងារច្រើនជាង៧០%នៃកម្លាំងការងារសរុប។ ទោះបីជាមានកំណើនក្នុងផ្នែកនេះយ៉ាងណាក្តី ក៏ផលិតផលកសិកម្មប្រចាំឆ្នាំបានបង្ហាញឱ្យឃើញនូវការវិនិយោគមិនគ្រប់គ្រាន់ ការធ្វើអាជីវកម្មលើសលុបលើធនធានធម្មជាតិ និងលក្ខខណ្ឌអាកាសធាតុមិនអំណោយផល ។ ចាប់ពីឆ្នាំ១៩៩៩ ផ្នែកកសិកម្មទទួលបានផលអវិជ្ជមានក្នុងរយៈពេល៣ឆ្នាំជួនៗ ដោយសារទឹកជំនន់និងគ្រោះរាំងស្ងួត។ សិទ្ធិលើទ្រព្យសម្បត្តិដែលពុំទាន់រៀបចំបានល្អ ហេដ្ឋារចនាសម្ព័ន្ធពុំទាន់អភិវឌ្ឍបានខ្ពស់ និងអភិបាលកិច្ចនៅមានកម្រិតជាកត្តារាំងស្ទះដល់កំណើននៃវិស័យកសិកម្ម។

៧- គួរកត់សម្គាល់ថា ក្នុងរយៈពេល១៣ឆ្នាំ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០៧ អត្រាអតិផរណាត្រូវបានរក្សាឱ្យនៅទាបក្រោម ៥%ក្នុងមួយឆ្នាំ ទុនបម្រុងរបស់ជាតិជារូបិយប័ណ្ណកើនឡើងចំនួន១៧ដង គឺពី១០០លានដុល្លារហួតដល់១.៧០០លានដុល្លា។ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០៦ ការនាំចូលកើនឡើង៨ដង គឺពី៤៦៣លានដុល្លា ដល់៣.៦ពាន់លានដុល្លា ចំណូលថវិកាកើនឡើង៥.៧ដង ដោយក្នុងមួយឆ្នាំកើនជាមធ្យម១០% ឯចំណាយថវិកាកើន៤.២ដង ដោយក្នុងមួយឆ្នាំកើនជាមធ្យម១៣%។

៨- សក្តានុពលសំខាន់នៃកំណើនសេដ្ឋកិច្ចក្នុងឆ្នាំថ្មីៗនេះ គឺផលិតផលសម្លៀកបំពាក់ និងទេសចរណ៍។ ទស្សវត្សរ៍ចុងក្រោយបង្ហាញពីការរីកចម្រើនយ៉ាងខ្លាំងក្នុងផ្នែកវាយនភ័ណ្ឌ និងសម្លៀកបំពាក់សម្រាប់នាំចេញទៅសហរដ្ឋអាមេរិកនិងអឺរ៉ុប តាមរយៈឋានៈជាប្រទេសដែលទទួលបានការយោគយល់បំផុត (Most Favoured Nations) និងប្រព័ន្ធយោគយល់ទូទៅ (Generallised System of Preferences)។ គិតតាមថ្លៃថេរឆ្នាំ២០០០ ការនាំចេញទំនិញមានសន្ទុះខ្លាំងនៅឆ្នាំ ២០០៦ ដោយមានកំណើន២១,៨% ធៀបនឹង២៥,២% និង១១,៤% នៅឆ្នាំ២០០៤ និង២០០៥ តាមលំដាប់លំដោយ។ គិតតាមថ្លៃថេរការនាំចេញផលិតផលសរុបក្នុងស្រុកបានកើនឡើង១៨,៧% នៅឆ្នាំ២០០៦ បើប្រៀបធៀបទៅនឹងកំណើន៩% នៅឆ្នាំ២០០៥[៩] ។

---

[៨] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៦ ទំព័រ ១។

[៩] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៦ ទំព័រ ១៨។

៩- វិស័យទេសចរណ៍កម្ពុជាបានរួមចំណែកយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ និងបានបង្កើតឱកាសការងារធ្វើជាច្រើនសម្រាប់អាជីវកម្មក្នុងស្រុក និងប្រជាជនក្រីក្រ។ ចំនួនទេសចរណ៍ជាតិ និងអន្តរជាតិមានការកើនឡើងជាលំដាប់ជាពិសេសរយៈពេលពីរឆ្នាំចុងក្រោយនេះ (ប្រមាណជាមធ្យមពី២០%-២៥%ក្នុងមួយឆ្នាំ)។ ដោយសារតែថាមភាពនៃវិស័យទេសចរណ៍បានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យនេះ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង៦របស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ មានការខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ ដោយបង្កលក្ខណៈងាយស្រួលសម្រាប់គ្រប់ផ្នែក(ភាគី) ពាក់ព័ន្ធទាំងផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៧នេះ អ្នកទេសចរណ៍អន្តរជាតិដែលបានមកទស្សនាកម្ពុជាមានចំនួន២.០១៥.១២៨នាក់ មានការកើនឡើង១៨.៥៣% ប្រៀបធៀបនឹងឆ្នាំ២០០៦ ក្នុងនោះទទួលបានចំណូលប្រមាណ១.៤០០លានដុល្លាអាមេរិក កើនឡើងប្រមាណ៣៣.៤៦% ប្រៀបធៀបនឹងឆ្នាំ២០០៦ (១.០៤៩លានដុល្លាអាមេរិក) រួមចំណែកប្រមាណ១៤%នៃផលទុនសរុបក្នុងស្រុក-ផសស (GDP) និងបានផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋបានប្រមាណ៣០០.០០០នាក់។

១០- តម្លៃបន្ថែមនៃឧស្សាហកម្មបានកើនឡើង១៨.៣% នៅឆ្នាំ២០០៦ បន្ទាប់ពីមានការកែតម្រូវកំណើន១៦.៦% និង១២.៧% នៅឆ្នាំ២០០៤ និង២០០៥ តាមលំដាប់លំដោយ។ វិស័យឧស្សាហកម្មដែលជាសំខាន់រួមមាន កម្មន្តសាល ៧២.៥% និងសំណង់២៤.១% តាមលំដាប់លំដោយនៅឆ្នាំ២០០៦[១០] ។

### ៣. ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ

១១- កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងកុមារមានដូចជា ÷

- អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅឆ្នាំ១៩៩២
- អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន នៅឆ្នាំ២០០០
- ពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ នៅឆ្នាំ២០០២
- ពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ នៅឆ្នាំ២០០២
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅឆ្នាំ២០០៦
- ពិធីសារប៉ាលែម៉ូ ដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលជាការបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្ម ដែលមានការចាត់

[១០] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៦ ទំព័រ៩។

តាំងឆ្លងដែន នៅឆ្នាំ២០០៦

- អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស នៅឆ្នាំ ២០០៧ (ចូលជាធរមាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០០៧)។

១២- កម្ពុជាជាភាគីអនុសញ្ញា និងពិធីសារបន្ថែមដទៃផ្សេងទៀតដូចជា÷

- អនុសញ្ញាអន្តរជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់អន្តរជាតិ (ឆ្នាំ២០០៥)
- ពិធីសាររបស់អង្គការសហប្រជាជាតិ ដើម្បីបង្ការ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស (ឆ្នាំ២០០១)
- អនុសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់កម្មករ និយោជិត បុរស-ស្ត្រីចំពោះការងារមានតម្លៃស្មើ(ឆ្នាំ២០០០)
- អនុសញ្ញាស្តីពីការរើសអើងក្នុងការងារ និងមុខរបរ (ឆ្នាំ២០០០)
- អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស (ឆ្នាំ១៩៩២)
- អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ឆ្នាំ១៩៩២)
- ពិធីសារទំនាក់ទំនង និងឋានៈជនភៀសខ្លួន (ឆ្នាំ១៩៩២)
- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ១៩៩២)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ១៩៩២)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ឆ្នាំ១៩៨៣)
- អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ចឆ្នាំ (ឆ្នាំ១៩៧០)
- អនុសញ្ញាស្តីពីការងារពេលយប់ (ឆ្នាំ១៩៦៩)
- អនុសញ្ញាបន្ថែមរបស់អង្គការសហប្រជាជាតិស្តីពីការលុបចោលទាសភាព ការជួញដូរទាសករ និងការអនុវត្ត ស្រដៀងគ្នានឹងទាសភាព (ឆ្នាំ១៩៥៧)
- អនុសញ្ញាស្តីពីការទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច ហើយការទទួល បានភាពយុត្តិធម៌ ក្នុងបញ្ហាបរិស្ថាន (ឆ្នាំ១៩៤៨)

### ៤. អនុសញ្ញាស្តីពីសិទ្ធិកុមារ និងផែនការសកម្មភាពជាតិសម្រាប់កុមារ

១៣- អនុលោមតាមរបៀបវារៈស្តុកខុល ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកលើកទី១ ស្តីពីការប្រឆាំងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលប្រព្រឹត្តទៅនៅប្រទេសស៊ុយអែតឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(ឆ្នាំ២០០០-២០០៤)។ ផែនការនេះផ្តោតលើកម្មវិធីសំខាន់៧៤គឺ កិច្ចបង្ការទប់ស្កាត់ កិច្ចការពារ ការស្តារនិងអភិវឌ្ឍសមត្ថភាព និងសមាហរណកម្មទៅក្នុងសហគមន៍។ បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកំពុងរៀបចំផែនការជាតិលើកទី២ សម្រាប់រយៈពេល៥ឆ្នាំ បន្តទៀត។

១៤- បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៦ ស្តីពីកុមារតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០០៣រួចមក រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារ "**កម្ពុជាដើម្បីកុមារ**" ដែលជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីសកម្មភាពចម្បង៧សម្រាប់កុមារ។ ឯកសារកម្ពុជាដើម្បីកុមារត្រូវបាន ផ្សព្វផ្សាយនៅក្នុងទិវាកុមារអន្តរជាតិនាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៤។ ឯកសារនេះបានស្រង់ដោយសង្ខេបនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះកុមារ ដែលមានចែងនៅក្នុងផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលមានគោលដៅសំខាន់៧ស្របទៅនឹងឯកសារពិភពលោកសមស្របសម្រាប់កុមារ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងសេចក្តីប្រកាសសហស្សវត្សរ៍។ នៅក្នុងឯកសារកម្ពុជាដើម្បីកុមារ រាជរដ្ឋាភិបាលបានអំពាវនាវដល់បណ្តាក្រសួងស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ ព្រមទាំងដៃគូសហប្រតិបត្តិការអភិវឌ្ឍសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ឱ្យសហការគ្នាយកចិត្តទុកដាក់ស្តាប់មតិយោបល់របស់កុមារ និងបំផុសចលនាកុមារចូលរួមក្នុងដំណើរការនេះឱ្យបានល្អប្រសើរ។

## គ. <u>ដំណើរការធ្វើសេចក្តីព្រាងរបាយការណ៍</u>

១៥- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតក្រុមការងារមួយ និងបានដឹកនាំការធ្វើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ របាយការណ៍នេះត្រូវបានធ្វើឡើងដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ តាមរយៈក្រុមការងារជំនាញ។ នៅពេលសេចក្តីព្រាងរបាយការណ៍ត្រូវបានបញ្ចប់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានធ្វើការប្រជុំពិគ្រោះយោបល់ ដើម្បីស្វែងរកការផ្តល់មតិបន្ថែមពីអ្នកដែលធ្វើការងារពាក់ព័ន្ធ ។ បន្ទាប់មកទៀត ក៏មានការផ្តល់មតិពីកុមារមកពីខេត្ត-ក្រុងមួយចំនួនតាមរយៈវេទិកាកុមារថ្នាក់ជាតិដែលធ្វើឡើងនៅថ្ងៃទី២៥-២៦ ខែកុម្ភៈ ឆ្នាំ២០០៧។

# II. វិធានការទូទៅដើម្បីអនុវត្តអនុសញ្ញា

## ក- <u>អំពីច្បាប់</u>

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់ ដើម្បីធ្វើឱ្យស្របជាមួយនឹងបទបញ្ញត្តិរបស់អនុសញ្ញា ជាពិសេសឱ្យស្របនឹងគោលការណ៍ទូទៅ (មាត្រា២, ៣, ៦ និង១២)។ ការយកចិត្តទុកដាក់ជាពិសេសត្រូវផ្តោតទៅលើការចុះបញ្ជីកំណើត ការថែទាំក្នុងគ្រួសារ ការថែទាំជំនួស និងយុត្តិធម៌អនីតិជន។
- ដាក់បញ្ចូលនូវកិច្ចការពារអំពីសិទ្ធិកុមារ ក្នុងដំណើរការបច្ចុប្បន្ន ឬ នៅពេលខាងមុខនៃការធ្វើសេចក្តីព្រាងច្បាប់ ជាពិសេស សេចក្តីព្រាងក្រមព្រហ្មទណ្ឌ រដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ។

១៦- ក្រសួងយុត្តិធម៌បានដឹកនាំដំណើរការពង្រឹងក្របខ័ណ្ឌការងារច្បាប់ដែលមានស្រាប់ និងពិនិត្យឡើងវិញនូវទម្រង់ទាំងអស់របស់ច្បាប់ ជាពិសេសសេចក្តីព្រាងច្បាប់ដែលមានការពាក់ព័ន្ធនឹងកុមារ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌

អនីតិជនទំនាស់នឹងច្បាប់ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ក្រសួងយុត្តិធម៌មិនបានធ្វើសេចក្ដីណែនាំស្ដីពី "ការចោទប្រកាន់ការផ្ដន្ទាទោសជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ"។ ពាក់ព័ន្ធនឹងផ្នែកព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌មិនបានដាក់ចេញនូវសេចក្ដីណែនាំអំពីការអនុវត្តគោលការណ៍ច្បាប់ជាតិ អន្តរជាតិ ដែលនៅជាធរមានទាក់ទងទៅនឹងកិច្ចការពារជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ។ សេចក្ដីណែនាំបានដាក់បញ្ចូលនូវបទប្បញ្ញត្តិជាច្រើនរបស់អនុសញ្ញាសិទ្ធិកុមារ ដែលពាក់ព័ន្ធដល់កិច្ចការពារកុមារជាជនរងគ្រោះ (ឧទាហរណ៍ មាត្រា១៦របស់អនុសញ្ញា)។ ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុវត្តទូទាំងប្រទេស កាលពីខែកក្កដា ឆ្នាំ២០០៧។

១៧- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) បានតាក់តែង និងដាក់ឱ្យអនុវត្តនូវនយោបាយជាតិស្ដីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ និងបានចេញប្រកាសស្ដីពីការទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ។ ទន្ទឹមនឹងនេះ ក្រសួងបានជំរុញដំណើរការពង្រឹងការអនុវត្តច្បាប់ ដែលមានស្រាប់ទាក់ទងទៅនឹងកិច្ចការពារផ្នែកសង្គមដល់កុមារ។

១៨- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។ ច្បាប់នេះផ្ដល់នូវយន្តការផ្លូវច្បាប់ ដើម្បីបង្ការអំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះដោយបន្ថែមទៅលើបទប្បញ្ញត្តិដែលនៅជាធរមាន។ ការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារកំពុងត្រូវបានផ្សព្វផ្សាយដោយក្រសួងកិច្ចការនារី។

១៩- អនុគណៈកម្មការតាក់តែងច្បាប់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបញ្ចប់ការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់នៅខែកញ្ញាឆ្នាំ២០០៦ ហើយបានធ្វើការប្រជុំពិគ្រោះយោបល់ដើម្បីស្វែងរកការផ្ដល់មតិបន្ថែមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ អន្តរជាតិនៅខែឧសភា ឆ្នាំ២០០៧។ សេចក្ដីព្រាងច្បាប់នេះផ្ដោតលើកុមារដែលប្រព្រឹត្តល្មើសច្បាប់ កំណត់នូវវិធានដែលទាមទារឱ្យតែងតាំងអ្នកជំនាញដើម្បីធ្វើការសម្រាប់កុមារទំនាស់នឹងច្បាប់ តម្រូវឱ្យមានតួនាទីរបស់បុគ្គលិកសង្គមកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ បង្កើតនីតិវិធីកុមារមេត្រី អាយុអប្បបរមាក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ការបន្ធូរបន្ថយការទទួលខុសត្រូវ មធ្យោបាយជំនួសការឃាត់ ឬឃុំខ្លួន ឬដាក់គុក ការបង្វែរនៅដំណាក់កាលផ្សេងៗ សន្និសីទក្រុមគ្រួសារ និងការលុបចោលលិខិតថ្កោលទោស។

២០- ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានទិសដៅបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដើម្បីថែរក្សា ពង្រឹងប្រពៃណីល្អរបស់ជាតិ ការពារសិទ្ធិ សេចក្ដីថ្លៃថ្នូរបស់មនុស្ស និងដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខភាព សុខុមាលភាពរបស់ប្រជាជន និងដើម្បីអនុវត្តឱ្យបានសមស្របផងដែរតាមពិធីសាររបស់អង្គការសហប្រជាជាតិស្ដីពីការបង្ការបង្ក្រាប និងផ្ដន្ទាទោសអំពើជួញដូរមនុស្ស និងលិខិតូបករណ៍អន្តរជាតិ ឬកិច្ចព្រមព្រៀងដទៃទៀតទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័ន។ ច្បាប់នេះទទួលការអនុម័តពីរដ្ឋសភារួចហើយ កាលពីខែធ្នូ ឆ្នាំ២០០៧ ។

២១- សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ជាតិបានចែង "ហាមមិនឱ្យលក់បារីឱ្យក្មេងក្រោមអាយុ១៨ឆ្នាំ" ។

២២- ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌដែលបានចែងអំពីកុមារ មាន ÷

- ការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៃអនីតិជន
- ទោសដែលអាចអនុវត្តចំពោះអនីតិជន
- ការប៉ះពាល់អនីតិជន និងគ្រួសារ
- ការប៉ះពាល់ដល់ការថែរក្សាអនីតិជន ការប៉ះពាល់ដល់បុគ្គភាព ការដាក់អនីតិជនឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ការជំរុញអនីតិជនប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់ ។

២៣- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវបានព្រាងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) សហការជាមួយអង្គការយូនីសេហ្វ ។ គោលបំណងនៃច្បាប់ គឺដើម្បីធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ។ សេចក្តីព្រាងច្បាប់នេះបានទទួលការផ្តល់មតិយោបល់ និងអនុសាសន៍ពីក្រសួង និងស្ថាប័នពាក់ព័ន្ធ អ្នកឯកទេសនៃអ.ស.ប អង្គការមិនមែនរដ្ឋាភិបាល និងបានដាក់ឱ្យមានការពិគ្រោះយោបល់តាមរយៈសិក្ខាសាលាថ្នាក់ជាតិ នៅខែមិថុនា ឆ្នាំ២០០៣ ដែលអ្នកចូលរួមជាតំណាងស្ថានទូត អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ក្រសួងពាក់ព័ន្ធ និងមន្ទីរ ស.អ.យ មួយចំនួន ។

២៤- ក្នុងចន្លោះឆ្នាំ២០០០-២០០១ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ហើយក្រសួងទេសចរណ៍បានចេញសារាចរ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដោយផ្តោតលើផ្នែកទេសចរណ៍ មានដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងរង្គសាល និងធ្វើការត្រួតពិនិត្យខ្សែភាពយន្តវីដេអូ ។

នៅឆ្នាំ២០០៦ ក្រសួង ស.អ.យ បានចេញសេចក្តីប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួល ការគ្រប់គ្រង និងការស្តារនីតិសម្បទាកុមារនៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ និងប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ។ ប្រកាសអន្តរក្រសួងត្រូវបានធ្វើឡើងដោយក្រសួងសង្គមកិច្ច និងក្រសួងមហាផ្ទៃនៅឆ្នាំ២០០១ ស្តីពីការអប់រំ កែប្រែ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិត ។ នៅឆ្នាំ២០០៣ នាយកដ្ឋានពន្ធនាគារបានចេញនីតិវិធីលេខ៣៤ ក្នុងគោលបំណងគ្រប់គ្រង និងថែទាំអ្នកទោសស្ត្រីដែលមានផ្ទៃពោះ និងកូនអ្នកទោសស្ត្រីនៅក្នុងពន្ធនាគារ ។

២៥- នៅចុងឆ្នាំ២០០៦ ក្រសួង ស.អ.យ បានសម្រេចរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ហើយបានឆ្លងអង្គប្រជុំទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ និងបានបញ្ជូនទៅសុំការអនុម័តពីរដ្ឋសភា ។ គោលបំណងនៃច្បាប់ គឺពង្រឹងកិច្ចការពារនិងអត្ថប្រយោជន៍របស់ជនពិការ ព្រមទាំងប្រឆាំងការរើសអើងចំពោះពួកគេ ។ សិទ្ធិទាំងនោះ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន រួមមាន សិទ្ធិក្នុងការរស់រានមានជីវិត ការទទួលបានការអប់រំ និងសេវាផ្នែកសុខភាព ។ ផ្អែកតាមច្បាប់នេះ រាជរដ្ឋាភិបាលត្រូវបង្កើតកម្មវិធីបង្ការពិការភាពដល់ពលរដ្ឋគ្រប់រូប តាមរយៈការថែទាំសុខភាពនៅពេលមានគភ៌ និងការផ្តល់អាហារ

ទ្រទ្រង់រាងកាយ។ សិស្សពិការគ្រប់រូបមានសិទ្ធិចូលសិក្សាក្នុងគ្រឹះស្ថានអប់រំដោយសមធម៌ ហើយសិស្សពិការនៃគ្រួសារក្រីក្រអាចចូលសិក្សាក្នុងគ្រឹះស្ថានរដ្ឋដោយឥតបង់ថ្លៃ។

២៦- រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។ អនុក្រឹត្យនេះតម្រូវឱ្យឪពុកឬម្តាយរាយការណ៍អំពីកំណើតរបស់ទារក ក្នុងរយៈពេល៣០ថ្ងៃដល់មន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយ (មាត្រា១៧)។ ករណីមានទារកដែលគេបោះបង់ចោល ទារកនោះនឹងត្រូវបានយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ ដើម្បីធ្វើការចុះសៀវភៅកំណើតហើយដាក់ឈ្មោះឱ្យ(មាត្រា១៩)។ អនុក្រឹត្យក៏បានជួយសម្រួលដល់ការចុះបញ្ជីកំណើត និងការផ្តល់សំបុត្រកំណើតដល់ទារកឬកុមារដែលពុំទាន់ចុះបញ្ជីកំណើត ឬគ្មានសំបុត្រកំណើតដែលរស់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះ ឬមជ្ឈមណ្ឌលកុមារកំព្រាផងដែរ(មាត្រា២០)។ នៅឆ្នាំ២០០២ និង២០០៤ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦០អនក្រ.បក និងលេខ១៧អនក្រ.បក ដើម្បីកែសម្រួលលើមាត្រាមួយចំនួននៃអនុក្រឹត្យលេខ១០៣។ មាត្រា៨នៃអនុក្រឹត្យលេខ៦០ បានចែងអំពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំសង្កាត់លើការងារអត្រានុកូលដ្ឋាន។ មាត្រា២៥នៃអនុក្រឹត្យលេខ១៧ បានចែងសម្រួលនីតិវិធីចុះសៀវភៅកំណើតឱ្យទារកដែលទើបកើតហើយទុកឱ្យហួសរយៈពេល៣០ថ្ងៃពុំរាយការណ៍។ ទន្ទឹមនេះដែរ សេចក្តីព្រាងក្រមរដ្ឋប្បវេណីក៏បានចែងអំពីសិទ្ធិ និងករណីរបស់ឪពុកម្តាយក្នុងការចុះសំបុត្រកំណើតឱ្យកូនផងដែរ។

២៧- ដើម្បីធ្វើឱ្យការងារចុះបញ្ជីកំណើតមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០៤៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័តទូទាំងប្រទេស។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះ ភាគរយនៃប្រជាជនដែលមានសំបុត្រកំណើតបានកើនពី២២% ក្នុងឆ្នាំ២០០០ ដល់៨៩% ក្នុងឆ្នាំ ២០០៦ (មកដល់ខែវិច្ឆិកា ២០០៦)។ ទោះបីជានៅពេលនេះ ទិន្នន័យដោយឡែកតាមអាយុនិងភេទ មិនទាន់មាននៅឡើយ ប៉ុន្តែក្រសួងមហាផ្ទៃបានណែនាំអភិបាលខេត្ត ក្រុង ឱ្យប្រមូលទិន្នន័យប្រជាពលរដ្ឋអាយុក្រោម១៨ឆ្នាំ ដែលបានចុះបញ្ជីកំណើត[១១]។

២៨- ច្បាប់ស្តីពីការអប់រំត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ក្នុងគោលដៅកំណត់អំពីវិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិសម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពដែលធានាបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបានចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អកប្បកិរិយាប្រកបដោយសីលធម៌ ជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។

---

[១១] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ៤៩៥ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦។

## ៦- ការសម្របសម្រួល

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ចាត់វិធានការដ៏មានប្រសិទ្ធភាព រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការសម្របសម្រួលការអនុវត្តអនុសញ្ញា នៅថ្នាក់ជាតិ តំបន់ និងមូលដ្ឋាន។
- ផ្តល់ដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនូវថវិកា និងធនធានមនុស្ស ដើម្បីបង្កើតនូវកិច្ចសហការសម្របសម្រួលជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលធ្វើការក្នុងវិស័យសិទ្ធិកុមារ។

**ពង្រឹងតួនាទី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) ក្នុងការសម្របសម្រួលការអនុវត្តអនុសញ្ញា**

២៩- នៅឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.ក) ដែលមានភារកិច្ចផ្តល់យោបល់ សម្របសម្រួលការងារពាក់ព័ន្ធនឹងកុមារ ជួយរាជរដ្ឋាភិបាលក្នុងការពិនិត្យតាមដាន ធ្វើរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារ ព្រមទាំងកម្មវិធីសកម្មភាពជាតិសម្រាប់កុមារ ស្រាវជ្រាវ និងជូនព័ត៌មានស្តីពីតម្រូវការ និងបញ្ហាដែលពាក់ព័ន្ធនឹងកុមារជូនរាជរដ្ឋាភិបាល ហើយទំនាក់ទំនងជាមួយដៃគូជាតិ អន្តរជាតិ ដើម្បីប្តូរយោបល់ បទពិសោធន៍ និងទស្សនៈ ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលំអស្ថានភាពរបស់កុមារ។ ក.ជ.ក.ក មានអនុគណៈកម្មការចំនួន៤ បំពេញកិច្ចការ និងសម្របសម្រួលការអនុវត្តវិស័យជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងអនុសញ្ញាសិទ្ធិកុមារ។

៣០- ក.ជ.ក.ក កំពុងរៀបចំកែសម្រួលអនុក្រឹត្យស្តីពីការបង្កើត ក.ជ.ក.ក ដែលនឹងមានរចនាសម្ព័ន្ធនៅតាមក្រសួងនានា និងនៅថ្នាក់ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ រចនាសម្ព័ន្ធនេះនឹងជួយសម្រួលដល់ការទទួលខុសត្រូវចំពោះការបំពេញភារកិច្ចការអនុវត្តអនុសញ្ញា និងពិធីសារជ្រើសរើស ក៏ដូចជាការប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងកុមារ។ មន្ត្រី ក.ជ.ក.ក បានទទួលការបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេសជាបន្តបន្ទាប់។

៣១- ក.ជ.ក.ក បានដំណើរការកម្មវិធីរបស់ខ្លួនដោយមានការឧបត្ថម្ភពីរដ្ឋាភិបាលនូវ ទីក អគ្គិសនី ទូរស័ព្ទ និងថវិកាមួយចំនួនសម្រាប់រៀបចំទិវាកុមារអន្តរជាតិ១មិថុនា និងបានទទួលថវិកាពីអង្គការយូនីសេហ្វសម្រាប់ដំណើរការការងាររដ្ឋបាល កម្មវិធី និងលើកទឹកចិត្តដល់មន្ត្រី ហើយមានកម្មវិធីមួយចំនួនទៀត ក៏បានទទួលការឧបត្ថម្ភថវិកាពីអង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (ILO/IPEC)។ ដោយឡែក មានអង្គការមួយចំនួនទៀត ដូចជាអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ(IOM) អង្គការសង្គ្រោះកុមារអូស្ត្រាលី សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia Acts) អង្គការទស្សនៈពិភពលោកកម្ពុជា គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (ECPAT) និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

នៅកម្ពុជា (COSECAM) បានឧបត្ថម្ភថវិកា និងចូលរួមសហការរៀបចំសកម្មភាព និងរបាយការណ៍ផ្សេងៗ។ ទោះយ៉ាងណាក្តី ក.ជ.ក.ក នៅតែប្រឈមមុខនឹងបញ្ហាជាច្រើន ដូចជាកង្វះធនធានមនុស្ស និងថវិកា។

## ច- ការពិនិត្យតាមដាន

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ពិចារណាបង្កើតនូវយន្តការឯករាជ្យ (ឧទាហរណ៍ Ombudsman សម្រាប់កុមារ) ដើម្បីពិនិត្យតាមដានការអនុវត្តអនុសញ្ញា និងដើម្បីដោះស្រាយបណ្តឹងរបស់កុមារអំពីការរំលោភសិទ្ធិរបស់ពួកគេក្នុងលក្ខណៈលឿនរហ័ស និងមេត្រីភាព ហើយផ្តល់ដំណោះស្រាយចំពោះការរំលោភសិទ្ធិ។ ជាបន្ថែមគណៈកម្មាធិការស្នើឱ្យរដ្ឋជាភាគីធ្វើយុទ្ធនាការលើកតម្កើង ដើម្បីសម្រួលការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពដោយកុមារនូវយន្តការនេះ។

**បង្កើតគណៈកម្មាធិការឃ្លាំមើល (Ombudsman ) សម្រាប់កុមារ ដើម្បីត្រួតពិនិត្យតាមដានការអនុវត្តអនុសញ្ញា**

៣២- បញ្ហានេះកំពុងត្រូវបានពិចារណាដោយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

## ឆ- ការប្រមូលទិន្នន័យ

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

បន្តការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធប្រមូលទិន្នន័យ ដើម្បីបញ្ចូលរាល់ផ្នែកទាំងអស់ដែលគ្របដណ្តប់ដោយអនុសញ្ញា។ ប្រព័ន្ធនោះគួររាប់បញ្ចូលកុមារអាយុក្រោម១៨ឆ្នាំទាំងអស់ ហើយផ្តោតជាពិសេសលើក្រុមកុមារដែលងាយទទួលរងគ្រោះជាមូលដ្ឋានសម្រាប់វាយតម្លៃការរីកចម្រើន ដែលទទួលបានក្នុងការយល់ដឹងអំពីអនុសញ្ញា។ ពាក់ព័ន្ធដល់ចំណុចនេះ គណៈកម្មាធិការជំរុញឱ្យរដ្ឋស្វែងរកជំនួយអន្តរជាតិ ដូចជាពីអង្គការយូនីសេហ្វ។

៣៣- ច្បាប់ស្តីពីស្ថិតិដែលគ្រប់គ្រងលើផ្នែកទាំងអស់ទាក់ទងនឹងការប្រមូល ដំណើរការនៃការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យ ក្នុងទូទាំងប្រទេសកម្ពុជា។ ផ្អែកតាមមាត្រា១១នៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទទួលខុសត្រូវក្នុងកិច្ចការនេះ។ កន្លងមក ប្រព័ន្ធទិន្នន័យកម្ពុជា (CAMInfo) បានកែសម្រួលពី Devinfo ដែលត្រូវបានវិទ្យាស្ថានជាតិស្ថិតិប្រកាសដាក់ឱ្យប្រើប្រាស់នៅខែមីនា ឆ្នាំ២០០៤ ដោយមានការគាំទ្រខាងបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការយូនីសេហ្វ និងអង្គការGTZ។ CAMInfo ត្រូវបានទទួលស្គាល់ថា ជាមូលដ្ឋានទិន្នន័យសូចនាករជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់ការតាមដានភាពរីកចម្រើនធៀបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅផ្សេងៗទៀតរបស់ជាតិ គោលដៅប្រចាំតំបន់ និងពិភពលោកផងដែរ រួមទាំងពិភពលោកសមស្របសម្រាប់កុមារ។ CAMInfo រួមមានទិន្នន័យថ្នាក់ជាតិ និងថ្នាក់ខេត្តរហូតដល់ឃុំដែលអាចធ្វើឱ្យមានការតាមដានពីសូចនាករនានានៅថ្នាក់មូលដ្ឋាន។ ទិន្នន័យចម្បងៗដែលបានពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ទិន្នន័យ

ដែលបានពីការឃ្លាំមើលជាប្រចាំទិន្នន័យរដ្ឋបាល និងមូលដ្ឋានទិន្នន័យឃុំ សង្កាត់ក៏ត្រូវបានដាក់បញ្ចូលទៅក្នុង CAMInfo ផងដែរ និងបានធ្វើបច្ចុប្បន្នភាពពីរដងក្នុងមួយឆ្នាំ។ CAMInfo ត្រូវបានប្រើប្រាស់សម្រាប់ធ្វើបច្ចុប្បន្នភាពនូវរបាយការណ៍ស្ដីពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ២០០៥ និងសម្រាប់ធ្វើរបាយការណ៍ទៀងទាត់របស់រាជរដ្ឋាភិបាលដើម្បីផ្ញើរជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប។

៣៤- នៅឆ្នាំ២០០២ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងអង្គការផ្សេងៗទៀត ក្រសួងផែនការបានរៀបចំមូលដ្ឋានទិន្នន័យជាតិឃុំ សង្កាត់។ ទិន្នន័យនេះត្រូវបានពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០០៤/២០០៥ ដើម្បីកែលំអគុណភាពទិន្នន័យ និងកែសម្រួលសូចនាករដែលមានស្រាប់ក៏ដូចជាដាក់បន្ថែមនូវសូចនាករស្ដីពីសុខភាព ការអប់រំ កិច្ចការពារ ទឹក និងអនាម័យផងដែរ។ មូលដ្ឋានទិន្នន័យជាតិឃុំ សង្កាត់ ត្រូវបានប្រមូលរៀងរាល់ឆ្នាំពីសៀវភៅទិន្នន័យតាមភូមិ និងឃុំ សង្កាត់ និងត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់កសាងផែនការវិនិយោគឃុំ សង្កាត់។

៣៥- នៅឆ្នាំ១៩៩៩ ដោយមានការឧបត្ថម្ភថវិកាពីអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ ក្រសួង ស.អ.យ បានបង្កើតប្រព័ន្ធទិន្នន័យដើម្បីប្រមូលផ្ដុំព័ត៌មានអំពីការបញ្ជូនត្រឡប់មកវិញនូវស្ត្រី និងកុមាររងគ្រោះដោយសារការជួញដូរ ដែលបញ្ជូនត្រឡប់មកពីប្រទេសនានា។

នៅឆ្នាំ២០០២ ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារគ្រាប់មីននៅកម្ពុជាត្រូវបានបង្កើតឡើង។ បច្ចុប្បន្នប្រព័ន្ធនេះត្រូវបានកែលំអ និងបានក្លាយជាប្រភពព័ត៌មានបឋមស្ដីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារគ្រាប់មីនបង្កប់ក្នុងដី/យុទ្ធភណ្ឌពុំទាន់ផ្ទុះ។ ប្រព័ន្ធព័ត៌មាននេះត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ។

នៅឆ្នាំ២០០៤ មូលដ្ឋានទិន្នន័យជាតិអំពីបទល្មើសព្រហ្មទណ្ឌខាងផ្លូវភេទ ត្រូវបានបង្កើតឡើងនៅក្រសួងមហាផ្ទៃ ដើម្បីប្រមូលផ្ដុំព័ត៌មានអំពីការរំលោភផ្លូវភេទ ការកេងប្រវ័ញ្ច និងករណីជួញដូរកុមារ ហើយផ្ដល់ព័ត៌មានលម្អិតអំពីករណីរបស់ជនរងគ្រោះ និងជនសង្ស័យ ដែលអាចប្រើប្រាស់ជាឧបករណ៍គ្រប់គ្រងករណីនៃបទល្មើស។

ក្នុងឆ្នាំ២០០៤ ក.ជ.ក.ក បានរៀបចំប្រព័ន្ធព័ត៌មានស្ដីពីការជួញដូរ អាជីវកម្មផ្លូវភេទលើកុមារ (TSEC Info) ដែលជាទិន្នន័យស្ដីពីការជួញដូរ អាជីវកម្មផ្លូវភេទលើកុមារ ផ្អែកតាមគំរូទិន្នន័យពីតំបន់ស្ដីពីការជួញដូរអាជីវកម្មផ្លូវភេទលើកុមារ(CSECInfo)។ មកដល់ពេលនេះ TSECInfo មានទិន្នន័យនៅមានកម្រិតនៅឡើយ ដោយមានភាពលំបាកក្នុងការប្រមូលព័ត៌មាន និងធនធានមនុស្សនៅមានកម្រិត។

ក្នុងឆ្នាំ២០០៧ ក្រសួង ស.អ.យ បានបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យអំពីការថែទាំជំនួសសម្រាប់កុមារ ដើម្បីប្រមូលទិន្នន័យទៀងទាត់អំពីកុមាររស់នៅក្រោមការថែទាំក្នុងមណ្ឌល។ ស្ថិតិចុងក្រោយដែលប្រមូលបានបង្ហាញថាកុមារសរុបចំនួន៨.៦៦៦នាក់ ដែលកំពុងរស់នៅក្រោមការថែទាំរយៈពេលវែងនៅក្នុងមជ្ឈមណ្ឌលសរុបចំនួន១៩៦ ក្នុងនោះមានមជ្ឈមណ្ឌលរដ្ឋចំនួន២០ និងមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន១៧៦។

នៅឆ្នាំ២០០៦ ក្រសួងយុត្តិធម៌ បានបង្កើតប្រព័ន្ធប្រមូលទិន្នន័យ និងប្រព័ន្ធត្រួតពិនិត្យយុត្តិធម៌អនីតិជនរួម

ទាំងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីត្រួតពិនិត្យលើដំណើរការរឿងក្តីរបស់កុមារទំនាស់នឹងច្បាប់ និងកុមាររងគ្រោះ នៅពេលដែលរឿងក្តីឆ្លងកាត់ដំណាក់កាល និងស្ថាប័នផ្សេងៗនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ប្រព័ន្ធនេះនឹងបញ្ចូលទិន្នន័យរបស់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងៗទៀត។

## ង- ការបែងចែកថវិកា

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ផ្តល់អាទិភាពដល់ការធានាថា ភាគច្រើនបំផុតនៃធនធានដែលមានត្រូវបានផ្តល់ដល់ផ្នែកសុខភាព អប់រំ និងសេវាកម្មសង្គមសម្រាប់កុមារ ហើយការយកចិត្តទុកដាក់ជាពិសេសត្រូវផ្តោតទៅលើការការពារក្រុមកុមារ ដែលងាយទទួលរងគ្រោះ និងជួបការលំបាក។

៣៦- រាជរដ្ឋាភិបាលមានគោលនយោបាយផ្តល់អាទិភាពខ្ពស់ទៅលើការចំណាយផ្នែកសង្គមកិច្ចនិងសេដ្ឋកិច្ច។ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះក្រសួងចំនួន៤ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ។ ចាប់ពីឆ្នាំ២០០០-២០០៦ ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បានកើនពី១៣,៦% ដល់១៨,៨% ក្រសួងសុខាភិបាលបានកើនពី៨,៤% ដល់១១% ក្រសួងអភិវឌ្ឍន៍ជនបទបានកើនពី០,៦% ដល់១,៣% ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកើនពី១,៩% ដល់២,៤%។ ដោយឡែក ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានចំណាយសម្រាប់ជួយដល់ជនងាយរងគ្រោះ រួមទាំងកុមារកំព្រានៅក្នុងមជ្ឈមណ្ឌលរដ្ឋ ជនចាស់ជរា និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្មបានកើនឡើងពី៣,៩៤% នៅឆ្នាំ២០០៣ ដល់៦,៦៦% នៅឆ្នាំ២០០៦ នៃកញ្ចប់ថវិកាជាតិសរុប។

## ច- ការផ្សព្វផ្សាយ និងការយល់ដឹងអំពីអនុសញ្ញា

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្សព្វផ្សាយគោលការណ៍ និងបទប្បញ្ញត្តិរបស់អនុសញ្ញា ដើម្បីឱ្យសង្គមដឹងពីសិទ្ធិកុមារ គួរផ្តោតជាពិសេសទៅលើការផ្សព្វផ្សាយអនុសញ្ញាក្នុងចំណោមជនជាតិភាគតិច និងអ្នករស់នៅជនបទ និងតំបន់ដាច់ស្រយាល។

៣៧- កម្ពុជាបានធ្វើសកម្មភាពមួយចំនួនធំដោយផ្ទាល់ និងដោយប្រយោល ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិកុមារ អំពីកិច្ចខិតខំប្រឹងប្រែងដែលពាក់ព័ន្ធទៅនឹងស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងក្រុម

មនុស្សផ្សេងទៀត ដូចជាព្រះសង្ឃ ដូនជី អាចារ្យ។ ក្រសួងព័ត៌មានបានចលនាឱ្យមានការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងធ្វើជាឃោសនាខ្លីៗ ក្នុងគោលបំណងជំរុញការយល់ដឹងជាសាធារណៈអំពីសិទ្ធិកុមារ។ ការបង្កើនការយល់ដឹងត្រូវបានធ្វើឡើងក្នុងស្រទាប់មន្ត្រីរាជរដ្ឋាភិបាល និងស្ថាប័នជំនាញ រាប់បញ្ចូលទាំងនគរបាល និងអាជ្ញាធរមូលដ្ឋានផង។

៣៨- នៅខែមករា ឆ្នាំ២០០១ ដោយមានការគាំទ្រថវិកាពីអង្គការយូនីសេហ្វ និងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃ អ.ស.ប ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.ក) បានរៀបចំធ្វើសិក្ខាសាលាថ្នាក់ជាតិមួយ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប ដែលមានអ្នកចូលរួមប្រហែល១០០នាក់ ជាមន្ត្រីរាជរដ្ឋាភិបាលមកពីក្រសួង ស្ថាប័ន និងតំណាងអង្គការជាតិ/អន្តរជាតិ។ គោលបំណងរបស់សិក្ខាសាលា គឺដើម្បីផ្សព្វផ្សាយសេចក្តីសង្កេតចុងក្រោយរបស់អ.ស.ប និងរកវិធីសាស្ត្រអនុវត្ត។ សមាជិកអង្គសិក្ខាសាលាបានលើកអនុសាសន៍ពាក់ព័ន្ធទៅនឹងបញ្ហាជាច្រើន ឧទាហរណ៍ ចំណុចវិធានការអនុវត្តទូទៅ រដ្ឋាភិបាលគួរពង្រឹងការអនុវត្តច្បាប់ ពិនិត្យឡើងវិញលិខិតបទដ្ឋានទាក់ទងនឹងការចុះបញ្ជីកំណើត និងកែលំអច្បាប់ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញា។

៣៩- នៅឆ្នាំ២០០២ ក.ជ.ក.ក បានរៀបចំវេទិកាកុមារនៅក្នុងខេត្តបីដែលមានការចូលរួមពីកុមារ ជាសិស្សសាលា កុមារកំព្រា កុមារអនាថាដែលស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងអង្គការ រួមទាំងលោកគ្រូ អ្នកគ្រូមកពីខេត្ត/ក្រុងចំនួន៦។ វេទិកានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យបានសមស្របតាមស្ថានភាពសង្គមកម្ពុជា លើកតម្កើងតម្លៃរបស់កុមារ និងជំរុញការចូលរួមរបស់កុមារក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។

៤០- រៀងរាល់ឆ្នាំ នាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបណ្តុះបណ្តាលអនុសញ្ញាស្តីពីសិទ្ធិកុមារដល់នាយក នាយករង លោកគ្រូ អ្នកគ្រូ និងកុមារជាសមាជិកក្រុមប្រឹក្សាកុមារនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅទូទាំង២៤ខេត្ត/ក្រុង។ កុមារទាំងនោះត្រូវបានសួរសាកល្បងពីសិទ្ធកុមារ ដើម្បីវាយតម្លៃដល់ការយល់ដឹង និងមានការជូនរង្វាន់ជ័យលាភី។

៤១- អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានធ្វើសកម្មភាពផ្សព្វផ្សាយសិទ្ធិកុមារដល់ប្រជាពលរដ្ឋក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងកុមារជាសិស្សសាលា តាមរយៈការបញ្ចាំងវីដេអូ ខិតប័ណ្ណផ្សព្វផ្សាយ ផ្ទាំងរូបភាព និងកូនសៀវភៅដែលមានរូបភាព និងខ្លឹមសារខ្លីៗងាយយល់។ ទន្ទឹមនេះ នៅឆ្នាំ២០០៥ អង្គការវឌ្ឍនភាពបានធ្វើការជាមួយកុមារសកម្មជនសិទ្ធិកុមារចំនួន៩៤០នាក់ មកពីភូមិដាច់ស្រយាលចំនួន១១៣ភូមិនៅក្នុងខេត្តពោធិសាត់ ដើម្បីផ្សព្វផ្សាយអនុសញ្ញាសិទ្ធិកុមារ និងបានបញ្ចូលសិទ្ធិកុមារទៅក្នុងកម្មវិធីបណ្ណាល័យចល័តរបស់អង្គការ។ ដោយឡែក អង្គការមូលនិធិសិទ្ធិកុមារ(CRF) បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ធ្វើការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារដល់គរុសិស្សនៅសាលាគរុកោសល្យ និងវិក្រឹត្យការចំនួន៧ និងផ្សព្វផ្សាយជូនលោកគ្រូ អ្នកគ្រូ និង

សិស្សនៅសាលាបឋមសិក្សានិងមធ្យមសិក្សាចំនួន៤៥ ក្នុង៣ខេត្ត (កណ្តាល សៀមរាប កំពង់ចាម) ជាលទ្ធផល គរុសិស្ស លោកគ្រូ អ្នកគ្រូ និងសិស្ស មានការយល់ដឹងអំពីសិទ្ធិទាំង៤របស់កុមារ ជាពិសេសយល់ដឹងអំពីការចូលរួមរបស់កុមារ និងកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការធ្វើទារុណកម្មលើរាងកាយកុមារ និងមានរៀបចំបោះពុម្ពជាសៀវភៅសម្រាប់លោកគ្រូ អ្នកគ្រូ។

៤២- ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ សំណុំឯកសារទាក់ទាញមតិគាំទ្រដែលក្នុងនោះមានទាំងអាំងឌីកាទ័រសំខាន់ៗទាក់ទងដល់ស្ត្រី និងកុមារផង ត្រូវបានប្រគល់ជូនអភិបាលខេត្ត និងស្រុក ដើម្បីដាក់បញ្ចូលបញ្ហាស្ត្រី និងកុមារ ទៅក្នុងការងារអាទិភាពរបស់ខ្លួន។ មកដល់ឆ្នាំ២០០៦នេះ គណៈកម្មាធិការឃុំសម្រាប់ការងារស្ត្រី និងកុមារ ត្រូវបានបង្កើតឡើងនៅក្នុងឃុំចំនួន២០៣ នៃខេត្តទាំង៦ ដែលគាំទ្រដោយអង្គការយូនីសេហ្វ។ គណៈកម្មាធិការទាំងនេះមានតួនាទីផ្តល់ប្រឹក្សាជូនក្រុមប្រឹក្សាឃុំ អំពីបញ្ហាទាំងឡាយដែលទាក់ទងដល់ស្ត្រី និងកុមារ។ ការពង្រីកគណៈកម្មាធិការនេះសម្រាប់ទូទាំងប្រទេសកំពុងត្រូវបានគ្រោងឡើង។ ចាប់តាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ នៅឆ្នាំ២០០២មក ក្រុមប្រឹក្សាឃុំ សង្កាត់ បានជ្រើសរើសផងដែរនូវសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ភេទស្រី ឬស្ត្រីនៅក្នុងឃុំ ដើម្បីកាន់កិច្ចការផ្នែកស្ត្រី និងកុមារ។ តួនាទីរបស់គាត់គឺធានាថា បញ្ហាទាក់ទងសិទ្ធិរបស់កុមារ និងស្ត្រី ត្រូវបានដាក់បញ្ចូលក្នុងគម្រោង និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

៤៣- ក.ជ.ក.ក សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងកុមារ បានរៀបចំទិវាកុមារអន្តរ-ជាតិ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារជារៀងរាល់ឆ្នាំ។ យុទ្ធនាការនេះមានទិសដៅលើកកម្ពស់ការយល់ដឹងដល់មន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សាធារណជន និងកុមារ អំពីសិទ្ធិ និងបញ្ហារបស់កុមារ ពិសេសអំពើហិង្សា រួមទាំងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

## ឆ- <u>ការហ្វឹកហ្វឺនដល់អ្នកជំនាញ</u>

៤៤- នៅឆ្នាំ២០០៤ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រិតការវិជ្ជាជីវៈមេធាវី បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោលអំពីសិទ្ធិកុមារ និងការការពារកុមារតាមផ្លូវច្បាប់ ដោយមានរៀបចំជាសៀវភៅសម្រាប់ការបណ្តុះបណ្តាលនេះ។ ការបណ្តុះបណ្តាលដំបូងសម្រាប់និស្សិតមេធាវីចំនួន៦០នាក់ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០០៥ ហើយការបណ្តុះបណ្តាលលើកទី២សម្រាប់និស្សិតមេធាវីចំនួន៥០នាក់ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០០៦ និងលើកទី៣បានបណ្តុះបណ្តាលសិស្សមេធាវីចំនួន៤៤នាក់ នៅឆ្នាំ២០០៧។ ដោយមានកិច្ចសហការពីក្រសួងយុត្តិធម៌ និងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រិតការវិជ្ជាជីវៈមេធាវី បានធ្វើការបណ្តុះបណ្តាលដល់មេធាវីប្រកបវិជ្ជាជីវៈចំនួន៤០នាក់ ស្តីពីសិទ្ធិកុមារ និងការការពារតាមផ្លូវច្បាប់នៅកម្ពុជា។ ការបណ្តុះបណ្តាលស្រដៀងនេះដែរត្រូវបានធ្វើឡើងនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារ និងនិស្សិតចៅក្រម និងព្រះរាជអាជ្ញា នៅក្នុងឆ្នាំ២០០៦ បាន១០៦នាក់ និងឆ្នាំ២០០៧ បាន២៤០នាក់។

៤៥- ឯកសារគំរូបណ្តុះបណ្តាលចំនួន៤ និងកូនសៀវភៅត្រូវបានរៀបចំរួចរាល់ហើយ ដោយមានការគាំទ្រពីក្រសួងជំនាញមានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ និងក្រសួងមហាផ្ទៃ។ សម្ភារៈបណ្តុះបណ្តាលទាំងអស់ដែលឧបត្ថម្ភដោយអង្គការយូនីសេហ្វត្រូវបានបោះពុម្ព និងផ្តល់ដល់ក្រសួងមហាផ្ទៃដើម្បីចែកផ្សព្វផ្សាយដល់ខេត្ត/ក្រុងទាំង២៤។ ការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិអំពីសុខភាព និងការអប់រំ បានធ្វើឡើងនៅខែកក្កដា ឆ្នាំ២០០៦ ដោយមានគ្រូបង្គោលមកពីក្រសួង និងខេត្តនានា។ ពីខែសីហា ដល់ខែតុលា ឆ្នាំ២០០៦ អង្គភាពរដ្ឋបាលថ្នាក់ខេត្តបានសហការជាមួយមន្ទីរសុខាភិបាល និងមន្ទីរអប់រំ ធ្វើការបណ្តុះបណ្តាលថ្នាក់ខេត្តដល់គ្រូបង្គោល បន្ទាប់មកធ្វើនៅថ្នាក់ឃុំទូទាំងប្រទេស។ ការបណ្តុះបណ្តាលថ្នាក់ជាតិដល់គ្រូបង្គោលអំពីការការពារកុមារ និងការធ្វើឱ្យកុមារមានសិទ្ធិពេញលេញ ត្រូវបានរៀបចំធ្វើឡើងសម្រាប់គ្រូបង្គោលមកពី២៤ខេត្ត/ក្រុង។ នៅឆ្នាំ២០០៦ ក្រសួងមហាផ្ទៃបានសហការជាមួយអង្គការមួយចំនួន ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនៅទាំង២៤ខេត្ត/ក្រុង ក្នុងនោះ១៨ខេត្ត/ក្រុង គាំទ្រដោយអង្គការ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP) តាមរយៈគម្រោងភាពជាដៃគូសម្រាប់រដ្ឋបាលមូលដ្ឋាន និងធនាគារអភិវឌ្ឍអាស៊ី តាមរយៈគម្រោងគាំទ្រការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ និង៦ខេត្តទៀត គាំទ្រដោយអង្គការយូនីសេហ្វ និងបានធ្វើការបណ្តុះបណ្តាលដល់គ្រូបង្គោលចំនួន៣៦នាក់ សម្រាប់ធ្វើការបណ្តុះបណ្តាលបន្តដល់អ្នកធ្វើការងារផ្នែកសង្គម។

## III. និយមន័យកុមារ

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ដាក់បញ្ចូលនិយមន័យកុមារទៅក្នុងច្បាប់។
- ក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ សូមពិចារណាអំពីការដាក់បញ្ចូលនូវអាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការព្រមព្រៀងរួមភេទ។
- អនុវត្តន៍ច្បាប់ស្តីពីអាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍។

### ក- <u>បញ្ចូលនិយមន័យកុមារទៅក្នុងច្បាប់</u> (អនុសញ្ញាមាត្រា ១)

៤៦- មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានកំណត់អំពីសិទ្ធិទាំង៤របស់កុមារ។ និយមន័យរបស់កុមារត្រូវបានដាក់បញ្ចូលក្នុងច្បាប់ និងសេចក្តីព្រាងច្បាប់មួយចំនួន។ ឧទាហរណ៍ មាត្រា១៧ នៃសេចក្តីព្រាងក្រមរដ្ឋប្បវេណីចែងថា អនីតិជនគឺជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។ ចំពោះអាយុនីតិភាពវិញ មាត្រា៩៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់ត្រឹម១៨ឆ្នាំ។

៤៧- អាយុអប្បបរមាសម្រាប់ការយល់ព្រមរួមភេទតាមផ្លូវច្បាប់ មានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី មាត្រា ២២៣១-១ ដែលកំណត់ចាប់ពីអាយុ១៥ឆ្នាំឡើងទៅ ។

៤៨- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២១២ ចែងថា "អនីតិជនអាយុក្រោម១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ "។ ក្រមព្រហ្មទណ្ឌថ្មីកំណត់ថា អាយុអប្បបរមាសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺ១៨ឆ្នាំ ( មាត្រា ៣៨) ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើសតម្រូវ ( មាត្រា៣៩) ។

៤៩- ច្បាប់ស្ដីពីការងារនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីអាយុអប្បបរមាដើម្បីចូលធ្វើការ ។ អាយុអប្បបរមានៃការធ្វើការងារផ្ដល់កម្រៃរបស់កុមារ គឺអាយុ១៥ឆ្នាំ ឬលើសពីនេះ ។ កុមារអាចធ្វើកិច្ចការបានដែរ សូម្បីនៅអាយុ១២ឆ្នាំ បើសិនជាការងារស្រាលៗ ហើយមិនធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងការរីកលូតលាស់ផ្លូវចិត្ត និងមិនប៉ះពាល់ដល់ការរៀនសូត្រ ការបណ្ដុះបណ្ដាលនានារបស់ពួកគេ ។

**ង- <u>អនុវត្តន៍អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍</u>**

៥០- អាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើដែលមានឧបសគ្គដល់សេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍ត្រូវហាមឃាត់ ។ បុរសចាប់ពីអាយុ២០ឆ្នាំ និងនារីចាប់ពីអាយុ១៨ឆ្នាំឡើងទៅអាចរៀបការបាន ។ ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះហើយមានការអនុញ្ញាតពីឪពុកម្ដាយ ឬអាណាព្យាបាល ។

## IV. គោលការណ៍ទូទៅ

**ក- <u>ការមិនរើសអើង</u> ( អនុសញ្ញាមាត្រា២)**

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ចាត់វិធានការយ៉ាងមានប្រសិទ្ធភាព ដើម្បីលុបបំបាត់ការរើសអើងចំពោះកុមារី ជាពិសេសទាក់ទងនឹងការទទួលបានការអប់រំ ។
- លុបបំបាត់ការរើសអើងចំពោះកុមាររស់នៅ ឬធ្វើការតាមចិញ្ចើមថ្នល់ កុមារដែលជាក្រុមជនជាតិភាគតិច ជាពិសេសអ្នកមានដើមកំណើតជាជនជាតិវៀតណាម កុមារពិការ និងកុមារមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ ។

៥១- ក្រសួងអប់រំ យុវជន និងកីឡា បានលុបបំបាត់វិភាគទានក្រៅផ្លូវការរបស់មាតាបិតា សម្រាប់សិស្សនៅកម្រិតអប់រំមូលដ្ឋាន ដោយរដ្ឋាភិបាលបានបង្កើនថវិកាដល់សាលាសម្រាប់ដំណើរការ ។ ក្រសួងបានពង្រឹងការងារគ្រប់គ្រងការរៀននិងការបង្រៀន គាំទ្រ និងផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ ពិសេសសិស្សស្រីមានចំនួនសរុប៦០.៣៧៤ នាក់ ដែលរស់នៅតំបន់ជនបទ តំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងជាជនជាតិភាគតិច ដើម្បីឱ្យពួកគេបាន

ចូលរៀន។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាមធ្យមសិក្សាបឋមភូមិចំនួន២១៥ ក្នុងខេត្ត/ក្រុងចំនួន១៧ ក្នុងឆ្នាំសិក្សា២០០៣-២០០៤។ ទន្ទឹមនេះដែរ ក្រសួងបានផ្តល់អាទិភាពឱ្យអ្នកគ្រូចេញថ្មីជ្រើសរើសសាលាដែលអាចទៅបម្រើការងារបាន ដើម្បីជៀសវាងការលំបាកដែលបុគ្គលិកនៅដាច់ស្រយាលអាចប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួន។ ក្រសួងបានផ្តល់ឱកាសឱ្យសិស្សស្រីពិការ បានចូលរៀននៅមជ្ឈមណ្ឌលកុមារពិការដោយផ្តល់អាហារូបករណ៍ ការយកចិត្តទុកដាក់ទៅលើការរស់នៅ ហូបចុក និងស្លៀកពាក់បានសមរម្យ។ បានកសាងអន្តេវាសិកដ្ឋាននៅតំបន់ដាច់ស្រយាល តំបន់ជនបទ តំបន់ជួបការលំបាក (ខេត្តមណ្ឌលគិរីមាន៣កន្លែង ខេត្តកំពង់ធំមាន១កន្លែង និងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាចំនួន៩កន្លែង) សម្រាប់ផ្តល់ឱកាសដល់សិស្សស្រីក្រីក្របានចូលរៀន ដែលមានចំនួនសរុបសម្រាប់សិស្សសាលាចំណេះទូទៅ១.០៨៣នាក់ សិស្សឧត្តមសិក្សា២៨២នាក់។ ទន្ទឹមនេះដែរ ចាប់ពីឆ្នាំ២០០១មក ក្រសួងមានយុទ្ធសាស្ត្រពង្រីកចំនួនសាលានៅជិតភូមិចំនួន៦.៧៤២សាលា នៅតំបន់ជនបទ និង៥៤៦សាលានៅតំបន់ដាច់ស្រយាល។ ក្រសួងបានលើកគោលនយោបាយក្នុងឃុំមួយមានអនុវិទ្យាល័យមួយ និងក្នុងស្រុក យ៉ាងហោចណាស់មានវិទ្យាល័យមួយ ឬកែប្រែសាលាបង្គោលក្នុងកម្រងសាលាបឋមសិក្សាឱ្យទៅជាអនុវិទ្យាល័យ ដើម្បីជៀសវាងកុំឱ្យសិស្សស្រីក្រីក្របោះបង់ចោលការសិក្សា ដោយមូលហេតុផ្លូវឆ្ងាយ ឬខ្វះសុវត្ថិភាព។ លើសពីនេះទៀត ក្រសួងបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំ ដែលក្នុងចំណោមគោលបំណងនៃច្បាប់នេះ មានគោលបំណងមួយគឺលុបបំបាត់ការរើសអើងក្នុងវិស័យអប់រំ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈ នយោបាយ ដើមកំណើតសង្គម ឬជាតិពន្ធ ទ្រព្យសម្បត្តិ ពិការភាព កំណើត ឬឋានៈ ដទៃទៀតឡើយ។

៥២- គោលនយោបាយរបស់រាជរដ្ឋាភិបាល ពុំមានការរើសអើងឡើយចំពោះកុមារនៅតាមចិញ្ចើមថ្នល់ និងកុមារជនជាតិភាគតិច ជាពិសេសកុមារដែលមានដើមកំណើតជាជនជាតិវៀតណាម។

ថ្មីៗនេះ អង្គការផ្លែនអន្តរជាតិបានសហការជាមួយក្រសួងមហាផ្ទៃធ្វើការសិក្សាអំពីបញ្ហាចុះបញ្ជីកំណើត ហើយបានលើកអនុសាសន៍មួយចំនួន ដែលបានមកពីការសិក្សាប្រៀបធៀបពីរបៀបចុះបញ្ជីកំណើតនេះជូនដល់ក្រសួងមហាផ្ទៃ។ អនុសាសន៍ទាំងនេះនឹងជួយក្រសួងឱ្យមានប្រព័ន្ធចុះបញ្ជីកំណើតប្រសើរជាងនេះ។ ប្រព័ន្ធថ្មីអាចជួយដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងស្ថានភាពរបស់ជនជាតិវៀតណាម។

មាត្រា៣៦នៃច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ហាមដាច់ខាតការរើសអើងគ្រប់បែបយ៉ាងក្នុងជីវិតរបស់បុគ្គល ឬសមាជិកគ្រួសារពួកគេដែលសង្ស័យថា ឬដឹងថាមានមេរោគអេដស៍ ដូចជាការដំឡើងឋានន្តរសក្តិ ការផ្តល់ការងារ។ ប្រព័ន្ធសុវត្ថិភាព និងជីវភាពរបស់ជនពិការត្រូវបានយកចិត្តទុកដាក់។ សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានរៀបចំនៅឆ្នាំ២០០១ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយនៅឆ្នាំ២០០៧ សេចក្តីព្រាងច្បាប់នេះបានឆ្លងអង្គប្រជុំទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ និងបានបញ្ជូនទៅសុំការអនុម័តពីរដ្ឋសភា។ ច្បាប់នេះមានគោលបំណងពង្រឹងការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ជនពិការ ព្រមទាំងប្រឆាំងការរើសអើងចំពោះជនពិការ ធានាការចូលរួមគ្រប់សកម្មភាពក្នុងសង្គមដូចជនដែលគ្មានពិការភាពដែរ។

## ៩- ឧត្តមប្រយោជន៍របស់កុមារ (អនុសញ្ញាមាត្រា៣)

៥៣- គោលការណ៍ទូទៅរបស់អនុសញ្ញា ត្រូវបានពិចារណាជាមូលដ្ឋានក្នុងការអភិវឌ្ឍច្បាប់សំខាន់ៗ និងកម្មវិធីដែលទាក់ទងដល់កុមារ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធមិអនីតិជនទំនាស់នឹងច្បាប់ តម្រូវឱ្យពិចារណាទៅលើសកម្មភាពទាំងអស់ទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់ អំពីឧត្តមប្រយោជន៍របស់ពួកគេ និងត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍជាអតិបរមារបស់អនីតិជន។ អនុក្រឹត្យលេខ២៩ ឆ្នាំ២០០១ បានប្រគល់ភារកិច្ចឱ្យក្រសួងសង្គមកិច្ច និងក្រសួងពាក់ព័ន្ធ ដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស ហើយទាមទារឱ្យគោរពនូវឧត្តមប្រយោជន៍របស់កុមារក្នុងដំណើរការសុំកូន។ ដូចគ្នានេះដែរ សេចក្តីព្រាងច្បាប់ស្តីពីសុំកូនអន្តរប្រទេសក៏បានពិចារណាអំពីឧត្តមប្រយោជន៍របស់កុមារផងដែរ។

## ឥ- សិទ្ធិរស់រានមានជីវិត និងអភិវឌ្ឍន៍ (អនុសញ្ញាមាត្រា ៦)

៥៤- ដោយសារបញ្ហាសុខភាព ឬសេវាថែទាំ ដូចជាការផ្តល់អាហារូបត្ថម្ភ ការផ្តល់ថ្នាំបង្ការ និងវិធានការដើម្បីកាត់បន្ថយមរណភាពរបស់កុមារ ដែលទាក់ទងនឹងសិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ ពត៌មានលំអិតនឹងមានបង្ហាញជូនក្នុងផ្នែកទី៧នៃរបាយការណ៍នេះ។

## ឃ- គោរពយោបល់របស់កុមារ (អនុសញ្ញាមាត្រា ១២)

៥៥- មាត្រា៧៤ នៃរដ្ឋធម្មនុញ្ញបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិក្នុងការសំដែងទស្សនៈដោយសេរី"។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំធ្វើវេទិកាកុមារ ដើម្បីផ្តល់ឱកាសដល់កុមារឱ្យបញ្ចេញទស្សនៈ មតិយោបល់ និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ឧទាហរណ៍ សេចក្តីព្រាងផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ បានដាក់បញ្ចូលទស្សនៈរបស់កុមារទៅក្នុងឯកសារចុងក្រោយដែរ។

# V. សិទ្ធិ និងសេរីភាព

## ក- ការចុះបញ្ជីកំណើត

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប***

- ធ្វើឱ្យការចុះបញ្ជីកំណើតមានលក្ខណៈជាកាតព្វកិច្ចសម្រាប់កុមារទាំងអស់ដោយគ្មានការរើសអើង ដោយផ្អែកលើច្បាប់។
- ចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីអនុវត្តអនុក្រិត្យដែលមានស្រាប់ (ឆ្នាំ១៩៩៧) ទាក់ទងនឹងសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ ជាពិសេស ដើម្បីធានាថា កុមារទាំងអស់ដែលមិនទាន់បានចុះបញ្ជីកំណើតនៅពេលកើតត្រូវបានចុះ។
- ធ្វើយុទ្ធនាការបង្កើនការយល់ដឹង ដើម្បីលើកទឹកចិត្តការចុះបញ្ជីកំណើតកុមារទាំងអស់នៅពេលកើត។

៥៦- រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ និងសេចក្ដីណែនាំដែលពាក់ព័ន្ធ ដើម្បីធ្វើឱ្យការចុះបញ្ជីកំណើតកាន់តែប្រសើរឡើង ឧទាហរណ៍ មាត្រា២៥នៃអនុក្រឹត្យលេខ១៧ ខែមិថុនា ឆ្នាំ២០០៤ បានចែងអំពីការសម្រួលនូវការចុះបញ្ជីកំណើតចំពោះកុមារដែលមិនទាន់បានចុះបញ្ជី ក្នុងរយៈ៣០ថ្ងៃក្រោយកំណើត។ អនុក្រឹត្យថ្មីស្ដីពីការចុះអត្រានុកូលដ្ឋានកំណើត កំពុងតែត្រូវបានពិនិត្យដោយក្រសួងមហាផ្ទៃ ដោយសហការជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍ។ ក្រមរដ្ឋប្បវេណីដែលតម្រូវឱ្យចុះអត្រានុកូលដ្ឋានកំណើត ជាកាតព្វកិច្ច ត្រូវបានអនុម័តដោយរដ្ឋសភានៅឆ្នាំ២០០៧។

៥៧- ក្រសួងមហាផ្ទៃបានជំរុញការផ្សព្វផ្សាយការងារអត្រានុកូលដ្ឋានតាមវិទ្យុ និងទូរទស្សន៍ សំដៅបង្កើនការយល់ដឹង និងការអនុវត្តការងារអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនោះដែរ ប្រព័ន្ធរាយការណ៍ត្រូវបានបង្កើតឡើងនៅថ្នាក់ស្រុក/ខណ្ឌ ដើម្បីកត់ត្រាស្ថិតិរបស់ប្រជាជន និងលទ្ធផលនៃការចុះអាត្រានុកូលដ្ឋានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។

៥៨- ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៦ ក្នុងចំណោមប្រជាជនសរុបចំនួន ១២.៨៦០.១២៤នាក់ មាន៧១៦.៦០៨នាក់ បានចុះសំបុត្រកំណើត (ស្រី៣៤១.៣១៩នាក់)។ មានប្រជាជនចំនួន ១១.៨២៨.២០៨នាក់ (ស្រ្តី៥.៩២៦.៩៤៣នាក់) បានចុះបញ្ជីកំណើត និងមានសំបុត្របញ្ជាក់កំណើតដែលស្មើនឹង ៩១,៩៨% នៃប្រជាជនសរុប ក្នុងឆ្នាំ២០០៦[១២]។

## ខ- សញ្ជាតិ (អនុសញ្ញាមាត្រា៧)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ពិនិត្យឡើងវិញនូវច្បាប់ស្ដីពីសញ្ជាតិតាមខ្លឹមសាររបស់អនុសញ្ញា ដើម្បីលុបបំបាត់មូលដ្ឋានទាំងអស់នៃការរើសអើងដែលអាចកើតមាន ហើយបំបាត់ និងរារាំងកុំឱ្យកុមារក្លាយទៅជាជនគ្មានសញ្ជាតិ។

៥៩- តាមច្បាប់ស្ដីពីសញ្ជាតិ សញ្ជាតិខ្មែរត្រូវបានផ្ដល់ដល់ទារកដែលកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទារកកើតនៅក្រៅប្រទេស ឱ្យតែឪពុក ឬម្ដាយមានសញ្ជាតិខ្មែរពីកំណើត ឬត្រូវបានទទួលស្គាល់ថាជាជនជាតិកម្ពុជា។

## គ. ការថែរក្សាអត្តសញ្ញាណ (អនុសញ្ញាមាត្រា៧)

៦០- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងហាមឃាត់ការដកសញ្ជាតិខ្មែរពីប្រជាពលរដ្ឋខ្មែរ រាប់បញ្ចូលទាំងកុមារផង។ មាត្រា១៩ នៃអនុក្រឹត្យលេខ១០៣ តម្រូវឱ្យអាជ្ញាធរចុះបញ្ជីកំណើតឱ្យកុមារដែលត្រូវបានគេបោះបង់ចោល។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានជំរុញឱ្យមានការយកចិត្តទុកដាក់

---

[១២] របាយការណ៍សរុបក្រសួងមហាផ្ទៃ (០១ សីហា ដល់ ៣១ ធ្នូ ២០០៦)។

ចំពោះការងារនេះ ចំពោះកុមារដែលរស់នៅក្នុងមណ្ឌលរដ្ឋ និងមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ដូចមានចែងក្នុងគោលនយោបាយ ស្តីពីការថែទាំជំនួស ។

## យ- សិទ្ធិចូលរួមរបស់កុមារ

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

១. ប្រកាន់យកវិធានការបន្ថែមរាប់បញ្ចូលទាំងការកែទម្រង់ច្បាប់ ដើម្បី ÷

- ពង្រឹងការចូលរួមរបស់កុមារក្នុងគ្រួសារ សាលារៀន និងក្នុងស្ថាប័នដទៃទៀត
- ធានានូវសេរីភាពសំដែងមតិ និងបង្កើតជាសមាគមន៍

២. ចាត់វិធានការ ដើម្បីបង្កើននូវការយល់ដឹងអំពីសិទ្ធិចូលរួមរបស់កុមារក្នុងគ្រួសារ សាលារៀន សហគមន៍ និងស្ថាប័ន ។

៦១- កុមារបានចូលរួមក្នុងវេទិកា និងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើននៅថ្នាក់ជាតិ និងអន្តរជាតិ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អង្គការមិនមែនរដ្ឋាភិបាល (សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ មូលនិធិសិទ្ធិកុមារ) និងអង្គការអន្តរជាតិ ។ វេទិកា និងកិច្ចប្រជុំមានដូចជា ÷

- វេទិកាថ្នាក់ជាតិ និងសិក្ខាសាលាមួយចំនួន ស្តីពីការលើកកម្ពស់សកម្មភាពប្រឆាំងការជួញដូរកុមារនៅកម្ពុជា ដែលមានការចូលរួមពីកុមារជាជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ សិស្សសាលា និងសកម្មជនសិទ្ធិកុមារ មកពីក្លឹបកុមារនិងយុវជន ។ សេចក្តីថ្លែងការណ៍ និងអនុសាសន៍របស់កុមារត្រូវបានពិចារណា និងដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងផែនការជាតិប្រាំឆ្នាំ ស្តីពីការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

- នៅឆ្នាំ២០០៤ និង២០០៧ តំណាងកុមារចំនួន៥រូប បានចូលរួមវេទិកាកុមារមហាអនុតំបន់ទន្លេមេគង្គ ។ សេចក្តីថ្លែងការ និងអនុសាសន៍របស់កុមារ ត្រូវបានលើកឡើងជូនមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំង៦ ដើម្បីដោះស្រាយតាមប្រទេសរៀងៗខ្លួន ។ ដោយឡែក នៅឆ្នាំ២០០៧ អនុសាសន៍របស់កុមារត្រូវបានដាក់បញ្ចូលក្នុងរបៀបវីរៈសម្រាប់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលប្រទេសទាំង៦ក្នុងតំបន់មេគង្គ ដែលប្រព្រឹត្តទៅនៅទីក្រុងប៉េកាំងនាខែធ្នូ ឆ្នាំ២០០៧ ។

- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីអំពើហិង្សាលើកុមារ មានកុមារចូលរួមចំនួន២២៥នាក់ ។ តំណាងកុមារចំនួន៣០នាក់ បានចូលរួមក្នុងវេទិកាថ្នាក់ជាតិសម្រាប់មនុស្សពេញវ័យ ។ នៅឆ្នាំ២០០៥ តំណាងកុមារ២នាក់ត្រូវបាន ជ្រើសរើសឱ្យទៅចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ ។

- តំណាងកុមារបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៥ ស្តីពីកុមារ តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅទីក្រុងប៉េកាំង ប្រទេសចិន នៅឆ្នាំ២០០០ និងលើកទី៦ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០០៣

ហើយនិងលើកទី៧ នៅខេត្តសៀមរាប ប្រទេសកម្ពុជាឆ្នាំ២០០៥។

- កុមារ៥រូបបានចូលរួមក្នុងសន្និសីទកុមារលើកទី១ តំបន់អាស៊ីអាគ្នេយ៍ដែលបានប្រព្រឹត្តទៅនៅប្រទេសហ្វីលីពីន ឆ្នាំ២០០៦។ កុមារី១រូបបានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ខ្ពស់ ដើម្បីពិនិត្យទៅលើលទ្ធផលនៃសម័យប្រជុំពិសេសសម្រាប់កុមារនៅទីស្នាក់ការអង្គការសហប្រជាជាតិទីក្រុងញូវយ៉ក នៅឆ្នាំ២០០៧។

- កុមារជាង៣.០០០នាក់បានចូលរួមក្នុងពិធីទិវាកុមារអន្តរជាតិ ១មិថុនា ដែលប្រព្រឹត្តទៅរាងរាល់ឆ្នាំក្រោមអធិបតីភាពថ្នាក់ដឹកនាំរបស់រាជរដ្ឋាភិបាល ភ្ញៀវជាតិ និងអន្តរជាតិ។ នៅក្នុងពិធីនោះ តំណាងកុមារបានឡើងថ្លែងសុន្ទរកថា សំដែងមតិយោបល់ និងសំណូមពររបស់ពួកគេជូនរាជរដ្ឋាភិបាល។

៦២- កុមារនៃអង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម (CAMP) បានចូលរួមក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ដោយសហការជាមួយក្រសួងទេសចរណ៍។

៦៣- កម្មវិធី "យុវវ័យថ្ងៃនេះ" រយៈពេល១៥នាទី និងកម្មវិធីជាច្រើនទៀតដែលមានប្រធានបទស្តីពីពលកម្មកុមារ ការជួញដូរកុមារ មេរោគអេដស៍/ជំងឺអេដស៍ សុខភាព និងអាហារូបត្ថម្ភ ត្រូវបានកសាងឡើងដោយយុវជន ហើយបានចាក់ផ្សាយតាមទូរទស្សន៍ជាតិ រៀងរាល់សប្តាហ៍ ដោយមានការឧបត្ថមពីអង្គការយូនីសេស។ យុវជន២៧នាក់ បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈខាងសារព័ត៌មានដើម្បីកសាងកម្មវិធីទូរទស្សន៍នេះ។

## ង- សេរីភាពក្នុងការសំដែងមតិ (អនុសញ្ញាមាត្រា១៣)

៦៤- មាត្រា៤១ នៃរដ្ឋធម្មនុញ្ញបានចែងអំពីសេរីភាពក្នុងការបញ្ចេញមតិ។ ច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលដែលចែងអំពីការលុបចោលនូវការផ្តន្ទាទោសដាក់គុកពី៨ថ្ងៃទៅ១ឆ្នាំ ចំពោះជនដែលបរិហាកេរ្តិ៍ និងជេរប្រមាថមកត្រឹមតែការដាក់ពិន័យជាប្រាក់ប៉ុណ្ណោះ។

## ច- សេរីភាពផ្នែកគំនិត មនសិកា និងសាសនា (អនុសញ្ញាមាត្រា១៤)

៦៥- មាត្រា៤៣ នៃរដ្ឋធម្មនុញ្ញបានចែងអំពីសេរីភាពខាងជំនឿសាសនា។ រាជរដ្ឋាភិបាលបានអនុញ្ញាតិឱ្យបង្កើតព្រះវិហារគ្រីស្តសាសនា មូស្លីម និងជំនឿផ្សេងៗទៀត ដែលជាកន្លែងអ្នកកាន់សាសនាទាំងនេះអាចគោរពជំនឿរបស់ពួកគេ។ ទាក់ទងនឹងបញ្ហានេះ ពុំមានការដាក់កម្រិតណាមួយទៅលើការទទួលបានសេរីភាព និងការគោរពសាសនាឡើយ។

## ឆ- សេរីភាពក្នុងការបង្កើតសមាគម (អនុសញ្ញាមាត្រា១៥)

៦៦- មាត្រា៤២ នៃរដ្ឋធម្មនុញ្ញបានចែងអំពីសិទ្ធិក្នុងការបង្កើតសមាគម។ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនត្រូវបានបង្កើតឡើង ឧទាហរណ៍ អង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម។ គោលបំណងរបស់អង្គការគឺដើម្បីចូលរួម និងធ្វើយុទ្ធនាការប្រឆាំងនឹងទេសចរណ៍ផ្លូវភេទ ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

## ផ- ការការពារជីវិតផ្ទាល់ខ្លួន (អនុសញ្ញាមាត្រា១៦)

៦៧- មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញបានចែងអំពី ការការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយ ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ មាត្រា៥ នៃសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ទំនាស់នឹងច្បាប់បានចែងអំពី ការហាមឃាត់ការផ្សព្វផ្សាយព័ត៌មាន ដែលបញ្ចេញឱ្យដឹងនូវអត្តសញ្ញាណរបស់អនីតិជន។ ការវិនិច្ឆ័យរឿងក្តីរបស់កុមារទំនាស់នឹងច្បាប់ត្រូវធ្វើឡើងជាសម្ងាត់។ ទោះយ៉ាងនេះក្តី ក៏នៅមានករណីផ្សាយរូបថតរបស់កុមារដោយពុំមានលាក់បំបាំងមុខ ឬអត្តសញ្ញាណរបស់ពួកគេឡើយ។

## ឈ- សិទ្ធិទទួលបានព័ត៌មានសមស្រប (អនុសញ្ញាមាត្រា១៧)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ធ្វើច្បាប់ពិសេសដើម្បីការពារកុមារពីព័ត៌មានមិនសមស្រប ជាពិសេសពីកម្មវិធីទូរទស្សន៍ និងភាពយន្តដែលមានរូបភាពអាសអាភាស អំពើហិង្សា និងដើម្បីធានាថាកុមារទទួលបានព័ត៌មានល្អសមស្រប។

៦៨- រាជរដ្ឋាភិបាលបានចេញគោលការណ៍ និងវិធានការដើម្បីបង្ក្រាប និងទប់ស្កាត់ការថតខ្សែភាពយន្ត និងវីដេអូ ក្នុងខែកញ្ញា ឆ្នាំ២០០០ ដោយតម្រូវឱ្យគ្រប់ភាពយន្ត និងវីដេអូទាំងអស់ដែលផលិតនៅក្នុងនិងក្រៅប្រទេស មានអាជ្ញាប័ណ្ណជាមុនសិន មុននឹងធ្វើអាជីវកម្ម។ ដើម្បីជំរុញការអនុវត្តអនុក្រឹត្យនេះឱ្យកាន់តែមានប្រសិទ្ធភាពនៅខែតុលា ឆ្នាំ២០០០ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចេញសារាចរណែនាំថា ក្រសួងនឹងមិនផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើការផលិតកាសែតវីដេអូ ខារ៉ាអូខេ ដែលមានរូបភាពអាសអាភាស អំពើប្លន់ ការកាប់សម្លាប់ អំពើហិង្សា ការជួញដូរគ្រឿងញៀន អាជីវកម្មផ្លូវភេទ ការជួញដូរកុមារ និងការចាប់ជំរិតកុមារឡើយ។

៦៩- ក្រសួងព័ត៌មានបានចេញសេចក្តីណែនាំ មិនអនុញ្ញាតឱ្យស្ថានីយទូរទស្សន៍បញ្ចាំងឈុតរំលោភ ឈុតអាសអាភាសឡើយ។ ខ្សែភាពយន្តដែលមានសាច់រឿងបង្កប់អំពើកាចសាហាវ ការកាប់សម្លាប់ ការចាប់ជំរិត ភេរវកម្ម ត្រូវតែបញ្ចាំងចាប់ពីក្រោយម៉ោង៩យប់តទៅ។ ស្ថានីយទូរទស្សន៍ទាំងអស់មិនត្រូវបញ្ចាំងរាល់ការសំដែង ដែលមានភាពសាហាវឃោរឃៅដែលអាចប៉ះពាល់ដល់កុមារ ហើយមិនអនុញ្ញាតឱ្យកុមារចូលសំដែងក្នុងកម្មវិធីណាដែលគ្មានខ្លឹមសារអប់រំ ឬដែលអាចបង្ករឱ្យមានឥទ្ធិពលអាក្រក់ដល់កុមារ។ រាល់សម្ភារៈផ្សព្វផ្សាយដែលជំរុញលើកទឹកចិត្តដល់កុមារជក់បារី និងផឹកគ្រឿងស្រវឹងត្រូវបានហាមឃាត់។

៧០- រាជរដ្ឋាភិបាលបានចេញគោលការណ៍ និងវិធានការ ដើម្បីបង្ក្រាប ទប់ស្កាត់ការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់ស្ត្រី និងកុមារ តាមប្រព័ន្ធអេឡិចត្រូនិច រួមមាន÷

- បង្ខាក់ Internet IP ដែលអាចបញ្ជូនរូបភាពអាសអាភាស
- រៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យតាមដាន លើគ្រប់មធ្យោបាយទាំងអស់សម្រាប់បញ្ជូនរូបភាព

អាសអាភាស ដោយមានឱកាសម្រាប់ទ្រទ្រង់សកម្មភាពអប់រំ តាមដានត្រួតពិនិត្យ អធិការកិច្ច និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

- ក្រសួងយុត្តិធម៌ ត្រូវពិនិត្យបំពេញបន្ថែមនូវចន្លោះខ្វះខាតនៃសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការបង្ក្រាបការជួញដូរមនុស្ស ហើយត្រូវជំរុញការអនុម័តច្បាប់នេះឱ្យបានឆាប់។
- ក្រសួងកិច្ចការនារីត្រូវធ្វើសេចក្តីព្រាងសេចក្តីណែនាំ ដើម្បីជួយសម្រួលដល់ការអនុវត្តក្នុងដំណាក់កាលរង់ចាំការអនុម័តច្បាប់ ។
- ក្រសួងនីមួយៗត្រូវណែនាំ និងអប់រំមន្ត្រីរាជការកុំឱ្យមើល ឬផ្សព្វផ្សាយរូបភាពអាសអាភាស។
- រៀបចំយុទ្ធនាការអប់រំយុវវ័យ និងសង្គម ដោយសហការជាមួយគ្រប់ក្រសួងពាក់ព័ន្ធ ។

### ញ- <u>សិទ្ធិរួចផុតពីអំពើទារុណកម្ម ការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក</u> (អនុសញ្ញាមាត្រា៣៧ កថាខ័ណ្ឌក)

៧១- ទារុណកម្ម ការរំលោភបំពានលើរាងកាយត្រូវបានហាមឃាត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ច្បាប់ដែលមានស្រាប់ផ្តល់ន័យទារុណកម្ម សំដៅលើការបង្ករបួសស្នាមលើបុគ្គលណាម្នាក់ដោយអាជ្ញាធរ។ មានមាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌបានចែងអំពីអំពើទារុណកម្ម និងការដាក់ទោសអ្នកប្រព្រឹត្ត។ អ្នកទោសអាចប្តឹងអំពីទារុណកម្មដល់អាជ្ញាធរមានសមត្ថកិច្ច ហើយអ្នកប្រព្រឹត្តខុសនឹងត្រូវដាក់ទណ្ឌកម្ម។ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានហាមឃាត់ការធ្វើបាបកុមារដោយមាតាបិតា។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ហាមឃាត់អំពើហិង្សាក្នុងគ្រួសារ។ អំពើហិង្សានេះអាចជាអំពើប្រព្រឹត្តធ្វើឡើងដោយឪពុក ឬម្តាយ មកលើកុមារ។ អំពើហិង្សារួមមាន អំពើទារុណកម្មដែលបង្កការឈឺចាប់ផ្លូវចិត្ត និងរូបកាយ។ អ្នកដែលប្រព្រឹត្តអំពើហិង្សានឹងត្រូវផ្តន្ទាទោស ផ្អែកតាមច្បាប់ព្រហ្មទណ្ឌដែលនៅជាធរមាន (មាត្រា៣៥)។ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំ ស្តីពីការដាក់វិន័យកុមារ ហើយស្នើឱ្យធ្វើការព្រមានដោយផ្ទាល់មាត់ ឬដាក់ទណ្ឌកម្មកុមារដោយឱ្យសរសេរឃ្លាឱ្យបានច្រើន ឬសរសេរប្រភេទទណ្ឌកម្មនៅក្នុងសៀវភៅសិក្ខាគារិករបស់សិស្ស។ មានតែក្រុមប្រឹក្សាវិន័យប៉ុណ្ណោះ ដែលមានសិទ្ធិដាក់ទណ្ឌកម្មលើកុមារ តែមិនអនុញ្ញាតឱ្យធ្វើទណ្ឌកម្មលើរាងកាយឡើយ។

## VI. បរិយាកាសគ្រួសារ និងកិច្ចថែទាំជំនួស

### ក- <u>ការណែនាំរបស់មាតាបិតា</u> (អនុសញ្ញាមាត្រា៥)

៧២- ប្រជាពលរដ្ឋកម្ពុជាមានប្រពៃណីស្រឡាញ់ថ្នាក់ថ្នមកូន និងខិតខំធ្វើជាមាតាបិតាល្អ ហើយទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ប្រៀនប្រដៅ បង្ហាត់បង្រៀន និងរៀបចំអនាគតឱ្យកូន។ តាមប្រពៃណីទំនៀមទម្លាប់ខ្មែរ ជីដូនជីតា មាមីង ឬសាច់ញាតិដទៃផ្សេងទៀត ក៏ចូលរួមចំណែកផងដែរក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ កុមារ

ដោយក្តីមេត្តាករុណា និងព្រហ្មវិហារធម៌។ ប៉ុន្តែក៏មានគ្រួសារមួយចំនួនតូច ដែលមាតាបិតាមិនបានផ្តល់ការអប់រំណែនាំឱ្យបានគ្រប់គ្រាន់ដល់កុមារឡើយ។

## ៩- ការទទួលខុសត្រូវរបស់មាតាបិតា (អនុសញ្ញាមាត្រា១៨)

៧៣- កាតព្វកិច្ចចិញ្ចឹមកុមារឱ្យក្លាយជាពលរដ្ឋល្អ ត្រូវបានចែងក្នុងមាត្រា៤៧នៃច្បាប់រដ្ឋធម្មនុញ្ញ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានចាត់ទុកថាជាបទល្មើសនូវការប្រព្រឹត្តអំពើហិង្សាដោយជនគ្រប់រូបដោយគ្មានគិតដល់ទំនាក់ទំនងជាមួយកុមារឡើយ។ ទោះបីយ៉ាងនេះក្តី ការអនុវត្តច្បាប់នេះចេញជាផ្លែផ្កាតិចតួចនៅឡើយ ដោយសារសមត្ថភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅមានកម្រិត ហើយការផ្សព្វផ្សាយច្បាប់នៅមិនទាន់បានទូលំទូលាយ។ មានបញ្ហាប្រឈមមុខជាច្រើនទាក់ទងនឹងការទទួលខុសត្រូវរបស់មាតាបិតា ដោយសារភាពក្រីក្រ និងកង្វះការអប់រំ។

## ត. ការបំបែកពីមាតាបិតា (អនុសញ្ញាមាត្រា៩)

៧៤- ការលែងលះគ្នាបង្ខំឱ្យមានការរស់នៅដាច់ដោយឡែក ជាពិសេសពីឪពុក តែទោះបីជាយ៉ាងណាក្តី តុលាការនឹងធ្វើអន្តរាគមន៍នៅក្នុងពេលមានការខ្វែងគំនិតរវាងមាតាបិតា ហើយឧត្តមប្រយោជន៍របស់កុមារនឹងត្រូវបានលើកយកមកពិចារណា។ មាត្រា៧៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបញ្ជាក់ថា ដើម្បីប្រយោជន៍របស់កុមារសេចក្តីសម្រេចអំពីថា តើភាគីណាមួយនឹងទទួលបានការគ្រប់គ្រងថែរក្សាកុមារនឹងត្រូវកំណត់ដោយផ្អែកលើកិច្ចព្រមព្រៀងរបស់ប្រពន្ធនិងប្តី។ ផ្អែកតាមគោលការណ៍ទូទៅទារកនៅបៅដោះត្រូវស្ថិតក្រោមការគ្រប់គ្រងថែរក្សារបស់ម្តាយ។ បងប្អូនសាច់សាលោហិតត្រូវបានបន្ទុកបណ្តាក់ឱ្យជួយមើលថែរក្សាកុមារ ដែលត្រូវបានបំពារបំពាន ឬមិនត្រូវបានយកចិត្តទុកដាក់ពីមាតាបិតា។ ក្នុងករណីដែលកុមារត្រូវបានដាក់ឱ្យនៅដោយឡែកជាបណ្តោះអាសន្នពីម្តាយដែលជាប់ពន្ធនាគារ សារាចរលេខ០១៥ ស.ក.អ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពីការប្រាស្រ័យទាក់ទងជាមួយពិរុទ្ធជន និងទណ្ឌិតជានារីដែលជាប់ពន្ធនាគារហើយមានកូននៅជាមួយបានកំណត់ថា មន្ទីរ ស.អ.យ ត្រូវតែធ្វើទំនាក់ទំនងផ្ទាល់ជាមួយអាជ្ញាធរពន្ធនាគារ ដើម្បីយកកុមារអាយុលើសពី៦ខែចេញពីម្តាយជាទណ្ឌិតក្នុងពន្ធនាគារ។ បទប្បញ្ញត្តិក៏បានផ្តល់ផងដែរនូវការសួរសុខទុក្ខរបស់កុមារចំពោះម្តាយនៅក្នុងពន្ធនាគារ។

## ថ- ការជួបជុំគ្រួសារឡើងវិញ (អនុសញ្ញាមាត្រា១០)

៧៥- កម្ពុជាពុំទាន់មានច្បាប់ជនភៀសខ្លួននៅឡើយទេ។ កម្ពុជាមានច្បាប់អន្តោប្រវេសន៍ ប៉ុន្តែគ្មានបទប្បញ្ញត្តិណាមួយចែងអំពីការសម្រួលឱ្យមានការជួបជុំគ្នារវាងកុមារ និងគ្រួសារទាំងនៅកម្ពុជានិងនៅបរទេស។ ដោយមានការជួយឧបត្ថម្ភពីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ កាកបាទក្រហមកម្ពុជា បានអនុវត្តកម្មវិធីស្វែងរកគ្រួសារចាប់ពីឆ្នាំ១៩៨៨។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ កាកបាទក្រហមកម្ពុជា បានរកឃើញគ្រួសារដែលបែកបាក់គ្នាក្នុងសម័យសង្គ្រាមចំនួន១២៦៣គ្រួសារ លើ៣៤៣ករណី ដែលក្នុងនោះមានមនុស្សចំនួន១.៣៤៤នាក់ រួមទាំងកុមារផង

និងបានបញ្ជូនសារឆ្លើយឆ្លងជាមួយកាកបាទក្រហមបណ្តាប្រទេសនានាចំនួន១២០.៩១៩ច្បាប់ សម្រាប់ស្វែងរកគ្រួសារ និងមនុស្សនៅក្រៅប្រទេស ។

**ង- ការបញ្ជូនកុមារដោយខុសច្បាប់ និងការមិនវិលត្រឡប់របស់កុមារ (អនុសញ្ញាមាត្រា១១)**

៧៦- វិធានការផ្សេងៗត្រូវបានប្រកាន់យកដើម្បីប្រយុទ្ធប្រឆាំងការបញ្ជូនមនុស្សខុសច្បាប់ ។ សេចក្តីព្រាងច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងក្រមរដ្ឋប្បវេណីមានគោលបំណងទប់ស្កាត់ការបញ្ជូនកុមារខុសច្បាប់ (កថាខ័ណ្ឌ៦) ។

**ច- ការជំរុញឱ្យមានការថែទាំកុមារ (អនុសញ្ញាមាត្រា២៧ កថាខ័ណ្ឌ៤)**

៧៧- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់មាតាបិតា ហើយកាពត្វកិច្ចនេះមិនផ្លាស់ប្តូរឡើយអំពីការទំនាក់ទំនងជាមួយកុមារ និងការថែទាំកុមារ ទោះបីមានការលែងលះរបស់ឪពុកនិងម្តាយក៏ដោយ ។ នៅពេលមាតាបិតាបានលែងលះដោយស្របច្បាប់ហើយ កុមារនៅតែទទួលបានការឧបត្ថម្ភគាំទ្រពីសំណាក់ឪពុក និងម្តាយផ្អែកតាមសេចក្តីសម្រេចរបស់តុលាការ ។ ទោះបីជាយ៉ាងនេះក្តី ការលែងលះគ្នាក្នុងតំបន់ជនបទជាទូទៅ ម្តាយជាអ្នកមើលថែរក្សាកូនតែម្នាក់ឯង ហើយមានការជួយឧបត្ថម្ភពីឪពុក ។ តាមខ្លឹមសាររបស់មាត្រា៣២៣ នៃក្រមព្រហ្មទណ្ឌ តុលាការអាចផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ទៅ ២.០០០.០០០ រៀល ដល់សហព័ទ្ធណាមួយដែលមិនព្រមបង់អាហារកាតព្វកិច្ចដល់កូនជាអនីតិជនក្នុងរយៈពេលចាប់ពី២ខែឡើងទៅ ។

**ឆ. កុមារឃ្លាតចេញពីមជ្ឈដ្ឋានគ្រួសារ (អនុសញ្ញាមាត្រា២០)**

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ចាត់វិធានការមានប្រសិទ្ធភាព តាមរយៈកម្មវិធីនៅមូលដ្ឋាន និងប្រឹក្សាយោបល់ ដើម្បីជំរុញថាគ្រួសារ គឺជាមជ្ឈដ្ឋានដ៏ល្អបំផុតសម្រាប់កុមារ និងដើម្បីផ្តល់អំណាចដល់មាតាបិតាក្នុងការថែរក្សាកូន ដើម្បីបញ្ចៀសការដាក់កុមារក្នុងមជ្ឈមណ្ឌលគាំពារកុមារ
- ដាក់ចេញគោលនយោបាយ និងបទបញ្ញាណែនាំទាក់ទងនឹងមជ្ឈមណ្ឌលកុមារ និងទម្រង់ថែទាំជំនួសផ្សេងទៀត
- ពង្រឹងសេវាសង្គម ជាពិសេសសម្រាប់កុមារកំព្រា ដោយសារមេរោគអេដស៍/ជំងឺអេដស៍
- ពង្រឹងការថែទាំជំនួសផ្សេងទៀត ដូចជាគ្រួសារចិញ្ចឹម
- ផ្តល់ថវិកា និងធនធានគ្រប់គ្រាន់សម្រាប់ទិសដៅនេះ ។

៧៨- នៅឆ្នាំ២០០១ក្រសួង ស.អ.យ បានដឹកនាំការអង្កេតថ្នាក់ជាតិមួយស្តីពីអ្នកផ្តល់សេវាថែទាំចំពោះកុមារនៅកម្ពុជា ។ លទ្ធផលដែលបានពីការធ្វើអង្កេតត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែសម្រួល គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ស្តីពីការផ្តល់ការថែទាំជំនួសចំពោះកុមារកំព្រា និងកុមារដែលគេបោះបង់ចោល ។ បទប្បញ្ញត្តិស្តីពីការគ្រប់គ្រង មជ្ឈមណ្ឌលកុមារកំព្រាត្រូវបានកែសម្រួល ដើម្បីជំរុញឱ្យមានការថែទាំជំនួសក្នុងមជ្ឈដ្ឋានគ្រួសារ និង

សហគមន៍ ។ នៅឆ្នាំ២០០៥ ក្រសួង ស.អ.យ បានបង្កើតមូលដ្ឋានទិន្នន័យ ស្តីពីស្ថានភាពកុមារដែលទទួលបានការថែទាំក្នុងមណ្ឌល ។ ទិន្នន័យត្រូវបានបញ្ចូលរៀងរាល់កន្លះឆ្នាំម្តង ដោយក្រុមធ្វើការងារផ្នែកសង្គម ដែលចុះពិនិត្យដល់កន្លែងថែទាំកុមារនៅក្នុងប្រទេស ។ រាជរដ្ឋាភិបាលបានជំរុញការថែទាំកុមារនៅតាមសហគមន៍ និងក្នុងគ្រួសារ ដោយផ្តោតលើការបញ្ចូលកុមារកំព្រា និងកុមារដែលគេបោះបង់ចោលទៅក្នុងសហគមន៍ និងគ្រួសារបង្កើត ឬចិញ្ចឹម ។ ទោះបីយ៉ាងនេះក្តី ចំនួនកុមារដែលទទួលបានការថែទាំនៅតាមមណ្ឌលបច្ចុប្បន្ន នៅមានកម្រិតខ្ពស់នៅឡើយ ។

៧៩- មកដល់ចុងឆ្នាំ២០០៧ មានមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋចំនួន២០ ដែលមានកុមារស្នាក់នៅចំនួន២.២៤០នាក់ និងមានមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន១៧៦ ដែលមានកុមារស្នាក់នៅចំនួន៦.៣៨៣នាក់ ។ កុមារទាំងនេះភាគច្រើនជាកុមារក្រីក្រ កុមារកំព្រា និងកុមារអនាថា ។ បន្ថែមលើនេះ មានកុមាររងគ្រោះដោយអំពើហិង្សា ការជួញដូរ និងការកេងប្រវ័ញ្ចមួយចំនួនតូច ដែលត្រូវបានថែរក្សារយៈពេលខ្លីក្នុងមណ្ឌលស្តារសម្បទា ។

៨០- ក្នុងគោលបំណងលើកកម្ពស់ជីវភាពកុមារ ដែលរស់នៅក្នុងមណ្ឌល រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរដ្ឋ ហើយក្រសួង ស.អ.យ បានរៀបចំបទបញ្ញាមួយចំនួនពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ ដូចជា ÷

- សេចក្តីជូនដំណឹងលេខ២៩១១ ស.ក.ប.យ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០០ ស្តីពីការពង្រឹងការងារគ្រប់គ្រងកុមារកំព្រា និងវិន័យផ្ទៃក្នុងរបស់មជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ
- ប្រកាសលេខ៩១ ស.ក.ប.យ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលយកទារកកំព្រា ឬកុមារកំព្រាត្រូវគេបោះបង់ចោលឱ្យចូលរស់នៅក្នុងមជ្ឈមណ្ឌល
- សេចក្តីណែនាំលេខ០២ ស.ក.ប.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២ ស្តីពីការពង្រឹងគុណភាពការងារគ្រប់គ្រងកុមារកំព្រាក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការនានា
- ប្រកាសលេខ០៣៨ ស.អ.យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ ដែលមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរាល់បញ្ហាដែលទាក់ទងនឹងការថែទាំកុមារដោយជនដែលមិនមែនជាឪពុកម្តាយបង្កើត
- ប្រកាសលេខ០៧៤ ស.អ.យ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមការងារជំនាញសម្រាប់ជំនួយឱ្យគណៈកម្មាធិការប្រឹក្សាថែទាំជំនួសចំពោះកុមារ ដែលរួមមានក្រុមការងាររៀបចំគោលការណ៍ណែនាំក្រុមការងាររៀបចំបទដ្ឋានអប្បបរមា ក្រុមការងារត្រួតពិនិត្យនិងវាយតម្លៃ និងក្រុមការងារកំណត់រកទម្រង់នៃការថែទាំជំនួសក្រៅស្ថាប័នដែលអនុវត្តបានល្អ
- ក្រសួងសង្គមកិច្ចបានរៀបចំបទដ្ឋានអប្បបរមាចំនួន២ ស្តីពីការថែទាំជំនួសដូចជា ការថែទាំក្នុងមណ្ឌលតាមវត្តអារ៉ាម តាមគ្រួសារ និងតាមផ្ទះជាក្រុម ដែលមានទិសដៅការពារសិទ្ធិ និងធានាការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត បញ្ញាស្មារតីយូរអង្វែងរបស់កុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀត ។

បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៦។ បទដ្ឋាននេះបានដាក់បញ្ចូលនូវគុណភាពនៃការថែទាំទាក់ទងនឹងសុខុមាលភាព ការអភិវឌ្ឍ ការចូលរួម និងការគ្រប់គ្រងមណ្ឌលគាំពារកុមារ។

៨១- គោលនយោបាយជាតិស្តីពីការថែទាំជំនួសចំពោះកុមារ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រកាសឱ្យប្រើ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦។ គោលនយោបាយនេះមានចែងអំពីប្រភេទផ្សេងៗគ្នានៃការថែទាំជំនួសចំពោះកុមារ ដែលមិនបានទទួលការថែទាំដោយឪពុកម្តាយបង្កើត ហើយកំណត់គោលការណ៍នៃការថែទាំជំនួស។ គោលការណ៍បានបង្ហាញពីតម្រូវការចង់បានការថែទាំក្នុងគ្រួសារ និងតាមសហគមន៍ជាជាងការថែទាំក្នុងមណ្ឌល ជម្រើសយូរអង្វែងជាជាងជម្រើសរយៈពេលខ្លី និងទម្រង់ថែទាំក្នុងប្រទេសដូចជា សុំកូន និងការថែទាំដោយសាច់ញាតិ គ្រួសារធម៌ក្នុងប្រទេស ជាជាងទម្រង់នៃការថែទាំជំនួសដោយអន្តរជាតិ។ ក្នុងគោលនយោបាយនេះរាជរដ្ឋាភិបាលកំណត់ថា ការថែទាំតាមមណ្ឌល និងសុំកូនអន្តរប្រទេស គឺជាជម្រើសចុងក្រោយ។ គោលនយោបាយនេះមានទិសដៅដូចខាងក្រោម÷

- ធានាឱ្យកុមារបានទទួលផលប្រយោជន៍ពីលិខិតូបករណ៍ ច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលការណ៍ទាំង៤របស់អនុសញ្ញា
- ធានាឱ្យកុមារបានរីកចម្រើនលូតលាស់នៅក្នុងក្រុមគ្រួសារ និងនៅក្នុងសហគមន៍ ពិសេសក្នុងគ្រួសារបង្កើត និងសហគមន៍ ជាកន្លែងដើម ឬស្រុកកំណើត
- ធានាឱ្យកុមារមានលទ្ធភាពទទួលបានសេវាសុខភាព សេវាអប់រំ ដោយឥតគិតថ្លៃ និងការគាំទ្រផ្លូវចិត្តដើម្បីឱ្យកុមារអាចរស់រាន និងអភិវឌ្ឍន៍
- បង្កើនសមត្ថភាពសហគមន៍ក្នុងការថែទាំ និងការការពារកុមារងាយរងគ្រោះ តាមរយៈការលើកស្ទួយ និង ពង្រឹងបណ្តាញសុវត្ថិភាពទាំងអស់របស់សហគមន៍។

៨២- ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០០៤-២០០៨ របស់ក្រសួង ស.អ.យ មានទិសដៅជំរុញការថែទាំជាចាំបាច់ចំពោះកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោលនៅតាមសហគមន៍និងគ្រួសារ។ មកដល់ចុងឆ្នាំ២០០៦ ក្រសួងបានចុះអនុស្សរណៈនៃការយោគយល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន១០៤ (អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ៥០ និងអង្គការអន្តរជាតិ៥៤) ដែលសកម្មក្នុងការធ្វើកម្មវិធីជួយដល់កុមារកំព្រា និងកុមារដែលងាយរងគ្រោះ។

៨៣- ក្រសួងសង្គមកិច្ចកំពុងធ្វើការកែប្រែមណ្ឌលថែទាំកុមារឱ្យទៅជាផ្ទះជាក្រុម (Group Home) ដើម្បីបង្កើតបរិយាកាសកុមារមេត្រី។ មណ្ឌលចំនួន៨ត្រូវបានកសាងទៅជាផ្ទះជាក្រុម ដែលការរស់នៅមានលក្ខណៈជាគ្រួសារ មានកុមារចំនួនពី១០ ទៅ១៥នាក់ រស់នៅរួមគ្នាក្រោមការថែទាំរបស់បុគ្គលិកមណ្ឌល។ ដោយសារធនធានរបស់រាជរដ្ឋាភិបាលនៅមានកម្រិត ចាំបាច់ត្រូវការធនធានបន្ថែមទៀតពីសប្បុរសជន និងអ្នកផ្តល់ជំនួយជាឯកជន ដើម្បីធានាការផ្តល់សេវាឱ្យបានគ្រប់គ្រាន់ និងសមស្រប។

៨៤- រាជរដ្ឋាភិបាលបានបង្កើនរបបឧបត្ថម្ភដល់កុមារក្នុងមណ្ឌលរបស់រដ្ឋជាបន្តបន្ទាប់។ នៅចុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១១៦អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ។ ផ្អែកតាមអនុក្រឹត្យនេះ ទារកអាយុពីរឆ្នាំចុះ ទទួលបាន៦០.០០០រៀល សម្រាប់ទឹកដោះគោ និង១២០.០០០រៀល សម្រាប់សំលៀកបំពាក់ សម្ភារៈដំណេក អនាម័យ និងព្យាបាល ហើយកុមារអាយុលើសពី២ឆ្នាំទទួលបាន៤៥.០០០រៀលសម្រាប់ម្ហូបអាហារ និង១២០.០០០រៀលសម្រាប់សំលៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល។ ចំពោះទារក ឬកុមារដែលពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ ត្រូវបានទទួលប្រាក់បន្ថែមចំនួន២០.០០០រៀលសម្រាប់បំប៉នសុខភាព។ អនុក្រឹត្យក៏បានកំណត់អំពីចំនួនអ្នកថែទាំ ផ្អែកតាមចំនួននិងអាយុរបស់កុមារ ដូចជា ត្រូវមានអ្នកថែទាំ១នាក់សម្រាប់ទារក៣នាក់ ដែលមានអាយុ១ឆ្នាំចុះ អ្នកថែទាំ១នាក់សម្រាប់កុមារ៥នាក់ដែលមានអាយុលើសពី១ឆ្នាំដល់៣ឆ្នាំ អ្នកថែទាំ១នាក់សម្រាប់កុមារពី១០ទៅ១៥នាក់ដែលមានអាយុលើសពី៣ឆ្នាំ អ្នកថែទាំ១នាក់សម្រាប់ទារកកំព្រា កុមារកំព្រា ដែលពិការធ្ងន់ធ្ងរ ឬកើតជំងឺអេដស៍ចំនួន២នាក់។

៨៥- កុមាររស់នៅតាមវត្តអារ៉ាម ជាកុមារគ្រួសារក្រីក្រ កុមារអនាថា កុមារដែលឪពុកម្តាយស្លាប់ដោយសារជំងឺអេដស៍។ ដោយមានការជួយទំនុកបំរុងពីព្រះសង្ឃ កុមារទាំងនោះបានចូលរៀននៅសាលាបឋមសិក្សាក្នុងមូលដ្ឋាន ថ្នាក់អក្ខរកម្ម និងរៀនវិជ្ជាជីវៈ ប៉ុន្តែសកម្មភាពនេះមានតិចតួចនៅឡើយ។ ការជួយទំនុកបំរុងនេះ បានមកពីសប្បុរសជន និងពុទ្ធិបរិស័ទ។

៨៦- មានកុមារមួយចំនួនទៀតរស់នៅដាច់ដោយឡែកពីគ្រួសារ ហើយរស់នៅលើចិញ្ចើមថ្នល់។ ផ្អែកតាមរបាយការណ៍របស់មន្ទីរស.អ.យ រាជធានី នៅឆ្នាំ២០០៦ឃើញមានកុមារអនាថាចំនួន៤.១៨៩នាក់នៅក្នុងរាជធានីភ្នំពេញ។ ដោយឡែក ផ្អែកតាមរបាយការណ៍របស់អនុគណៈកម្មការដោះស្រាយជនអនាថាខេត្តកំពត កំពង់ចាម កណ្តាល ពោធិ៍សាត់ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ តាកែវ និងក្រុងព្រះសីហនុ នៅឆ្នាំ២០០៦ ខេត្តក្រុងទាំងនោះមានជនអនាថាសរុប២.១៩៧នាក់។

៨៧- នីតិវិធីគ្រប់គ្រងពន្ធនាគារលេខ៣៤ របស់ក្រសួងមហាផ្ទៃចែងថា ប្រធានពន្ធនាគារត្រូវចាត់វិធានការសមស្របដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ទារកដែលកើតនៅក្នុងពន្ធនាគារ និងស្ត្រីដែលមានផ្ទៃពោះ និងក្រោយពេលសំរាល។

៨៨- នៅឆ្នាំ២០០៣ អាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍បានប៉ាន់ប្រមាណថា កុមារចំនួន៦០.០០០នាក់បានរងគ្រោះដោយមេរោគអេដស៍/ជំងឺអេដស៍។ ការសិក្សានេះបានចង្អុលបង្ហាញផងដែរថា មេរោគអេដស៍/ជំងឺអេដស៍ដែលកើតមាននៅក្នុងចំណោមគ្រួសារក្រីក្រ ធ្វើឱ្យប៉ះពាល់ជាខ្លាំងដល់សុខុមាលភាពរបស់គ្រួសារទាំងនោះ។ ការសិក្សានៅឆ្នាំ២០០០ ស្តីពីបណ្តាញថែទាំកុមារតាមផ្ទះបានបង្ហាញថា ៤០%នៃកុមារក្នុងគ្រួសារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ រស់នៅដោយខ្វះខាតសម្ភារៈជាមូលដ្ឋាន ដូចជា អាហារ និងសម្លៀកបំពាក់ ហើយ៣០% ធ្វើកិច្ចការផ្ទះ

ទន្ទឹមនេះដែរ ២១% ធ្វើការដើម្បីផ្គត់ផ្គង់គ្រួសារ[១៣] ។

៨៩- ផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស.អ.យ ឆ្នាំ២០០៤-២០០៨ គ្របដណ្តប់បញ្ហាទាក់ទងនឹងប្រជាជនដែលរងគ្រោះដោយសារជំងឺអេដស៍ ដូចជា ÷

- ពង្រឹង និងពង្រីកមជ្ឈមណ្ឌល និងបណ្តាញការងារនៅតាមសហគមន៍ ដើម្បីផ្តល់សេវាសង្គមដល់បុគ្គល និងគ្រួសារ ដែលរងគ្រោះដោយសារជំងឺអេដស៍ ។
- ពង្រឹងបំណិនជីវិត និងការយល់ដឹងឱ្យកាន់តែច្រើន អំពីកម្មវិធីគាំទ្រសម្រាប់គ្រួសារដែលរងផលប៉ះពាល់ពីជំងឺអេដស៍[១៤] ។

ក្រសួង ស.អ.យ បានធ្វើផែនការយុទ្ធសាស្ត្រស្តីពីមេរោគអេដស៍/ជំងឺអេដស៍(២០០៣-២០០៥) បានរៀបចំវេទិកាស្តីពីផលប៉ះពាល់ដល់សង្គមដោយសារមេរោគអេដស៍/ជំងឺអេដស៍ និងធ្វើការលើកកម្ពស់ការយល់ដឹង ដើម្បីទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ ។

៩០- ក្រុមការងារថ្នាក់ជាតិស្តីពីកុមារកំព្រានិងកុមារងាយរងគ្រោះ ត្រូវបានបង្កើតនៅឆ្នាំ២០០៦ ហើយបានធ្វើការវិភាគទៅលើស្ថានភាពកុមារកំព្រា និងកុមារងាយរងគ្រោះទូទាំងប្រទេស រៀបចំនូវក្របខ័ណ្ឌយុទ្ធសាស្ត្រពហុផ្នែក និងផែនការសកម្មភាពថ្នាក់ជាតិសម្រាប់រយៈពេល៣ឆ្នាំ (២០០៨-២០១០) ព្រមទាំងធ្វើការប៉ាន់ប្រមាណថវិកាសម្រាប់អនុវត្តផែនការនេះ ដើម្បីការពារថែទាំ និងគាំទ្រកុមារកំព្រា និងកុមារងាយរងគ្រោះ ។

## ជ- <u>សុំកូន</u> (អនុសញ្ញាមាត្រា២១)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប***

- បន្តដំណើរការអនុម័តច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- កែទម្រង់ច្បាប់ដែលមានស្រាប់ស្តីពីសុំកូនក្នុងស្រុក
- ចូលជាភាគីអនុសញ្ញា ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ឆ្នាំ១៩៩៣
- ពង្រឹងការិយាល័យសុំកូន ។

៩១- នីតិវិធី និងបទបញ្ញត្តិស្តីពីសុំកូនអន្តរប្រទេសត្រូវបានពិនិត្យជាថ្មី និងពង្រឹងបន្ថែម ដោយបានរៀបចំលិខិតបទដ្ឋានផ្សេងៗ ស្តីពីសុំកូនអន្តរប្រទេស ដែលមានដូចខាងក្រោម ÷

---

[១៣] - ការប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម របស់ហ៊ីវ-អេដស៍លើគ្រួសារមានកុមារតូច និងកុមារជំទង់នៅកម្ពុជា (ទំព័រទី៤) ។

[១៤] - ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច ២០០៤-០៨ (ទំព័រ ៩៧) ។

- អនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រា យកទៅចញ្ចឹមជាកូនទៅបរទេស ។
- ប្រកាសលេខ០៧៤ ស.ក.ប.យ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០១ ស្តីពីបែបបទ និងការបញ្ជូនសំណុំឯកសារសុំទារកកំព្រា ឬកុមារកំព្រាយកទៅចញ្ចឹមជាកូនទៅបរទេស ។
- លិខិតលេខ១៤៨១ ស.ក.ប.យ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការហាមចុះផ្សាយព័ត៌មានតាមប្រព័ន្ធអ៊ិនធឺណិត ដែលប៉ះពាល់ដល់សិទ្ធិកុមារនៅកម្ពុជា ។
- លិខិតលេខ០១០ ស.ក.ប.យ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣ ស្តីពីសេចក្តីជូនដំណឹងចំពោះសាមីអ្នកស្នើសុំកូនចិញ្ចឹមពីប្រទេសកម្ពុជា ។

៩២- ចំនួនកុមារត្រូវបានសុំយកទៅបរទេសពីឆ្នាំ២០០០ ដល់២០០៧ ដែលរាជរដ្ឋាភិបាលបានផ្តល់ការឯកភាពមានដូចខាងក្រោម ÷

| ឆ្នាំ | សរុប | ស្រី |
|---|---|---|
| ២០០០ | ៤៥៤នាក់ | ២៧៨នាក់ |
| ២០០១ | ៤២៨នាក់ | ២៧២នាក់ |
| ២០០២ | ៤៩០នាក់ | ២២៨នាក់ |
| ២០០៣ | ២៨០នាក់ | ១៦៦នាក់ |
| ២០០៤ | ១៩៤នាក់ | ១០៧នាក់ |
| ២០០៥ | ១៧៣នាក់ | ៩១នាក់ |
| ២០០៦ | ២៩៤នាក់ | ១៤៣នាក់ |
| ២០០៧ | ២៤៩នាក់ | ១០៤នាក់ |

*ប្រភព : ការិយាល័យសុំកូន (គិតមកដល់ចុងឆ្នាំ ២០០៧)*

ដើម្បីធានាការគ្រប់គ្រងការសុំកូនអន្តរប្រទេសឱ្យមានប្រសិទ្ធភាព ក្រសួង ស.អ.យ បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានតាក់តែងស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ។ សេចក្តីព្រាងច្បាប់នេះកំពុងត្រូវបានពិភាក្សាដោយអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

នៅដើមឆ្នាំ២០០៧ កម្ពុជាបានចូលជាភាគីលើអនុសញ្ញាក្រុងឡាអេ ស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ កម្ពុជាបានចាត់តាំងរួចហើយនូវអាជ្ញាធរកណ្ដាល និងកំពុងបន្តពង្រឹងការិយាល័យសុំកូន ដើម្បីអនុវត្តអនុសញ្ញានេះ។

## ឈ. <u>ការត្រួតពិនិត្យជាទៀងទាត់លើការថែរក្សាកុមារ</u> (អនុសញ្ញាមាត្រា២៥)

៩៣- មានបទប្បញ្ញត្តិដើម្បីពង្រឹងការងារគ្រប់គ្រងមណ្ឌលកុមារកំព្រាដូចជា សេចក្ដីណែនាំលេខ០២ ស.ក.ប.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២ ស្ដីពីការពង្រឹងគុណភាពការងារគ្រប់គ្រងកុមារកំព្រា ក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការនានា ប្រកាសលេខ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំក្នុងមណ្ឌល។ គណៈកម្មការមួយត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យមើលនិងផ្ដល់ប្រឹក្សាលើបញ្ហាទាក់ទងនឹងការថែទាំជំនួស។

## ញ. <u>ការបំពារបំពាន និងការមិនយកចិត្តទុកដាក់ចំពោះកុមារ</u> (អនុសញ្ញាមាត្រា១៩ និង៣៩)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប***

- ចាត់វិធានការមានប្រសិទ្ធភាព ដើម្បីបង្ការ និងប្រឆាំងការបំពារបំពាន និងការប្រព្រឹត្តមិនគប្បីលើកុមារនៅក្នុងគ្រួសារ នៅតាមសាលារៀន ស្ថាប័នផ្សេងទៀត និងក្នុងសង្គម
- ការអនុវត្តច្បាប់គួរត្រូវបានពង្រឹង ទាក់ទងនឹងបទឧក្រិដ្ឋខាងលើ
- នីតិវិធី និងយន្តការកុមារមេត្រី ដើម្បីដោះស្រាយបណ្ដឹងស្ដីពីការបំពារបំពានលើកុមារ ដើម្បីធ្វើឱ្យកុមារទទួលបានយុត្តិធម៌ឆាប់រហ័ស និងជៀសវាងបាននូវនិទណ្ឌភាពរបស់ជនល្មើស
- កម្មវិធីអប់រំដើម្បីប្រឆាំងអាកប្បកិរិយាដែលជាទំលាប់ក្នុងសង្គមទាក់ទងនិងការបំពារបំពាន និងការប្រព្រឹត្តមិនគប្បីលើកុមារ។

៩៤- តាមប្រពៃណី ទំនៀមទម្លាប់របស់កម្ពុជា មាតាបិតា អាណាព្យាបាល លោកគ្រូ អ្នកគ្រូ អាចដាក់វិន័យ និងផ្ដល់ការណែនាំដើម្បីកែកំហុសឆ្គងរបស់កុមារ។ ក្នុងករណីដែលកុមារត្រូវបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ឬរងនូវអំពើហិង្សាអាជ្ញាធរពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធអាចធ្វើអន្តរាគមន៍ ដើម្បីយកកុមារឱ្យនៅក្រោមការថែរក្សារបស់ជីដូនជីតា ឬញាតិសន្ដាន ឬបញ្ជូនទៅមណ្ឌលសង្គ្រោះ ។

៩៥- រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្ដេជ្ញាចិត្ត ដើម្បីទប់ស្កាត់ការបំពារបំពាន និងអំពើហិង្សាលើកុមារក្នុងគ្រួសារ នៅតាមសាលារៀន ឬតាមគ្រឹះស្ថាននានា និងក្នុងសង្គមជាតិទាំងមូល តាមរយៈការអនុម័តច្បាប់ដែលពាក់ព័ន្ធ ÷

ក- ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារបានហាមឃាត់ឪពុកម្ដាយ មិនឱ្យបំពារបំពានលើរូបរាងកាយកូនរបស់ខ្លួន កូនប្រសារ កូនចិញ្ចឹម ឬ កូនរបស់សហព័ទ្ធមុនឡើយ។ អំណាចមេបាត្រូវដកពីមាតាបិតាដែល ÷

១. ខកខានមិនបានអប់រំកូន

២. បង្ខំកុមារឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋ ឬអំពើប្រឆាំងនឹងសង្គម

៣. ធ្វើបាបកុមារ

៤. ប្រព្រឹត្តអំពើផ្ទុយពីសីលធម៌ដែលជះឥទ្ធិពលមិនល្អដល់កុមារ

សេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយតុលាការ។ បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល អាចយកមកអនុវត្តដើម្បីដាក់ទណ្ឌកម្មលើឪពុកម្តាយនោះបានផងដែរ។

ខ-ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានគោលបំណងប្រយុទ្ធប្រឆាំងនឹងអាជីវកម្មផ្លូវភេទ និងអំពើអាសលើមនុស្ស រួមទាំងកុមារផង។

គ-ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងការប្រកាន់តាមវប្បធម៌អហិង្សា ហើយធ្វើឱ្យមានបរិយាកាសចុះសំរុងក្នុងគ្រួសារ និងក្នុងសង្គម។

៩៦- ក្រសួងកិច្ចការនារីបានរៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២០០៤-២០០៨ ដែលមានឈ្មោះថា " នារីរតនៈទី២ " ដោយបានរៀបចំនូវសកម្មភាពជាច្រើនសម្រាប់ធ្វើការផ្សព្វផ្សាយ តាមរយៈការបោះពុម្ព ខិតប័ណ្ណ ផ្ទាំងរូបភាព ម៉ូតូកង់បីចំនួន២០គ្រឿង ដែលមានសារអប់រំ "គ្មានអំពើហិង្សាគ្រួសារមានសុភមង្គល" និងប៉ាណូចំនួន៣ផ្ទាំងនៅទីក្រុងភ្នំពេញ និង៣ផ្ទាំងទៀតនៅខេត្តកំពង់ចាម។ ក្រៅពីការផ្សព្វផ្សាយតាមផ្ទាំងប៉ាណូ ក្រសួងកិច្ចការនារីបានបើកវេទិកាផ្សព្វផ្សាយច្បាប់នៅតាមបណ្តាខេត្តមួយចំនួន ដែលមានអ្នកចូលរួមជានាយប៉ុស្តិ៍នគរបាលទាំង៧៦សង្កាត់កងរាជអាវុធហត្ថលើផ្ទៃប្រទេសចំនួន៨៣នាក់ និងនាយទាហានគ្រប់អគ្គនាយកដ្ឋានចំនួន៨៣នាក់ (នារី៩នាក់)។ បានផលិតស្ពតតាមទូរទស្សន៍ដែលមានរយៈពេល៣នាទី ផ្សាយនៅស្ថានីយ៍ប៉ុស្តិ៍លេខ៥ មានរយៈពេល៣៩ថ្ងៃ និងទូរទស្សន៍ជាតិកម្ពុជារយៈពេល៣ខែ មានការចាក់ផ្សាយចំនួន៤ដង។

៩៧- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល បានហាមឃាត់ការដាក់វិន័យចំពោះកុមារ ដែលធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍផ្នែករាងកាយ ផ្លូវចិត្ត និងផ្នែកសង្គមរបស់កុមារ។ បទដ្ឋាននេះក៏បានកំណត់អំពីភារកិច្ចទទួលខុសត្រូវចម្បងរបស់អ្នកគ្រប់គ្រងមណ្ឌលគឺ ការពារសុវត្ថិភាពកុមារឱ្យរួចផុតអំពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្សេងៗ និងមានចែងអំពីសិទ្ធិរបស់កុមារក្នុងការធ្វើពាក្យបណ្តឹង និងទទួលកិច្ចការពារតាមផ្លូវច្បាប់ ក្នុងករណីដែលកុមារទទួលការរំលោភបំពានផ្សេងៗ។ នៅក្នុងមណ្ឌលយុវនីតិសម្បទារបស់ក្រសួង ស.អ.យ កុមារណាដែលមិនគោរពវិន័យរបស់មណ្ឌលកុមារនោះអាចនឹងត្រូវដាក់វិន័យដោយបំពេញពលកម្មបន្ថែមដូចជា ថែទាំសួន។ បើកុមារណាត្រូវបានដាក់វិន័យដោយសារការបង្កទំនាស់វាយតប់គ្នា កុមារនោះត្រូវដាក់ឱ្យនៅដាច់ដោយឡែកមួយរយៈ។

៩៨- ក្នុងករណីជនណាម្នាក់បង្ករអំពើហិង្សា ហើយបង្កររបួសស្នាមដោយចេតនាលើជនដ៏ទៃណាមួយ បុគ្គលនោះនឹងត្រូវបានផ្តន្ទាទោសតាមមាត្រា៤១នៃបទប្បញ្ញតិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ។ ជនបៀតបៀនកេរ្តិ៍ខ្មាស់នឹងត្រូវផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ដដែលនេះ។ បុគ្គលណាមួយរំលោភ ឬប៉ុនប៉ងរំលោភសេពសន្ថវៈ នឹងត្រូវផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០១ ។

មាននីតិវិធីសម្រាប់តុលាការសម្រេចលើបណ្តឹង ស្តីពីការបំពារបំពានលើកុមារ ដើម្បីធានាឱ្យកុមារទទួលបាននូវយុត្តិធម៌ និងជៀសវាងនូវការដាក់ទណ្ឌកម្មផ្សេងៗលើកុមារ។ ក្រសួង ស.អ.យ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផ្តល់សេវាកម្មផ្នែកច្បាប់ កិច្ចអន្តរាគមន៍ ការស៊ើបអង្កេត ការពិគ្រោះយោបល់ ការជួយផ្តល់មេធាវី និងជួយផ្តល់ជម្រកបណ្តោះអាសន្នដល់ជនរងគ្រោះ និងកុមារប្រឆាំងនឹងច្បាប់។

## VII. សុខភាពមូលដ្ឋាន និងសុខុមាលភាព

### ក- <u>សិទ្ធិរស់រាន និងការអភិវឌ្ឍន៍</u> (អនុសញ្ញាមាត្រា៦ កថាខ័ណ្ឌ២)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ប្រកាន់យកវិធីសាស្រ្តពហុផ្នែកដើម្បីដោះស្រាយបញ្ហាឈឺ និងស្លាប់របស់កុមារ ដោយទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់អនក្ខរកម្ម កង្វះការផ្គត់ផ្គង់ទឹកស្អាត និងចំណីអាហារមិនមានសុវត្ថិភាព ដែលនាំឱ្យកុមារមានជំងឺ
- កំណត់ផ្នែកអាទិភាពដោយផ្អែកលើទិន្នន័យជាមូលដ្ឋាន (baseline data) ដែលប្រមូលតាមការស្រាវជ្រាវដោយហ្មត់ចត់
- ប្រកាន់យកយុទ្ធសាស្រ្តដោយពិចារណាលើហេតុថា ការថែទាំសុខភាពភាគច្រើនធ្វើនៅក្រៅមូលដ្ឋានសុខាភិបាល និងការគ្រប់គ្រងរបស់រដ្ឋ
- ទទួលស្គាល់តម្រូវការរបស់សហគមន៍ដែលនៅដាច់ដោយឡែកពីគេ
- វិធានការដើម្បីបង្កើតផ្នែកថែរក្សាសុខភាពបឋមប្រកបដោយប្រសិទ្ធភាពខ្ពស់ រាប់បញ្ចូលទាំងយុទ្ធសាស្រ្ត ដើម្បីជំរុញការស្វែងរកការថែរក្សាកុមារឈឺ។

៩៩- ដើម្បីដោះស្រាយអត្រាស្លាប់របស់ទារកនិងកុមារដែលមានកម្រិតខ្ពស់ (ធៀបទៅនឹងប្រទេសដទៃក្នុងតំបន់) កិច្ចប្រជុំពិគ្រោះយោបល់កម្រិតខ្ពស់ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០០៤ ក្រោមអធិបតីភាពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមពីសមាជិកនៃភាពជាដៃគូនៃការរស់រានរបស់កុមារ (អង្គការយូនីសេហ្វ អង្គការសុខភាពពិភពលោក កម្មវិធីសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការជប៉ុន សហគមន៍អឺរ៉ុប និង

នាយកដ្ឋានសម្រាប់កិច្ចការអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក)។ អន្តរាគមន៍ទាំង១២ក្នុងប័ណ្ណពិន្ទុនិងអាំងឌីកាទ័រសំខាន់ៗ (ការផ្តើមបំបៅដោះភ្លាមក្រោយប្រសូត ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ការផ្តល់អាហារបន្ថែម ការផ្តល់ថ្នាំគ្រាប់វីតាមីនអា ការព្យាបាលបង្គ្រប់ជាតិទឹក ការព្យាបាលការរលាកសួតដោយប្រើអង់ទីប៊ីយ៉ូទិក ការចាក់ថ្នាំបង្ការជំងឺកញ្រ្ជិល និងតេតាណុស ការប្រើមុងជ្រលក់ថ្នាំ ការព្យាបាលជំងឺគ្រុនចាញ់ ការកំចាត់មូសខ្លា ដើម្បីបំបាត់ជំងឺគ្រុនឈាម និងការសម្រាលកូនដោយបុគ្គលិកសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលហើយមានជំនាញ) ទាក់ទងនឹងការរស់រានរបស់កុមារ ត្រូវបានឯកភាពក្នុងអង្គប្រជុំលំដាប់កំពូលនេះ។

១០០-នៅឆ្នាំ២០០៤ មានប្រជាពលរដ្ឋតែ៦៧.១%ដែលមានអាយុពី៧-១៥ឆ្នាំ ហើយ៦៩.៦% ដែលមានអាយុលើសពី១៥ឆ្នាំជាអ្នកចេះអក្សរ។ បន្ថែមលើនេះមានគម្លាតក្នុងអក្ខរកម្មរវាងទីប្រជុំជននិងជនបទ រវាងបុរស និងស្ត្រី ដូចមានខាងក្រោម ÷

**អត្រាអក្ខរកម្មក្នុងចំណោមកុមារអាយុចន្លោះ៧ ដល់១៥ ឆ្នាំ**

| | សរុប | ភ្នំពេញ | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|
| សរុប | ៦៧,១% | ៨៩,១% | ៧៥,០% | ៦៣,៥% |
| ប្រុស | ៧៤,៤% | ៩៣,៩% | ៨០,៥% | ៧១,៣% |
| ស្រី | ៦០,៣% | ៨៤,៧% | ៦៩,៦% | ៥៦,៣% |

**អត្រាអក្ខរកម្មក្នុងចំណោមប្រជាពលរដ្ឋអាយុចាប់ពី១៥ឆ្នាំឡើងទៅ**

| | សរុប | ភ្នំពេញ | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|
| សរុប | ៦៩,៦% | ៩០,៧% | ៧៧,២% | ៦៥,៩% |
| ប្រុស | ៨០,២% | ៩៦,១% | ៨៤,៩% | ៧៧,៥% |
| ស្រី | ៦០,១% | ៨៥,៧% | ៧០,០% | ៥៥,៦% |

អក្ខរកម្មក្នុងចំណោមស្ត្រី និងកុមារមានកម្រិតទាប ជាពិសេសក្នុងតំបន់ជនបទ គឺជាក្តីបារម្ភ ព្រោះនឹងមានផលប៉ះពាល់ជាអវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រ អត្រាស្លាប់របស់ទារក ការរស់រានរបស់កុមារ សុខភាពដ៏ប្រសើរក្នុងគ្រួសារ និងការសិក្សារបស់កុមារ។

១០១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា " ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព " បានផ្តោតការយកចិត្តទុកដាក់លើ ១)-ការផ្តល់ឱ្យពលរដ្ឋគ្រប់រូបនូវទឹកដែលមានសុវត្ថិភាព និងប្រកបដោយអនាម័យ ២)-ការផ្តល់សេរីភាពដល់ពលរដ្ឋគ្រប់រូប ដោយបញ្ចៀសការគំរាមកំហែងបាត់បង់ជីវិត និងលក្ខខណ្ឌជីវិតដែលបណ្តាលមក

ពីភាពចៃដន្យដែលទាក់ទងនឹងទឹក ៣)-ការផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបាននូវសន្តិសុខស្បៀងសម្រាប់ការរស់នៅរបស់ប្រជាជន និងសម្រាប់សកម្មភាពសេដ្ឋកិច្ច ៤)-ការធានាបរិស្ថានទឹកដែលគ្មានជាតិពុល និងការទ្រទ្រង់ជីវិតមច្ឆា និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក។

១០២-នៅឆ្នាំ១៩៩៨មានគ្រួសារចំនួន២៩% មានទឹកស្អាតប្រើប្រាស់ (ទីប្រជុំជន៦០.៣% និងជនបទ២៣.៧%[១៥]) ហើយចំនួននេះបានកើនដល់៤៤% ក្នុងឆ្នាំ២០០៤ (ទីប្រជុំជន៧២% និងជនបទ៤០%[១៦])។ នៅឆ្នាំ១៩៩៨គ្រួសារ១៤.៥% មានបង្គន់អនាម័យប្រើប្រាស់ (ទីប្រជុំជន៤៩% និងជនបទ៨.៦%[១៧]) ហើយនៅឆ្នាំ២០០៤ គ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់បានកើនឡើងដល់២២% (ទីប្រជុំជន៥៥% និងជនបទ១៦%[១៨])។ ក្រសួងអភិវឌ្ឍន៍ជនបទបានផ្តល់ការអប់រំស្តីពីសុខភាពអនាម័យ និងការប្រើប្រាស់ទឹកស្អាត និងបង្គន់ដល់សហគមន៍មូលដ្ឋាន ដើម្បីឱ្យប្រជាពលរដ្ឋកាន់តែមានការយល់ដឹងអំពីការអនុវត្តអនាម័យល្អ ។

## ១- <u>ការកាត់បន្ថយមរណភាពកុមារ</u>

១០៣-អត្រាមរណភាពរបស់ទារកនិងកុមារអាយុក្រោមប្រាំឆ្នាំ បានថយចុះគួរឱ្យកត់សម្គាល់ពីឆ្នាំ២០០០ ដល់ ២០០៥។ អត្រាមរណភាពរបស់ទារក បានថយចុះពី៩៥[១៩] នៅឆ្នាំ២០០០ មកត្រឹម៦៦[២០] នៅឆ្នាំ២០០៥ ក្នុង១០០០កំណើតរស់ ឯអត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំបានថយចុះពី១២៤[២១] មកត្រឹម៨៣[២២] ក្នុង១០០០កំណើតរស់ក្នុងរយៈពេលដូចគ្នា។

១០៤-ការថយចុះនៃអត្រាមរណភាពរបស់ទារកនិងកុមារនេះ បណ្តាលមកពីកត្តាសំខាន់ៗជាច្រើនដូចជា ការថយចុះនៃការមានកូនជាមធ្យមក្នុងស្ត្រីម្នាក់ៗ ការកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងមាតាមានភាពប្រសើរឡើង ការទទួលបានទឹកស្អាតនិងរស់នៅមានអនាម័យ ការកើនឡើងនូវការចាក់ថ្នាំបង្ការ ហើយនិងការទទួលបានសេវាថែទាំសុខភាពប្រសើរជាងមុន។

---

[១៥] ឯកសារឆ្ពោះទៅរកយុទ្ធសាស្ត្រស្តីពីប្រជាជន (ទំព័រ១៥) និងឯកសារគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (ទំព័រ៩)

[១៦] ឯកសារអង្កេតចន្លោះជំរឿន ឆ្នាំ២០០៤ (ទំព័រ ១៤)

[១៧] ឯកសារឆ្ពោះទៅរកយុទ្ធសាស្ត្រស្តីពីប្រជាជន (ទំព័រ១៦)

[១៨] ឯកសារអង្កេតចន្លោះជំរឿន ឆ្នាំ២០០៤ (ទំព័រ ១៤)

[១៩] អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០

[២០] អង្កេតប្រជាសាស្ត្រ និងសុខភាព ២០០៥

[២១] អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០

[២២] អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០៥

១០៥-នៅកម្ពុជាជំងឺបីយ៉ាងដែលធ្វើឱ្យកុមារភាគច្រើនស្លាប់គឺ ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ គ្រុនក្ដៅនិងរាគ។ ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរក្នុងរយៈពេល២សប្ដាហ៍បានចុះពី២០% មកត្រឹម៩.៥%។ ប៉ុន្តែ ជំងឺគ្រុនក្ដៅមិនមានការផ្លាស់ប្ដូរភាគរយឡើយ(៣៥%)។ ចំពោះជំងឺរាគវិញ បានកើនពី១៩% (ឆ្នាំ២០០០) ដល់២០% (ឆ្នាំ២០០៥)។ នៅឆ្នាំ២០០៥ ការអង្កេតប្រជាសាស្ត្រ និងសុខភាពបានបង្ហាញថា ជំងឺរលាកផ្លូវដង្ហើមស្រួចជាមូលហេតុមួយ ដែលធ្វើឱ្យកុមារស្លាប់មានប្រមាណជា៣០% បន្ទាប់មក មានជំងឺរាគ២៧% ជំងឺគ្រុនឈាម១១% ហើយកុមារមួយចំនួនបានស្លាប់ដោយជំងឺកញ្ជ្រិល។

## ២- <u>សុខភាពរបស់ម្ដាយ</u>

១០៦-នៅឆ្នាំ២០០៥ អត្រាមរណភាពរបស់មាតាមាន៤៧២នាក់ ក្នុងចំណោម១០០.០០០កូនកើតរស់។ ការមានកូនជាមធ្យមក្នុងស្ត្រីម្នាក់បានថយចុះពី៤.០នៅឆ្នាំ២០០០ ដល់៣.៤ នៅឆ្នាំ២០០៥។ សមាមាត្រនៃស្ត្រីរៀបការអាយុពី១៥-៤៩ឆ្នាំ ប្រើវិធីពន្យាកំណើតទំនើបបានកើនពី១៩% នៅឆ្នាំ២០០០ ដល់២៧% នៅឆ្នាំ២០០៥។ ជាង១/៦ឬ១៧%នៃការស្លាប់របស់ស្ត្រីអាយុពី១៥-៤៤ឆ្នាំ គឺបណ្ដាលមកពីការមានផ្ទៃពោះ និងការសំរាល។

១០៧-ការអង្កេតប្រជាសាស្ត្រ និងសុខភាពបានបង្ហាញថា សមាមាត្រនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ បានកើនពី៣២%នៅឆ្នាំ២០០០ ដល់៤៤% នៅឆ្នាំ២០០៥ ហើយស្ត្រីមានផ្ទៃពោះដែលបានទទួលការថែទាំមុនពេលសំរាល បានកើនឡើងដល់៦៩% ធៀបនឹងឆ្នាំ២០០០ មានតែ៣៨%។ ជាមួយនេះ តាមរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាល ការសំរាលកូននៅតាមសេវាសុខាភិបាលសាធារណៈ បានកើនពី៣២% នៅឆ្នាំ២០០៥ ដល់៤៦% នៅឆ្នាំ២០០៧ ហើយការថែទាំផ្ទៃពោះមុនពេលសំរាលកូន បានកើនដល់៨៨% នៅឆ្នាំ២០០៧។

## ៣- <u>ការថែទាំសុខភាពបឋម</u>

១០៨-ការផ្ដល់ថ្នាំបង្ការគ្រប់ប្រភេទដល់ទារកនិងកុមារបានកើនឡើង ។ ការផ្ដល់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេសម្រាប់កុមារចាប់ផ្ដើមធ្វើពីឆ្នាំ២០០២ ហើយបានពង្រីកនៅទូទាំងប្រទេសនៅឆ្នាំ២០០៥។ ក្នុងខែតុលា ឆ្នាំ២០០០ កម្ពុជាត្រូវបានប្រកាសថាជាប្រទេសគ្មានជំងឺគ្រុនស្វិតដៃជើង។ កម្មវិធីផ្ដល់ថ្នាំបង្ការត្រូវបានធ្វើផងដែរចំពោះស្ត្រីមានគភ៌និងស្ត្រីក្នុងវ័យបន្តពូជនៅគ្រប់ខេត្ត/ក្រុង ដើម្បីបង្ការជំងឺតេតាណុស។ តារាងខាងក្រោមបង្ហាញអំពីលទ្ធផលសង្ខេបនៃកម្មវិធីចាក់ថ្នាំបង្ការពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧÷

| **ថ្នាំបង្ការជំងឺ** | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **២០០៦** | **២០០៧** |
|---|---|---|---|---|---|---|---|---|
| របេង- BCG | ៨៣% | ៧៨% | ៧៥% | ៧៦% | ៩៥% | ៨៧% | ៨៧% | ៩០% |
| ស្វិតដៃជើង- Polio 3 | ៧១% | ៧០% | ៦៤% | ៦៩% | ៨៦% | ៨២% | ៨០% | ៨២% |
| ខាន់ស្លាក់/ក្អកមាន់/តេតាណូស-DTC3 | ៧១% | ៧១.៥% | ៦៤% | ៦៩% | ៨៥% | ៨២% | ៨០% | ៨២% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| កញ្រ្ជិល | ៦៩% | ៧០% | ៦២% | ៦៥% | ៨០% | ៧៩% | ៧៨% | ៧៩% |
| រលាកថ្លើមប្រភេទបេ | - | - | - | - | - | ២៨% | ៤៤% | ៥៣% |
| តេតាណូសយ៉ាងតិចពីរដង សម្រាប់ស្ត្រីមានផ្ទៃពោះ | ៤៦% | ៤៨% | ៤៣% | ៤៣% | ៥១% | ៥១% | ៥០% | ៥០% |
| តេតាណូសសំរាប់ស្ត្រីក្នុងវ័យបន្តពូជ | ១៧% | ៣០% | ១៩% | ២៦% | ២៣% | ១៩% | ១៨% | ១៥% |

*ប្រភព : ទិន្នន័យរបស់ក្រសួងសុខាភិបាល-កម្មវិធីជាតិផ្តល់ថ្នាំបង្ការ*

## ៤- កម្មវិធីអាហារូបត្ថម្ភ

### ៤.១- ការបំបៅដោះកូន

១០៩-ការអង្កេតប្រជាសាស្ត្រនិងសុខភាពបានបង្ហាញថា ការបំបៅដោះកូនដោយទឹកដោះម្តាយតែមួយមុខគត់មានការកើនឡើងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ។ នៅឆ្នាំ២០០៥ មាន៦០%នៃទារកអាយុក្រោម៦ខែ បៅទឹកដោះម្តាយតែមួយមុខគត់ បើប្រៀបធៀបនឹងឆ្នាំ២០០០ មានទារកអាយុក្រោម៦ខែតែ១១%ទេដែលបៅដោះម្តាយមួយមុខ។ ដើម្បីជំរុញការបំបៅកូនដោយទឹកដោះម្តាយឱ្យកាន់តែប្រសើរឡើង អនុក្រឹត្យលេខ១៣៣ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ។ អនុក្រឹត្យនេះមានគោលបំណងរួមចំណែកក្នុងការផ្តល់នូវអាហារូបត្ថម្ភឱ្យបានសព្វគ្រប់ និងមានសុវត្ថិភាពដល់ទារកនិងកុមារតូចៗ តាមរយៈការគាំពារនិងការលើកកម្ពស់ការបំបៅដោយទឹកដោះម្តាយ និងការជំរុញលើកទឹកចិត្តឱ្យមានការផ្តល់អាហារបន្ថែមឱ្យបានត្រឹមត្រូវនិងស្របតាមអាយុកំណត់របស់ទារក និងកុមារ ដើម្បីធានាឱ្យមានការប្រើប្រាស់សមស្របនូវផលិតផលជំនួសទឹកដោះម្តាយតែនៅពេលណាដែលចាំបាច់ និងដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់។ អនុក្រឹត្យក៏បានកំណត់អំពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ទាំងផលិតផលក្នុងស្រុកទាំងផលិតផលនាំចូលពីបរទេស ការដាក់កម្រិតលើការផ្សព្វផ្សាយ ការហាមឃាត់ និងទោសប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផលផងដែរ។ ការផ្តល់អាហារបន្ថែមដល់ទារកចាប់ពីអាយុ៦ខែឡើងទៅក៏មានភាពប្រសើរជាងមុនដែរ គឺមានការកើនឡើងពី៧៦% នៅឆ្នាំ២០០០ មក៨២% នៅឆ្នាំ២០០៥។

### ៤.២- ការលុបបំបាត់កង្វះវីតាមីនអា

១១០-ការបន្ថែមវីតាមីនអា ត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជាយ៉ាងទូលំទូលាយ តាមរយៈការចុះផ្តល់សេវាតាមភូមិដោយបុគ្គលិកមណ្ឌលសុខភាព ការចែកចាយតាមរយៈអ្នកស្ម័គ្រចិត្តភូមិ និងតាមយុទ្ធនាការពីរដងក្នុងមួយឆ្នាំ ដោយផ្តោតលើកុមារអាយុពី៦ខែដល់៥ឆ្នាំ និងម្តាយដែលបំបៅដោះកូនក្នុងរយៈពេល៨អាទិត្យក្រោយសំរាល។ កម្មវិធី

ជាតិអាហារូបត្ថម្ភរបស់ក្រសួងសុខាភិបាលបានបង្ហាញថា អត្រានៃការផ្តល់វីតាមីនអាដល់កុមារអាយុ៦ខែ ដល់៥ឆ្នាំ បានកើនពី៦៣%(ឆ្នាំ២០០០) ដល់៨៦%(ឆ្នាំ២០០៧)។ អត្រានៃការផ្តល់វីតាមីនអាដល់ម្តាយដែលបំបៅដោះកូន បានកើនពី៤៩%(ឆ្នាំ២០០៥)ដល់៥៩%(ឆ្នាំ២០០៧)។

| ការផ្តល់ថ្នាំវីតាមីនអា | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|
| ដល់កុមារ៦ខែដល់៥ឆ្នាំ | ៧២% | ៧៩% | ៨៦% |
| ម្តាយដែលបំបៅកូន | ៤៩% | ៥៣% | ៥៩% |

៤.៣- <u>បញ្ហាកង្វះអ៊ីយ៉ូដ</u>

១១១-កង្វះអ៊ីយ៉ូដបានជះឥទ្ធិពលអវិជ្ជមានដល់សុខភាពកុមារ រួមមាន ពកក អន់ថយសតិបញ្ញា និងការយឺតយ៉ាវការលូតលាស់ផ្នែករូបរាងកាយនិងស្មារតី ។ តាមការស្រាវជ្រាវក្នុងឆ្នាំ១៩៩៧ ជាមួយអង្គការយូនីសេហ្វបានបង្ហាញឱ្យឃើញថា ក្នុងចំណោមប្រជាជនទូទាំងប្រទេសមាន១៧%ជួបបញ្ហាកង្វះអ៊ីយ៉ូដ។ ដើម្បីដោះស្រាយបញ្ហានេះ នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានចេញអនុក្រិត្យឱ្យអនុវត្តជាចាំបាច់នូវការបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលដែលនាំចូលពីបរទេស និងអំបិលដែលផលិតក្នុងប្រទេស។ ជាលទ្ធផល ផលិតផលអំបិលអ៊ីយ៉ូដបានកើនពី២០% ឆ្នាំ២០០៣ ដល់ជាង១០០% នៅឆ្នាំ២០០៤។ គ្រួសារដែលប្រើអំបិលអ៊ីយ៉ូដបានកើនពី១៤% នៅឆ្នាំ២០០០ ទៅ៧៣% នៅឆ្នាំ២០០៥។

| ផលិតផលអំបិលអ៊ីយ៉ូដក្នុង១ឆ្នាំ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|
| ធៀបនឹងតម្រូវការ៧៥.០០០តោន | ១២៧.០៥៦តោន | ១៤១.៣៨៩តោន | ១៤០.៣០៩តោន |

៤.៤- <u>ភាពស្លេកស្លាំងដោយសារខ្វះជាតិដែក</u>

១១២-ការអង្កេតសុខភាពនិងប្រជាសាស្ត្រនៅឆ្នាំ២០០០ និងឆ្នាំ២០០៥ បានបង្ហាញថា ភាពស្លេកស្លាំងដោយខ្វះជាតិដែកលើកុមារអាយុពី៦-៥៩ខែបានថយចុះពី៦៣,៤% មក ៦១,៩% ក្នុងនោះភាពស្លេកស្លាំងធ្ងន់ធ្ងរបានថយចុះពី២,០% មក០,៧%។ ភាពស្លេកស្លាំងលើស្ត្រីមានផ្ទៃពោះបានថយចុះពី៦៦% មក៥៧% ហើយក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជអាយុពី១៥ ទៅ៤៩ឆ្នាំ ភាពស្លេកស្លាំងបានថយចុះពី៥៨% មក៤៧%។ ភាពស្លេកស្លាំងដែលមានពេលស្ត្រីស្ថិតក្នុងវ័យបន្តពូជនិងពិសេសពេលស្ត្រីមានផ្ទៃពោះអាចមានផលប៉ះពាល់ដល់សុខភាពរបស់កូន ហេតុនេះហើយទើបក្រសួងសុខាភិបាលយកចិត្តទុកដាក់លើការផ្តល់ថ្នាំជាតិដែកជូនដល់ស្ត្រីក្នុងវ័យបន្តពូជ ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលបំបៅកូនក្នុងកំឡុង៤២ថ្ងៃក្រោយសម្រាល។ បន្ថែមពីលើការផ្តល់គ្រាប់ថ្នាំជាតិដែកនេះ គណៈកម្មាធិការជាតិអាហារូបត្ថម្ភបាន និងកំពុងបន្តសហការជាមួយអង្គការជាដៃគូនានា ជាពិសេស អង្គការ RACHA ក្នុងការបញ្ចូលជាតិដែក

ទៅក្នុងទឹកត្រី ទឹកស៊ីអ៊ីវ និងក្នុងមីកញ្ចប់ឆ្អិនស្រាប់ឈ្មោះ "តារា" ក្នុងគោលបំណងលុបបំបាត់កង្វះជាតិដែកដែលមានក្នុងចំណោមកុមារនិងស្ត្រីនៅកម្ពុជា។

## ៥- សមាហរណកម្មការទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារ

១១៣-ដើម្បីព្យាបាលជំងឺរលាកសួតនិងជំងឺរាគរូស ក្រសួងសុខាភិបាលបាននឹងកំពុងអនុវត្តយុទ្ធសាស្ត្រមួយឈ្មោះថាសមាហរណកម្មទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារ(ស.ព.ជ.ក)។ យុទ្ធសាស្ត្រនេះរួមបញ្ចូលកម្មវិធីជាច្រើន និងមានទិសដៅលើកកម្ពស់ការបង្ការ ការព្យាបាលជំងឺ ការផ្តល់ថ្នាំបង្ការ ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភដល់កុមារ និងការអនុវត្តអនាម័យតាមរយៈការពង្រឹងទំនាក់ទំនងរវាងសេវាសុខាភិបាលនិងសហគមន៍។ យុទ្ធសាស្ត្រនេះរួមបញ្ចូលការបង្កើតឱ្យមានប្រព័ន្ធសមស្របសម្រាប់បញ្ជូនអ្នកជំងឺ ការផ្តល់សេវាអមវេជ្ជសាស្ត្រ និងការបញ្ជូនកុមារមានជំងឺទៅកាន់មណ្ឌលសុខភាពដែលមានសេវាកម្មនិងការថែទាំគ្រប់គ្រាន់ ការលើកកម្ពស់ការយល់ដឹងដល់សហគមន៍និងការផ្តល់ប្រឹក្សាដល់ឪពុកម្តាយ ឬអ្នកថែទាំកុមារនៅតាមផ្ទះ។

ការអនុវត្ត ស.ព.ជ.ក ត្រូវបានពង្រីកជារៀងរាល់ឆ្នាំ ដោយមានមណ្ឌលសុខភាពចំនួន៤៥នៅឆ្នាំ២០០២ រហូតដល់មានមណ្ឌលសុខភាពចំនួន៥៣៣ នៅចុងឆ្នាំ២០០៧ ។ ផែនការអនុវត្ត ស.ព.ជ.ក នេះនឹងត្រូវពង្រីកឱ្យបានដល់មណ្ឌលសុខភាពចំនួន៦៦៩ និងមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងចំនួន៧ទៀត នៅឆ្នាំ២០១០។

| | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|
| ចំនួនមណ្ឌលសុខភាពអនុវត្តគម្រោងសកម្មភាព | ៤៥ | ៨៦ | ១៦៤ | ៣២២ | ៤៥៦ | ៥៣៣ |

*ប្រភព: ស្ថិតិក្រសួងសុខាភិបាល (នាយកដ្ឋានកំចាត់ជំងឺឆ្លង)*

១១៤-ជំងឺគ្រុនឈាមនៅតែរាតត្បាតនៅតាមខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា ។ សកម្មភាពជាច្រើនត្រូវបានអនុវត្តជាបន្តបន្ទាប់ដោយគណៈកម្មការជាតិប្រយុទ្ធជំងឺគ្រុនឈាម សហការជាមួយមន្ទីរសុខាភិបាលខេត្ត/ក្រុង និងរដ្ឋអំណាចមូលដ្ឋាន តាមរយៈការលើកកម្ពស់ការយល់ដឹងក្នុងគ្រួសារដើម្បីលុបបំបាត់ជម្រកមូសខ្លា ព្រមទាំងចែកថ្នាំសម្រាប់កំចាត់ដង្កូវទឹក។ ជាលទ្ធផល អត្រាស្លាប់ដោយសារជំងឺគ្រុនឈាមបានថយចុះពី១,៥% (ឆ្នាំ២០០០) មក១% (ឆ្នាំ២០០៧)។

១១៥-ប្រទេសកម្ពុជាបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទប់ស្កាត់ការរាតត្បាតនៃជំងឺគ្រុនចាញ់ តាមរយៈការពង្រឹងការអប់រំសុខភាពដល់សហគមន៍ និងការចែកមុងជ្រលក់ថ្នាំនៅតាមតំបន់ដែលមានកើតជំងឺគ្រុនចាញ់មធ្យមនិងខ្ពស់។ ជាលទ្ធផលអត្រានៃការស្លាប់ដោយជំងឺគ្រុនចាញ់បានថយចុះពី១១,៤ករណី ក្នុងចំណោមប្រជាជន ១.០០០នាក់ (ឆ្នាំ២០០៣) មក៧,៣% (ឆ្នាំ២០០៥) និង៤,២ករណី (ឆ្នាំ២០០៧)។

១១៦-ជំងឺស៊ីស្តូសូមីញ៉ាស៊ីសនៅតែជាបញ្ហាមួយដល់សុខភាព ជាពិសេសចំពោះប្រជាពលរដ្ឋមួយចំនួនដែលរស់នៅតាមដងទន្លេមេគង្គ និងដៃទន្លេក្នុងខេត្តក្រចេះនិងស្ទឹងត្រែង។ ចំណែកដង្កូវក្នុងពោះវៀនក៏បង្កជាបញ្ហាសុខភាពក្នុងចំណោមប្រជាពលរដ្ឋដែលរស់នៅតាមជនបទនិងតំបន់ជាយក្រុង ពិសេសកុមារក្នុងវ័យសិក្សានិងស្ត្រីក្នុងវ័យបន្តពូជ។ ការអប់រំអំពីអនាម័យត្រូវបានធ្វើឡើងតាមរយៈ ខិតប័ណ្ណ វិទ្យុ និងការផ្តល់ថ្នាំទម្លាក់ព្រូន។ នៅឆ្នាំ២០០៤ កម្មវិធីកំចាត់ព្រូនទូទាំងប្រទេសបានដំណើរការយ៉ាងសកម្ម និងបានធ្វើឱ្យកម្ពុជាជាប្រទេសទីមួយក្នុងពិភពលោកដែលអាចការពារកុមារសិក្សានៅបឋមសិក្សាចំនួន៧៥% រួចផុតពីជំងឺដង្កូវក្នុងពោះវៀន។

## ៩- មេរោគអេដស៍/ជំងឺអេដស៍

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ចាត់វិធានការមានប្រសិទ្ធភាពសម្រាប់បង្ការមេរោគអេដស៍/ជំងឺអេដស៍ រាប់បញ្ចូលយុទ្ធនាការអប់រំ និងបង្កើនការយល់ដឹង។

១១៧-ប្រទេសកម្ពុជាសម្រេចបានជោគជ័យក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ដោយអត្រាប្រេវ៉ាឡង់ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំបានថយចុះគួរឱ្យកត់សម្គាល់ គឺពី៣%(ឆ្នាំ១៩៩៧) មក ១,៩% (ឆ្នាំ២០០៥)។ ការរាលដាលនៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះអាយុពី១៥-២៤ឆ្នាំ ដែលបានទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពមុនពេលសំរាលកូនបានថយចុះពី២,៥%(ឆ្នាំ១៩៩៨) ដល់២,១%(ឆ្នាំ២០០៥)។ ទោះជាមានការថយចុះនៃការរីករាលដាលនៃមេរោគអេដស៍នេះមែន ក៏អត្រាប្រេវ៉ាឡង់នេះនៅតែមានកម្រិតខ្ពស់ជាងគេបើធៀបទៅនឹងប្រទេសក្នុងតំបន់ ហើយការបង្ការការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ពីប្តីទៅប្រពន្ធ និងពីម្តាយទៅកូននៅតែជាអាទិភាព។ កុមារដែលអាចផ្ទុកមេរោគអេដស៍ត្រូវបានគេប៉ាន់ប្រមាណថាមានពី៧.៣០០នាក់ នៅឆ្នាំ២០០៣ និង២.៨៤០នាក់ នៅឆ្នាំ២០០៦។

១១៨-ការធ្លាក់ចុះប្រេវ៉ាឡង់មេរោគអេដស៍គឺដោយសារការអន្តរាគមន៍ខ្លាំងក្លានិងចំទិសដៅ តាមរយៈការជំរុញឱ្យប្រើស្រោមអនាម័យ១០០% មិត្តអប់រំមិត្តនៅតាមសហគមន៍ យុទ្ធនាការផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈការចុះអប់រំផ្ទាល់ក៏ដូចជាតាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងការតស៊ូមតិ។

១១៩-គោលនយោបាយជាតិស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១។ គោលនយោបាយនេះបានផ្តោតជាសំខាន់លើគោលការណ៍៤យ៉ាងគឺ ១)-ការបង្ការការចម្លងមេរោគអេដស៍ពីប្តីទៅប្រពន្ធក្នុងវ័យបន្តពូជ ២)-ការបង្ការមិនឱ្យមានផ្ទៃពោះដែលមិនចង់បានក្នុងចំណោមស្ត្រីដែលមានផ្ទុកមេរោគអេដស៍ ៣)-ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនតាមរយៈការផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ ការអនុវត្តការ

សំរាលកូន និងការចិញ្ចឹមទារកមានសុវត្ថិភាព និង៤)-ការផ្តល់សេវាថែទាំនិងគាំទ្រដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍កុមារ និងគ្រួសារមានផ្ទុកមេរោគអេដស៍នៅសហគមន៍។

១២០-នៅឆ្នាំ២០០៧មានមណ្ឌលសុខភាពចំនួន៩៥ បានផ្តល់សេវាកម្មបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលនៅឆ្នាំ២០០២មានតែ២កន្លែងប៉ុណ្ណោះ។ នៅឆ្នាំ២០០៧មានស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ចំនួន៥៣០នាក់បានមកសំរាលកូននៅមន្ទីរពេទ្យ ក្នុងនោះមានស្ត្រី៥០៥នាក់បានទទួលថ្នាំពន្យារជីវិត។ ចំនួនមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ បានកើនឡើងពី២២មណ្ឌល(ឆ្នាំ២០០២) ដល់២០០មណ្ឌល (ឆ្នាំ២០០៧)។

១២១-មានការកើនឡើងនូវចំនួនកុមារនិងមនុស្សពេញវ័យដែលទទួលបានថ្នាំពន្យារជីវិត។ នៅឆ្នាំ២០០៦មានកុមារ៥០% បានទទួលថ្នាំពន្យារជីវិត អត្រានេះបានកើនឡើងដល់៩០%នៅឆ្នាំ២០០៧។ នៅឆ្នាំ២០០៥មានមនុស្សពេញវ័យចំនួន១២.៣៩៥នាក់បានទទួលថ្នាំពន្យារជីវិត ឆ្នាំ២០០៦បានកើនដល់២០.១៣១នាក់ ហើយនៅដំណាច់ឆ្នាំ២០០៧មានចំនួន២៦.៦៦៤នាក់។ ដោយយល់ឃើញពីសារៈសំខាន់នៃការឆ្លើយតបតាមរយៈយន្តការពហុផ្នែកជាច្រើនដើម្បីទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍ក្នុងឆ្នាំ២០០១ ដើម្បីដឹកនាំសម្របសម្រួលនិងតាមដានត្រួតពិនិត្យការដោះស្រាយថ្នាក់ជាតិ តាមរយៈក្រសួង ស្ថាប័ននិងខេត្ត/ក្រុងទាំងអស់។ អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍ទទួលខុសត្រូវចំពោះការរៀបចំ និងការត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (២០០១-២០០៥ និង២០០៦-២០១០)របស់កម្ពុជា។ បញ្ហាប្រឈមចំពោះមុខគឺការរក្សានូវកម្រិតវឌ្ឍនភាព និងកំណត់យុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ពីប្តីទៅប្រពន្ធ និងពីម្តាយទៅកូន។

## ត- <u>កុមារពិការ</u> (អនុសញ្ញាមាត្រា ២៣)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- សហការជិតស្និទ្ធ និងគាំទ្រសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យនេះ ដើម្បីអភិវឌ្ឍកម្មវិធីចង្អុលបង្ហាញឱ្យទាន់ពេលដើម្បីបង្ការពិការភាព
- អនុវត្តនីតិវិធានការថែទាំជំនួស ការដាក់កុមារពិការក្នុងស្ថាប័ន
- ធ្វើគម្រោង និងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដើម្បីកាត់បន្ថយការរើសអើង
- បង្កើតកម្មវិធី និងមជ្ឈមណ្ឌលអប់រំពិសេស ហើយលើកទឹកចិត្តការដាក់បញ្ចូលកុមារពិការចូលក្នុងប្រព័ន្ធអប់រំ និងសង្គម
- បង្កើតការត្រួតពិនិត្យតាមដានគ្រប់គ្រាន់លើគ្រឹះស្ថានឯកជនសម្រាប់កុមារពិការ។

១២២-ក្រសួង ស.អ.យ បានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ (ក.ស.ជ) តាមប្រកាសលេខ៣០៨ ស.ក.ប.យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៩។ ក្រុមប្រឹក្សានេះជាស្ថាប័នពាក់កណ្តាល រដ្ឋាភិបាល និងពាក់កណ្តាលអង្គការដែលមានតួនាទីជាអ្នកពិគ្រោះយោបល់ជំនាញទៅលើបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងសុខុមាលភាពជនពិការ ដោយសហការជាមួយរាជរដ្ឋាភិបាល អ្នកតាត់តែងគោលនយោបាយ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ធ្វើការសម្របសម្រួល ដើម្បីរៀបចំយុទ្ធវិធីថ្នាក់ជាតិដ៏ទូលំទូលាយមួយសម្រាប់ការស្តារលទ្ធភាពពលកម្ម ការផ្តល់ឱកាសស្មើគ្នា និងការទប់ស្កាត់ពិការភាព។

១២៣-ក្រសួង អ.យ.ក សហការជាមួយក្រសួង ស.អ.យ និង ក.ស.ជ បានរៀបចំកសាងគោលនយោបាយស្តីពីការអប់រំកុមារពិការ ដែលគោលនយោបាយនេះកំពុងត្រូវបានស្នើសុំការអនុម័តពីក្រសួង អ.យ.ក ដើម្បីដាក់ឱ្យអនុវត្ត។ បច្ចុប្បន្នសេចក្តីព្រាងផែនការមេសម្រាប់ការអនុវត្តគោលនយោបាយនេះត្រូវបានរៀបចំរួចរាល់ជាស្ថាពរ។ ឯកសារបណ្តុះបណ្តាលស្តីពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ កំពុងត្រូវបានរៀបចំសម្រាប់បណ្តុះបណ្តាលគ្រូដែលកំពុងបំពេញមុខងារ និងគ្រូដែលកំពុងបំពាក់បំប៉នគរុកោសល្យ។ ការរៀបចំឯកសារខាងលើនេះ បានទទួលការឧបត្ថម្ភទាំងផ្នែកបច្ចេកទេស និងថវិកាពីអង្គការយូនីសេហ្វ។ បច្ចុប្បន្ន ក្រសួង អ.យ.ក បានបញ្ចូលឧបករណ៍នៃការប្រមូលស្ថិតិកុមារពិការនៅតាមសាលារៀន តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS)។

១២៤-នៅឆ្នាំ២០០០ ក្រសួង ស.អ.យ បានសហការជាមួយ ក.ស.ជ និងអង្គការដៃគូរសហប្រតិបត្តិការអភិវឌ្ឍអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្ម និងកម្មវិធីនានាដើម្បីលើកកម្ពស់សុខុមាលភាពកុមារពិការ រួមមាន ÷

- កុមារពិការដែលរស់នៅតាមមណ្ឌលរបស់រដ្ឋមានចំនួន៧២នាក់ (ប្រុស៣២នាក់ ស្រី៤០នាក់)
- កុមារពិការដែលទទួលសេវាកម្មពីអង្គការនានាចំនួន២.០០៧ នាក់ (ប្រុស១.១៤៨នាក់ ស្រី៨៥៩នាក់)។
- កុមារពិការរស់នៅតាមសហគមន៍ក្នុង២០ខេត្ត-ក្រុង មានចំនួន៨.៧៩៣នាក់ (ប្រុស៧.២១៧នាក់)[២៣]។

១២៥-នៅឆ្នាំ២០០៧ ស្ថិតិកុមារពិការមាន

- កុមារពិការនៅក្នុងមណ្ឌលរដ្ឋចំនួន១០៣នាក់ (ប្រុស៦៨នាក់ ស្រី៣៥នាក់)
- កុមារពិការនៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល (៩អង្គការ) ចំនួន៨៥៧នាក់ (ប្រុស៥២៦នាក់ ស្រី៣៣១នាក់)
- កុមារពិការរស់នៅតាមសហគមន៍ក្នុង១១ខេត្ត ក្រុង (៨៦ស្រុក) សរុបចំនួន១៣.៥៩៨នាក់។

១២៦-នៅឆ្នាំ២០០៦ ក្រសួង ស.អ.យ និង ក.ស.ជ ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការយូនីសេហ្វ បានអនុវត្តគម្រោងសម្របសម្រួលថ្នាក់ជាតិ លើការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍ និងផ្សព្វផ្សាយការយល់ដឹងពី

[២៣]- របាយការណ៍របស់ក្រសួង សង្គមកិច្ចឆ្នាំ២០០០ (ទំព័រ១០ ចំណុចយ)។

ពិការភាព ដើម្បីពង្រឹងសមត្ថភាពមន្ត្រីក្រសួងនិងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ឱ្យកាន់តែមានប្រសិទ្ធិភាពឡើង និងពង្រឹងទំនាក់ទំនងរវាងក្រសួង និងអង្គការដៃគូរសហប្រតិបត្តិការអភិវឌ្ឍ តាមរយៈការសម្របសម្រួល ការពិនិត្យតាមដាន និងការវាយតម្លៃកម្មវិធី និងជំរុញការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីពិការភាព ព្រមទាំងជំរុញការចូលរួមក្នុងសហគមន៍ដើម្បីផ្តល់សិទ្ធិអំណាចដល់ជនពិការ និងផ្តល់ឱកាសដល់ជនពិការចូលរួមក្នុងសកម្មភាពសង្គម។

១២៧-ក្នុងមួយឆ្នាំៗមានកុមារពិការចំនួន៧២១នាក់ ក្នុងចំណោមកុមារពិការ១.៨៣៣នាក់ បានទទួលសេវាកម្មស្តារសម្បទា ហើយត្រូវបានតាមដានពិនិត្យ និងផ្តល់ប្រឹក្សាដោយអង្គការមិនមែនរដ្ឋាភិបាល។ សម្ភារៈសិប្បនិម្មិតចំនួន២.៦៦១គ្រឿងត្រូវបានផ្តល់។ កុមារពិការចំនួន៧៤៩នាក់ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសាលាមធ្យមសិក្សា។ មានវេជ្ជបណ្ឌិតចំនួន២២នាក់ និងគិលានុប្បដ្ឋាក២២នាក់ ដែលបម្រើការងារនៅតាមមន្ទីរពេទ្យបង្អែកនានានៃស្រុកមួយចំនួនបានទទួលការបណ្តុះបណ្តាលអំពីជំនាញវះកាត់ជាមូលដ្ឋាន ដើម្បីលើកកម្ពស់ការថែទាំជាបន្ទាន់ដល់ជនរងគ្រោះដោយសារមីន។

## ឃ- <u>សិទ្ធិក្នុងការទទួលការថែទាំសុខភាព</u> (អនុសញ្ញាមាត្រា២៤)

| |
|---|
| ***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប*** |
| ធ្វើការកែលំអរ និងពង្រីកការទទួលសេវាថែរក្សាសុខភាព និងឱសថដើម្បីធានាឱ្យកុមារនៃគ្រួសារក្រីក្រ និងកុមារនៃក្រុមដែលពុំសូវបានគេអើពើទទួលបានសេវាទាំងនេះ។ |

១២៨-ចំណុចទី៦១នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល បានថែងពីអាទិភាពលើការបង្កើតមណ្ឌលសុខភាពនៅទូទាំងប្រទេស ជាទីកន្លែងដែលសេវាសុខាភិបាលមូលដ្ឋានប្រកបដោយប្រសិទ្ធភាព សមធម៌ និងចិរភាព ត្រូវបានផ្តល់ជូនដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ។ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើវិធានការបង្ការ និងព្យាបាលនូវជំងឺឆ្លងនានា ការគាំពារមាតានិងទារក ដើម្បីកាត់បន្ថយអត្រាមរណៈ ព្រមទាំងលើកកម្ពស់ការអប់រំសុខភាព និងផ្សព្វផ្សាយព័ត៌មាន ជាពិសេសក្នុងតំបន់ជនបទ។ ប្រជាពលរដ្ឋក្រីក្រត្រូវបានទទួលសេវាដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព។ ការទទួលរបស់ជនក្រីក្រនូវសេវាកម្មសុខភាពមានគុណភាព ត្រូវបានផ្តល់តាមរយៈការពង្រីកមូលនិធិសមធម៌។ រាជរដ្ឋាភិបាលប្តូរផ្តាច់ជំរុញការរៀបចំ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យសុខាភិបាលឱ្យមានប្រសិទ្ធភាព ដើម្បីធានាការផ្តល់សេវាសុខភាពមានគុណភាពនិងសុវត្ថិភាពចំណីអាហារ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវគោលនយោបាយលើកទឹកចិត្តការប្រើប្រាស់ឱសថបុរាណគួបផ្សំនឹងឱសថសម័យដោយមានការផ្តល់ព័ត៌មាន និងត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់ និងសមស្រប។

១២៩-ដើម្បីរក្សាសុខភាពជូនប្រជាជន ជាពិសេសប្រជាជនក្រីក្ររួមទាំងកុមារផង រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកប្រព័ន្ធសុខាភិបាល ដោយធ្វើការសាងសង់បន្ថែមនូវប៉ុស្តិ៍សុខភាព មណ្ឌលសុខភាពជាច្រើន និងជួសជុលអគារចាស់ៗមួយចំនួន ក្នុងទិសដៅបង្កើនការផ្តល់សេវាសុខភាពឱ្យបានគ្រប់ទៅតាមផែនការគ្របដណ្តប់សុខាភិបាល និងផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៣-២០០៧ ដែលមានដូចជា ÷

- ការសាងសង់ ជួសជុល និងពង្រីកប៉ុស្តិ៍សុខភាព មណ្ឌលសុខភាពដែលជាមូលដ្ឋានជួរមុខនៃប្រព័ន្ធសុខាភិបាលសាធារណៈ បានកើនឡើងដូចមានក្នុងតារាងខាងក្រោម :

| មូលដ្ឋានសុខាភិបាល | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|---|---|
| ប៉ុស្តិ៍សុខភាព | ៤ | ៤ | ១០ | ១១ | ៤០ | ៤៤ | ៧៩ | ៩៥ |
| មណ្ឌលសុខភាព | ៧០២ | ៧៦៥ | ៨១២ | ៨២៣ | ៨៣២ | ៨៧២ | ៨៨១ | ៨៨១ |
| មន្ទីរពេទ្យបង្អែកកម្រិតទី១ | - | - | - | ២៨ | ២៨ | ២៥ | ២៥ | ២៨ |
| មន្ទីរពេទ្យបង្អែកកម្រិតទី២ | ២៤ | ៣១ | ៣៥ | ២៤ | ២៦ | ២៨ | ២៧ | ៣០ |
| មន្ទីរពេទ្យបង្អែកកម្រិតទី៣ | - | - | - | ១៣ | ១៥ | ១៦ | ១៧ | ១៨ |
| មន្ទីរពេទ្យបង្អែកជាតិ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |

មណ្ឌលសុខភាពផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ រួមទាំងកុមារនៅតាមតំបន់ដាច់ស្រយាលមាន ប៉ុស្តិ៍សុខភាពផ្តល់សេវាសុខភាណបឋម និងជួយបញ្ជូនអ្នកជំងឺមកកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។ ប៉ុស្តិ៍សុខភាពទាំងនោះនឹងក្លាយទៅជាមណ្ឌលសុខភាព នាពេលអនាគតតាមសំណុំសកម្មភាពអប្បបរមា ដែលមានសម្ភារៈបរិក្ខារពេទ្យ-ឱសថ និងបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលសំណុំអប្បបរមា ដើម្បីផ្តល់សេវាជូនប្រជាជនស្ត្រីនិងកុមារ ដែលមានជាអាទិ៍ សេវាពិគ្រោះពិនិត្យ និងព្យាបាលជំងឺទូទៅ សេវាសុខភាពមាតា និងទារកទើបនឹងកើត កុមារ សុខភាពបន្តពូជ ការថែទាំផ្ទៃពោះមុនសម្រាល ការសម្រាលកូនមានអនាម័យ និងសុវត្ថិភាព ការថែទាំស្ត្រីនិងទារកក្រោយពេលសម្រាល ការផ្តល់ថ្នាំបង្ការជំងឺ៧មុខ ដល់ទារកនិងកុមារ ការចាក់ថ្នាំបង្ការជំងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្នុងវ័យបន្តពូជ អាហារូបត្ថម្ភ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការថែទាំទារក និងកុមារតូច សមាហរណកម្មនៃការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ ការពន្យាកំណើត សុខភាពបន្តពូជយុវវ័យ ការរំលូតកូន និងការថែទាំក្រោយរំលូត) សេវាជំងឺឆ្លង (ជំងឺកាមរោគ និងរោគស្ត្រី ជំងឺអេដស៍ របេង ហង់សិន គ្រុនចាញ់ គ្រុនឈាម ផ្តាសាយបក្សី) សេវាជំងឺមិនឆ្លង (សម្ពាធឈាមខ្ពស់ ទឹកនោមផ្អែម មហារីកដោះ-ស្បូន សុខភាពផ្លូវចិត្ត សុខភាពមាត់ធ្មេញ ការថែទាំភ្នែក ការវះកាត់តូច និងរុំរបួស) សេវាអប់រំសុខភាព និងការផ្តល់សេវាចុះតាមមូលដ្ឋាន។

នៅទូទាំងប្រទេសមានមន្ទីរពេទ្យបង្អែកចំនួន៧៦ ដោយមិនរាប់មន្ទីរពេទ្យជាតិចំនួន៨កន្លែងនៅភ្នំពេញទេ។ មន្ទីរពេទ្យបង្អែកទាំងនេះត្រូវផ្តល់ជូនប្រជាជននូវសេវាពិនិត្យព្យាបាល និងថែទាំជំងឺ សេវាវះកាត់ សម្ភព រោគស្ត្រី កាមរោគ អេដស៍ ជំងឺមាត់ធ្មេញ ជំងឺផ្លូវ និងជំងឺទូទៅដទៃទៀត មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ជាពិសេសសេវាទាំងឡាយណាដែលមណ្ឌលសុខភាពមិនអាចផ្តល់ជូនបាន។ បច្ចុប្បន្ន ចំនួនមន្ទីរពេទ្យបង្អែក ដែលមានសេវាវះកាត់ធំ (កម្រិតទី២ និងទី៣) បានកើនចំនួនពី២៤ នៅឆ្នាំ២០០០ ដល់៤៨ នៅឆ្នាំ២០០៨។

ក្រៅពីប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកដូចបានរៀបរាប់ខាងលើ មានមន្ទីរពេទ្យបង្អែកជាតិ ដូចជា មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យកុមារអង្គរ មន្ទីរពេទ្យជ័យវរ្ម័នទី៧ ដែលជាមន្ទីរពេទ្យជំនាញទទួលពិនិត្យព្យាបាលជំងឺជូនស្ត្រីមានផ្ទៃពោះនិងកុមារ។ ក្រៅពីនេះ មានមជ្ឈមណ្ឌលព្យាបាល ជំងឺបេះដូងដែលមានបំពាក់សម្ភារៈបរិក្ខាគ្រប់គ្រាន់ សម្រាប់ដំណើរការផ្តល់សេវានៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង ដែលបានដំណើរការតាំងពីខែវិច្ឆិកា ឆ្នាំ២០០១។ មជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង មានបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់ ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន បាន បើកឱ្យប្រើប្រាស់ជាផ្លូវការ ចាប់ពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០២មក។

១៣០-ក្រៅពីសេវាសុខភាពសាធារណៈ មានសេវាសុខភាពឯកជនដែលជាសេវាដៃគូយ៉ាងសកម្ម ហើយបានរីកដុះដាលយ៉ាងខ្លាំង។ ក្នុងឆ្នាំ២០០៥នៅទូទាំងប្រទេស មានបន្ទប់ពិគ្រោះព្យាបាលជំងឺឯកជនចំនួន២៣៤កន្លែង និងបន្ទប់ពិគ្រោះព្យាបាលមាត់ធ្មេញចំនួន៣៣កន្លែង ដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល។ មានគ្លីនិករបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន៨កន្លែង និងគ្លីនិកពាក់កណ្តាលអង្គការចំនួន៣កន្លែង។ នៅឆ្នាំ២០០៧ មានបន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅចំនួន១.០០០កន្លែង បន្ទប់ព្យាបាលមាត់ធ្មេញចំនួន១១៥កន្លែង មន្ទីរពហុព្យាបាលចំនួន២៧កន្លែង មន្ទីរសម្ភពចំនួន៦កន្លែង បានទទួលការអនុញ្ញាតិបើកសេវាឯកជន។

១៣១-ដើម្បីធានាការទទួលបានស្មើគ្នានូវសេវាកម្មសុខាភិបាលសាធារណៈ មូលនិធិសមធមិត្រូវបានបង្កើតឡើង ដើម្បីបង់ថ្លៃព្យាបាលជំនួសគ្រួសារក្រីក្រ។ មូលនិធិសមធមិនឹងត្រូវបានដាក់ឱ្យដំណើរការនៅគ្រប់មណ្ឌលសុខភាពទាំងអស់ ដែលបានអនុវត្តប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល។ ការអនុវត្តមូលនិធិសមធមិនេះបង្ហាញពីកិច្ចខិតខំដើម្បីធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្រីក្រ ជាពិសេសកុមារទទួលបានសេវាសុខាភិបាលសាធារណៈប្រកបដោយគុណភាព។ នៅឆ្នាំ២០០៣ មានស្រុកប្រតិបត្តិចំនួន៧០ បានអនុវត្តមូលនិធិសមធមិ បច្ចុប្បន្ននេះ មានស្រុកប្រតិបត្តិចំនួន៣៦ កំពុងអនុវត្តគម្រោងមូលនិធិ ក្នុងនោះស្រុកប្រតិបត្តិចំនួន២៧ អនុវត្តដោយប្រើប្រាស់ថវិកាជំនួយរបស់ដៃគូអភិវឌ្ឍ និងស្រុកប្រតិបត្តិចំនួន៩ អនុវត្តដោយប្រើប្រាស់ថវិកាជាតិ។ ចំនួនអ្នកក្រីក្រ ដែលទទួលបានជំនួយពីមូលនិធិសមធមិ បានកើនឡើងពី៥.២៣៤នាក់ នៅឆ្នាំ២០០២ ដល់១៩.៩៣៧នាក់ នៅឆ្នាំ២០០៣ និងពី៨៩.៣២០នាក់ នៅឆ្នាំ២០០៦ ដល់១៥២.២១៣នាក់ នៅឆ្នាំ២០០៧ (ក្រសួងសុខាភិបាល)។ អត្រាប្រើប្រាស់គ្រែ ជាពិសេសក្នុង

ចំណោមកុមារបានកើនជាខ្លាំងនៅមន្ទីរពេទ្យ ដែលកំពុងអនុវត្តមូលនិធិសមធម៌នេះ។ ជាមួយគ្នានេះដែរ ការអនុវត្តការធានារ៉ាប់រងសុខភាពសហគមន៍ បានកើនពី១គម្រោង នៅឆ្នាំ២០០៣ ដល់៩ គម្រោង នៅឆ្នាំ២០០៧។

## ង- សុខភាពកុមារវ័យជំទង់

> ***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***
>
> - ធ្វើការសិក្សាចំរុះផ្នែក និងស៊ីជំរៅដើម្បីកំណត់វិសាលភាពបញ្ហាសុខភាពរបស់កុមារវ័យជំទង់ រួមមានសុខភាពផ្លូវចិត្តជាមូលដ្ឋានសម្រាប់ធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយសុខភាពកុមារវ័យជំទង់ ហើយពង្រឹងការអប់រំសុខភាពបន្តពូជ។
> - អភិវឌ្ឍសេវាកម្មផ្តល់ប្រឹក្សាកុមារមេត្រី រួមជាមួយការថែទាំ និងសម្ភារៈស្តារសម្បទាសម្រាប់កុមារវ័យជំទង់។

១៣២-ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាក់ព័ន្ធដទៃទៀត បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍ ដើម្បីដាក់បញ្ចូលបញ្ហាសុខភាពទូទៅនិងសុខភាពបន្តពូជ ជំងឺអេដស៍ ទៅក្នុងកម្មវិធីសិក្សា។ នៅឆ្នាំ២០០៥ ក្រសួងសុខាភិបាលបានសហការជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍសុខាភិបាល ដើម្បីដាក់បញ្ចូលការផ្តល់សេវាសុខភាពបន្តពូជវ័យជំទង់ទៅក្នុងប្រព័ន្ធសេវាសុខភាពសាធារណៈ ហើយពិធីសារ និងឯកសារសម្រាប់បណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ត្រូវបានរៀបចំបង្កើតឡើង។ ចាប់ពីឆ្នាំ២០០៥មក មានមណ្ឌលសុខភាពចំនួន១២ កំពុងផ្តល់សេវាសុខភាពបន្តពូជ ជូនកុមារវ័យជំទង់។

១៣៣-កម្មវិធីសុខភាពផ្លូវចិត្តត្រូវបានពង្រឹង និងពង្រីក ដើម្បីបញ្ចូលសេវាពិនិត្យនិងព្យាបាលជំងឺផ្លូវចិត្តកុមារ ដែលកំពុងត្រូវបានផ្តល់នៅមន្ទីរពេទ្យមួយ និងមណ្ឌលសុខភាពចំនួន១៣កន្លែង។ កម្មវិធីជាតិសុខភាពផ្លូវចិត្តបានផ្តល់ការបណ្តុះបណ្តាលជាហូរហែរដល់វេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា និងគិលានុបដ្ឋាយិកា។

១៣៤-ពាក់ព័ន្ធនឹងធនធានមនុស្ស ចំនួននិស្សិតដែលបានបញ្ចប់ការណ្តុះបណ្តាលជំនាញវេជ្ជសាស្ត្របានកើនឡើងពី១០៩នាក់ (ឆ្នាំ១៩៩៨) ដល់៥៥៩នាក់(ឆ្នាំ២០០៣) ហើយសិក្ខាកាមប្រហែល១២.០០០នាក់ បានទទួលការបណ្តុះបណ្តាលនៅនឹងកន្លែងការងារស្តីពីសំណុំសកម្មភាពអប្បបរមា[២៤]។

១៣៥-ផលិតផលសរុបក្នុងស្រុក ត្រូវបានផ្តល់ដល់ផ្នែកសុខាភិបាលស្មើនឹង១,២៦% ក្នុងឆ្នាំ២០០៥។ ការផ្តល់នេះ បានកើនឡើងជាហូរហែរចាប់ពីឆ្នាំ២០០២។ ថវិកាជាតិផ្តល់ជូនក្រសួងសុខាភិបាល បានកើនពី៦,៦%(ឆ្នាំ២០០០) ដល់ ១០,៥% (ឆ្នាំ២០០៦)។

---

[២៤] សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)

| ឆ្នាំ | ២000 | ២00១ | ២00២ | ២00៣ | ២00៤ | ២00៥ |
|---|---|---|---|---|---|---|
| ថវិកាចំណាយសរុប-លានដុល្លា | ៤0១ | ៤៣៧ ,៦ | ៤៨៦.៦ | ៥៥១.៧៥ | ៥១៣.៣ | ៥៣៣.១ |
| (ពាន់លានរៀល) | ១៥៤៥.១ | ១៧0៧.២ | ១៩២២.៤ | ២២0៧.៣ | ២0៧៨.៦ | ២១៣២.៦ |
| ថវិកាដែលផ្តល់ឱ្យសុខាភិបាល(លានដុល្លា) | ២៦.៤ | ៣៣.៣ | ៤១.៥ | ៤៣.២ | ៤៧.៤ | ៥៦.១ |
| (ពាន់លានរៀល) | ១0១.៨ | ១២៩.៧ | ១៦៤.៤ | ១៧៣.0 | ១៩២.១ | ២២៤.៥ |
| គិតជាភាគរយ | ៦.៦ | ៧.៦ | ៨.៦ | ៧.៨ | ៩.២ | ១0.៥ |

*ប្រភព : សៀវភៅស្ថិតិប្រចាំឆ្នាំ ២00៦ NIS, MoP-December 2006*

១៣៦-ការលំបាកមួយចំនួននៅក្នុងវិស័យសុខាភិបាលរួមមាន ៖

- មិនទាន់មានគ្រប់ចំនួននូវមណ្ឌលសុខភាព ដែលផ្តល់សំណុំសកម្មភាពអប្បបរមាពេញលេញ និងមន្ទីរពេទ្យបង្អែកដែលផ្តល់សំណុំសកម្មភាពបង្គ្រប់កម្រិត៣ ដើម្បីគាំទ្រផែនការគ្របដណ្តប់សុខាភិបាល
- មណ្ឌលសុខភាពមួយចំនួនមិនមានបុគ្គលិកគ្រប់គ្រាន់ ជាពិសេសឆ្មបនិងអ្នកផ្តល់សេវាសុខភាពជូនកុមារ ហើយជួនកាលមិនមានបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ សម្រាប់គាំពារសុខភាពមាតា និងកុមារ
- មានការខ្វះខាតឱសថ បរិក្ខាពេទ្យទំនើបៗ បន្ទប់សម្រាប់ផ្តល់សេវា ជាពិសេសបន្ទប់ដាច់ ដោយឡែកសម្រាប់ផ្តល់សេវាដល់កុមារវ័យជំទង់
- ការយល់ដឹងរបស់ប្រជាជន ពិសេសមាតាបិតានៅមានកម្រិតក្នុងការថែទាំជំងឺ និងបញ្ជូនកូនមកព្យាបាលនៅមណ្ឌលសុខភាព ដោយសារមូលហេតុខ្វះព័ត៌មានត្រឹមត្រូវអំពីសេវាដែលផ្តល់ដោយមណ្ឌលសុខភាព កង្វះព័ត៌ មានអំពីទីកន្លែងដែលត្រូវទទួលសេវាពីពេលវេលានៃការផ្តល់សេវាទាំងនោះ អំពីការលើកលែងបង់ថ្លៃសេវាសម្រាប់អ្នកក្រីក្ររួមទាំងកុមារផង។ ខ្វះការលើកទឹកចិត្តឱ្យបានសមស្របពីសហគមន៍ ភូមិ ឃុំ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីសុខភាពសញ្ញាគ្រោះថ្នាក់ និងការទទួលសេវាសុខាភិបាលនៅថ្នាក់មូលដ្ឋាន
- បញ្ហាកង្វះអាហារូបត្ថម្ភនៅតែកើតមាននៅតាមតំបន់ជនបទដាច់ស្រយាល ពិសេសក្នុង ចំណោមកុមារ
- ការចូលរួមប្រើប្រាស់សេវាសុខាភាព ជាពិសេសក្នុងចំណោមអ្នកក្រីក្រនៅមានកម្រិត។

១៣៧-បណ្តាវិធានការ ដើម្បីដោះស្រាយការលំបាកខាងលើមានដូចជា ៖

- សាងសង់បន្ថែម និងពង្រីកមណ្ឌលសុខភាពទៅតាមផែនការគ្របដណ្តប់សុខាភិបាល
- ធានាការផ្គត់ផ្គង់ឱសថ និងបរិក្ខាឱ្យបានគ្រប់គ្រាន់តាមតម្រូវការ និងទៀងទាត់
- ធ្វើការបណ្តុះបណ្តាលឆ្មប បុគ្គលិកសុខាភិបាលដែលកំពុងបំពេញការងារសំខាន់ៗ ដូចជាជួយគាំទ្រស្ត្រី និងកុមារ

- បន្តអនុវត្តគ្រប់កម្មវិធីសុខភាពទាំងអស់ ជាពិសេសកម្មវិធីអប់រំសុខភាព និងការបង្កើនចំណេះដឹង ការកែប្រែឥរិយាបថរបស់ប្រជាជន ដូចដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល
- ធ្វើការលើកទឹកចិត្តចំពោះបុគ្គលិក ដែលធ្វើការនៅតំបន់ជនបទដាច់ស្រយាល ដោយបង្កើនប្រាក់ឧបត្ថម្ភក្នុងពេលយាមកាម ប្រាក់ឧបត្ថម្ភលើការធ្វើដំណើរនិងស្នាក់នៅទៅតាមភាពជាក់ស្តែង
- ធ្វើការលើកទឹកចិត្តដល់ឆ្មបដែលជាបុគ្គលិកសុខាភិបាលមានជំនាញ ក្នុងការសម្រាលកូននៅតាមមណ្ឌលសុខភាព
- ពង្រីកប្រព័ន្ធហិរញ្ញប្បទានសុខាភិបាលដល់គ្រប់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក អនុវត្តមូលនិធិសមធម៌ ហើយឈានទៅធានារ៉ាប់រងសុខភាពសម្រាប់ប្រជាជនគ្រប់រូបរាប់ទាំងកុមារផង នាពេលអនាគត
- អនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់ការរស់រានរបស់កុមារ ដើម្បីកាត់បន្ថយការស្លាប់របស់កុមារ និងសម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- អនុវត្តគោលនយោបាយជាតិស្តីពីអាហារូបត្ថម្ភ និងគោលនយោបាយជាតិស្តីពីការផ្តល់អាហារដល់ទារក និងកុមារតូចៗ ដើម្បីលើកកម្ពស់ស្ថានភាព អាហារូបត្ថម្ភរបស់ម្តាយនិងកុមារ
- អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ រួមទាំងសុខភាពបន្តពូជកុមារវ័យជំទង់ពីឆ្នាំ២០០៦ ដល់២០១០
- បំផុសការគាំទ្រពីសហគមន៍ក្នុងការចូលរួមលើកកម្ពស់សុខភាពនៅតាមមូលដ្ឋាន ដើម្បីឱ្យរៀនអំពីសញ្ញាអាសន្ន និងការបញ្ជូនអ្នកជំងឺទាន់ពេលវេលាទៅមណ្ឌលសុខភាព
- បន្តធ្វើយុទ្ធនាការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីបញ្ហាសុខភាព ការថែទាំ ការការពារ ការព្យាបាលជំងឺ កិច្ចបង្ការការរាតត្បាតនៃជំងឺឆ្លង រួមទាំងមេរោគអេដស៍ផងដែរ
- បន្តផ្តល់សេវាកម្មនៅតាមមូលដ្ឋានភូមិ ឃុំជាពិសេសភូមិ ឃុំដាច់ស្រយោល
- ពង្រឹងការទទួលខុសត្រូវនូវតួនាទីរបស់វេជ្ជបណ្ឌិត ឆ្មប និងគិលានុប្បដ្ឋាក/យិកា ចំពោះប្រជាជននៅមូលដ្ឋាន
- បន្ថែមភាពកក់ក្តៅទៅលើកុមារពិការ និងកុមារកើតអេដស៍
- បង្កើនថវិកាជាតិសម្រាប់ចំណាយលើផ្នែកសុខភាពមាតា និងកុមារ
- បង្កើនកិច្ចសហការជាមួយដៃគូអ្នកផ្តល់ជំនួយ ដៃគូសហប្រតិបត្តិការអភិវឌ្ឍសុខាភិបាលទាំងអស់ ដើម្បីលើកកម្ពស់ការ ផ្តល់សេវាសុខភាពមាតា និងកុមារ ជាពិសេសផ្តល់ការគាំទ្រថវិកា និងបច្ចេកទេស ។

១៣៨-នៅក្នុងឆ្នាំថ្មីៗនេះអាំងឌីកាទ័រស្ទើរតែទាំងអស់ដែលទាក់ទងនឹងសុខភាព បានបង្ហាញពីនិន្នាការវិជ្ជមាន អាស្រ័យដោយអ្នកក្រីក្រអាចមានលទ្ធភាពងាយស្រួលជាងមុនក្នុងការទទួលបានសេវាកម្មសុខាភិបាលសាធារណៈ ដើម្បីផ្សារ

ភ្ជាប់នូវគម្លាតរវាងទីប្រជុំជននិងជនបទ ក៏ដូចជារវាងក្រុមមនុស្ស ដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចខុសៗគ្នា ហើយផ្លូវថ្នល់នៅជនបទដែលប្រសើរជាងមុន និងប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការខ្ពស់ជាងមុន នឹងអាចជួយដោះស្រាយបញ្ហាមួយចំនួនដែលនាំឱ្យមានការបន្ថយនូវគម្លាតទាំងនោះ ។

## ច- <u>សន្តិសុខសង្គម សេវាថែទាំកុមារ និងមណ្ឌលថែទាំ</u> ( អនុសញ្ញាមាត្រា២៦ និង១៨.៣)

១៣៩-មាត្រា៣៦ នៃរដ្ឋធម្មនុញ្ញ ចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវការធានារ៉ាប់រងសង្គម និងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលមានចែងក្នុងច្បាប់ ។ មាត្រា៤៦ បានធានានូវសិទ្ធិរបស់ស្ត្រីក្នុងការឈប់សំរាកពេលសម្រាលកូនដោយមានប្រាក់បៀវត្សរ៍ ។ មានការទាមទារឱ្យរដ្ឋជួយសម្រួលដល់ស្ត្រី ជាពិសេសស្ត្រីនៅតំបន់ជនបទដែលពុំមានការឧបត្ថម្ភទទួលបានការឧបត្ថម្ភឱ្យស្ត្រីទទួលបានការព្យាបាលជំងឺ ហើយកូនរបស់ពួកគាត់ទទួលបានការអប់រំ និងកម្រិតជីវភាពសមរម្យ ។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវបានអនុម័តដោយសភា និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រក្នុងឆ្នាំ២០០២ ។ គោលបំណងនៃច្បាប់នេះ គឺដើម្បីបង្កើតឡើងប្រព័ន្ធសន្តិសង្គម ដោយផ្តល់ប្រាក់ឧបត្ថម្ភ រួមមានផ្នែកសុខភាពសង្គម និងគ្រោះថ្នាក់ទាក់ទងនឹងការងារ ។ ច្បាប់មានបទប្បញ្ញត្តិស្តីពីការផ្តល់មូលនិធិសន្តិសុខសង្គម និងប្រាក់សោធនសម្រាប់អ្នកសិទ្ធិវន្ត ។ កុមារក៏ត្រូវបានរាប់បញ្ចូលថាជាអ្នកសិទ្ធិវន្តដែរ ។

## ឆ- <u>កម្រិតជីវភាពរស់នៅ</u> ( អនុសញ្ញាមាត្រា២៧ កថាខ័ណ្ឌ១-៣)

១៤០-កម្ពុជាបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ។ ដែលឆ្លុះបញ្ចាំងទៅនឹងក្របខណ្ឌច្បាប់ ដែលមានស្រាប់ដូចជារដ្ឋធម្មនុញ្ញមាត្រា៥២ និង៦៣ ។ ផ្តើមចេញពីនេះមានវិធានការ ឬគោលនយោបាយជាច្រើនដែលបានប្រកាន់យក ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាព ។ ជាលទ្ធផល ភាពក្រីក្រត្រូវបានកាត់បន្ថយ ហើយសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋត្រូវបានកាន់តែប្រសើរឡើង ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តីភាពក្រីក្រនៅតែជាក្តីកង្វល់ដ៏ចម្បងមួយ ហើយការឈានទៅសម្រេចបាននូវកម្រិតជីវភាពសមរម្យគឺស្ថិតនៅលើផ្លូវមួយដ៏វែងឆ្ងាយ ។

## VIII. ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

- ប្រកាន់យកវិធានការមានប្រសិទ្ធភាពដើម្បី ៖

ក-ធ្វើឱ្យការអប់រំនៅបឋមសិក្សាមិនបង់ថ្លៃ ហើយមានលក្ខណៈជាករណីយកិច្ចសម្រាប់កុមារទាំងអស់

ខ-ធ្វើឱ្យកើនអត្រានៃការសិក្សា និងបន្ថយអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់

គ-បង្កើនការចូលរៀន ជាពិសេស សម្រាប់កុមារក្រីក្រ កុមារី កុមារក្នុងក្រុមជនជាតិភាគតិច និងកុមាររស់នៅតំបន់ជនបទដាច់ស្រយាល ។

- វិធានការ ដើម្បីធ្វើឱ្យប្រសើរនូវប្រព័ន្ធអប់រំតាមរយៈ ៖

ឃ-បង្កើនថវិកាសម្រាប់វិស័យអប់រំ

ង-ផ្តល់ការបណ្តុះបណ្តាលដើម្បីបង្កើនជំនាញគ្រូបង្រៀន

ច-រៀបចំកម្មវិធីសិក្សាឱ្យបានផ្សារភ្ជាប់ច្រើនទៅនឹងសេចក្តីត្រូវការរបស់កុមារ

ឆ-ពង្រីកឱកាសសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំក្រៅប្រព័ន្ធ រាប់បញ្ចូលក្នុងកម្រិតមធ្យមសិក្សា

ជ-បង្កើតប្រព័ន្ធវាយតម្លៃ ដើម្បីវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃប្រពន្ធ័អប់រំ ។

### ក- <u>ការងារអប់រំ</u>

#### ១- <u>ការធានាឱ្យទទួលបានសេវាអប់រំប្រកបដោយសមធម៌</u>

១៤១-រាជរដ្ឋាភិបាលចាប់ផ្តើមកែទម្រង់អប់រំអភិក្រមទូទាំងវិស័យ ដែលមានលក្ខណៈផ្តោតទៅរកប្រជាពលរដ្ឋក្រីក្រ ដើម្បីសម្រេចបាននូវការអប់រំជាមូលដ្ឋានដោយសមធម៌ ដូចដែលបានបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ។ គោលនយោបាយបានយកចិត្តទុកដាក់ដល់ជនក្រីក្រ គឺដើម្បីកាត់បន្ថយឧបសគ្គនៃការចុះឈ្មោះចូលរៀនជាសាកល និងការបញ្ចប់ការអប់រំកម្រិតបឋមដែលបានប្រតិបត្តិរួមមាន ការលុបបំបាត់ការបង់វិភាគទានក្រៅផ្លូវការក្នុងឆ្នាំ២០០១ ការផ្តល់អាហារូករណ៍កម្រិតមធ្យមសិក្សាបឋមភូមិដល់អ្នកក្រីក្រ និងជនជាតិភាគតិចក្នុងឆ្នាំ២០០២ ការបញ្ចប់សាលាបឋមសិក្សាដែលមានថ្នាក់មិនគ្រប់កម្រិត ។

១៤២-គំនិតផ្តួចផ្តើមថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំមូលដ្ឋាន ត្រូវបានអនុវត្ត រួមមាន ៖

- ការកែប្រែកម្មវិធីសិក្សាពីថ្នាក់ទី១ដល់ទី១២ និងការអនុម័តគោលនយោបាយកម្មវិធីសិក្សាថ្មីក្នុងឆ្នាំ ២០០៥ ។
- ការអនុវត្តសាកល្បងសាលាកុមារមេត្រីក្នុងឆ្នាំ២០០០ ហើយការពង្រីកចាប់ផ្តើមក្នុងឆ្នាំ២០០១ ។ ផ្អែកតាមផែនការយុទ្ធសាស្ត្រអប់រំ (ឆ្នាំ២០០៦-២០១០) ក្រសួងអប់រំបានព្រាងទិសដៅ ដើម្បីពង្រីកការគ្របដណ្តប់នៃសាលាកុមារមេត្រីដល់៧០% នៃសាលាបឋមសិក្សាទូទាំងប្រទេស ។

១- គោលនយោបាយជាតិ និងគម្រោងប្រតិបត្តិការសាលាកុមារមេត្រីត្រូវបានអនុម័តជាផ្លូវការនៅចុងឆ្នាំ២០០៧ ។

២- សាលាកុមារមេត្រីត្រូវបានអនុវត្តក្នុងសាលាបឋមសិក្សា ដើម្បីជួយកុមារទាំងអស់ឱ្យរៀនបានប្រសើរឡើង រាប់បញ្ចូលអន្តរាគមន៍ទាំង ៦ សមាសភាគ ៖

. សាលារៀន ដែលប្រមែប្រមូលសិស្សដែលមិនបានចូលរៀនឱ្យចូលរៀន

. សាលារៀនដែលធានាថា កុមារទាំងអស់រៀនបានយ៉ាងប្រសើរ ហើយសម្រេចសក្តានុពលរបស់ពួកគេ

. សាលាជំរុញឱ្យមានសុវត្ថិភាព សុខភាព អនាម័យ និងកិច្ចការពារកុមារ

. សាលារៀនដែលឆ្លើយតបដល់បញ្ហាយេនឌ័រ

. សាលារៀនដែលមានការចូលរួមដោយសិស្ស គ្រួសារ និងសហគមន៍

. សាលារៀនមានធនធានគ្រប់គ្រាន់

នៅឆ្នាំ២០០៧ ក្រសួងអប់រំយុវជន និងកីឡា បានកសាងឯកសារគោលនយោបាយ និងផែនការមេ នៃសាលាកុមារមេត្រី និងបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងឯកសារគាំទ្រការអនុវត្តកម្មវិធីសាលាកុមារមេត្រីចំនួន៤ឯកសារ និងកំពុងតាក់តែងឯកសារសាលាកុមារមេត្រីជាជំនួយសម្រាប់គ្រប់សាលារៀនដើម្បី ប្រើប្រាស់ចាប់ពីឆ្នាំ ២០០៧ ។ ឯកសារទាំងនោះរួមមាន ៖

. ផែនទីសិក្សា : សម្រាប់អនុវត្តសមាសភាគទី១ ក្នុងការប្រមូលកុមារទាំងអស់ចូលរៀន

. គោលវិធីសិស្សមជ្ឈមណ្ឌល : សម្រាប់អ្នកសម្របសម្រួល និងសម្រាប់កំណត់ត្រាគ្រូក្នុងការអនុវត្តសមាសភាគទី២ ស្តីពីប្រសិទ្ធិភាពក្នុងការបង្រៀន និងរៀន

. របៀបហូបស្អាត ផឹកស្អាត រស់នៅស្អាត : សម្រាប់អនុវត្តសមាសភាគទី៣ ទាក់ទងនឹងសុខភាព សុវត្ថិភាព និងការការពារកុមារ

. ក្រុមប្រឹក្សាកុមារ : ក្នុងការជំរុញ និងបង្កើនការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ ដែលជាសមាស ភាគទី៥ នៃកម្មវិធីសាលាកុមារមេត្រី ។

៣- ការអនុវត្តសាកល្បងនូវកម្មវិធីអប់រំកុមារអាយុ៦ឆ្នាំ ដែលចូលរៀននៅថ្នាក់ទី១ដោយមិនបានឆ្លងកាត់មត្តេយ្យសិក្សា ដើម្បីសម្រួលដល់អន្តរកាលរបស់កុមារពីការនៅផ្ទះមិនទាន់ចូលរៀន និងនៅពេលចូលរៀន ហើយពង្រឹងមូលដ្ឋាននៃការសិក្សា។ ពីឆ្នាំ២០០៦-២០០៧ មានការបណ្តុះបណ្តាលសាលាកុមារមេត្រីដល់គ្រូឧទ្ទេសចំនួន៣៧៣នាក់ នៅសាលាគរុកោសល្យនិងវិក្រិតការ ដើម្បីរៀនពីវិធីសាស្ត្រសាលាកុមារមេត្រី និងបណ្តុះបណ្តាលគ្រូឧទ្ទេសចំនួន៤២៨នាក់ អំពីកម្មវិធីអប់រំកុមារអាយុ៦ឆ្នាំដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សាមុននឹងចូលរៀនថ្នាក់ទី១ រាប់បញ្ចូលទាំងសាលាអនុវត្តផងដែរ ។

៤- នៅឆ្នាំ២០០៦-២០០៧ មានការបណ្តុះបណ្តាលគរុសិស្សជាង១៨.០០០នាក់ មកពីខេត្តចំនួន៦ ស្តីពីវិធីសាស្ត្រសាលាកុមារមេត្រី ដោយប្រើឯកសារសាលាកុមារមេត្រីដែលបានផលិតកន្លងមក។ ក្រសួង អប់រំ យុវជន និងកីឡា បានបញ្ចូលបញ្ញត្តិ និងបច្ចេកទេសគរុកោសល្យអំពីសាលាកុមារមេត្រី និងកម្មវិធីអប់រំកុមារអាយុ៦ឆ្នាំ ដែលចូលរៀនថ្នាក់ទី១ មិនបានឆ្លងកាត់មតេយ្យសិក្សាទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ ហើយបានធ្វើការបំប៉នចំពោះគ្រូឧទ្ទេសចំនួន៥៨២នាក់ មកពីសាលាគរុកោសល្យ និងវិក្រឹត្យការទាំង១៨ ខេត្ត ក្រុង។

៥- គ្រូថ្នាក់ទី១ទាំងអស់ក្នុងខេត្តចំនួន៦ បានទទួលការ បណ្តុះបណ្តាលអំពីកម្មវិធីអប់រំកុមារអាយុ៦ឆ្នាំ ដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សាមុននឹងចូលរៀនថ្នាក់ទី១។

៦- នៅឆ្នាំ២០០៧ ក្រសួង អ.យ.ក ក៏បានផ្តល់ការបំប៉នសាកល្បងដល់គ្រូឧទ្ទេសថ្នាក់ស្រុក គ្រូបង្រៀន នាយកសាលាទាំងអស់អំពីកម្មវិធីស្តីពីការរៀន និងការបង្រៀនប្រកបដោយប្រសិទ្ធភាព ដែលជាសមាសភាគទី២នៃសាលាកុមារ មេត្រីនៅក្នុងខេត្តចំនួន៦ ដើម្បីអភិវឌ្ឍជំនាញគ្រូបង្រៀន និងគាំទ្រការប្រជុំបច្ចេកទេសរៀងរាល់ថ្ងៃព្រហស្បតិ៍។ ក្រសួងបានបំពាក់បំប៉នដល់នាយក នាយិការងសាលារៀនចំនួន១.៥៥៥នាក់ (ស្រី២៧៩នាក់) គ្រូបង្រៀនកម្រិតមូលដ្ឋាន បាន២ជំនាន់មានចំនួន២.៣៩២នាក់(ស្រី៨៨៩នាក់) គ្រូជាប់កិច្ចសន្យាពីរជំនាន់បានចំនួន៦៩២នាក់ (ស្រី២០៣នាក់) គ្រូបង្រៀនថ្នាក់គួបនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកចំនួន៣០៣នាក់ (ស្រី២៦នាក់)។ ការបំប៉ននេះផ្តោតទៅលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ការប្រើប្រាស់បច្ចេកទេសពតិមានវិទ្យា និងសារគមនាគមន៍ និងជំនាញសំខាន់ៗរយៈពេលខ្លី។

១៤៣-ច្បាប់ស្តីពីអប់រំត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ ទន្ទឹមនេះដែរ ក្រសួង អ.យ.ក កំពុងរៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុទ្ធមួយចំនួនឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍស្ថាប័ន។ ក្រសួងក៏បានរៀបចំ និងអនុម័តផែនការសកម្មជាតិយូរអង្វែង ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៥។

### ១.១- <u>ការអប់រំនៅមត្តេយ្យសាលា</u>

១៤៤-ក្នុងឆ្នាំ២០០០ ក្រសួង អ.យ.ក បានកសាងគោលនយោបាយអប់រំកុមារតូចដែលជាជំហានដំបូងឆ្ពោះទៅកាន់ការអប់រំការថែទាំកុមារតូច ផ្តោតជាសំខាន់ទៅលើកុមារអាយុ៣ឆ្នាំដល់អាយុតម្រូវឱ្យចូលរៀន(៦ឆ្នាំ)។ ការថែទាំកុមារតូចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអ.យ.ក ដែលឥឡូវនេះបានបង្កើនការទទួលស្គាល់នូវសារៈសំខាន់នៃការអប់រំកុមារតូច ដែលមានអាយុពី០-៣ឆ្នាំ និងអាយុពី៣-៥ឆ្នាំ។

១៤៥-ចំណុច៤.១នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ បានគាំទ្រការអភិវឌ្ឍកុមារតូច។ ការផ្តល់ការអប់រំដល់កុមារដែលមានអាយុតិច អាចឱ្យពួកគេរៀនបានលទ្ធផលល្អនៅកម្រិតសិក្សាបន្ទាប់ទៀត និងអាចជួយកាត់បន្ថយការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សា ដែលជួយឱ្យពួកគេអាចរៀនបានថ្នាក់ខ្ពស់នៅកម្រិតបឋម

សិក្សា។ ចំណុចដៅនៅក្នុងឆ្នាំ២០១០ គឺចំនួន៥០%នៃកុមារដែលមិនបានចូលរៀននឹងបានចូលមត្តេយ្យសិក្សាមុនពេលចូលរៀននៅបឋមសិក្សា។

១៤៦-ឆ្នាំសិក្សា២០០៦-២០០៧ មានសាលាមត្តេយ្យសរុបចំនួន២.៦៤១។ ក្នុងនោះសាលាមត្តេយ្យសាធារណៈចំនួន ១.៥២៤ សាលាមត្តេយ្យឯកជនចំនួន១០០ និងសាលាមត្តេយ្យសហគមន៍ចំនួន១.០១៧។ តាមរយៈការចល័តក្រុមមត្តេយ្យ និងការចូលរួមរបស់មាតាបិតា និងសហគមន៍ កុមារចំនួន១៣០.២៨៨នាក់ អាយុពី៣-៥ឆ្នាំ បានចុះឈ្មោះក្នុងថ្នាក់មត្តេយ្យ (កុមារី៦៥.៧៦៨)។ ចាប់តាំងពីឆ្នាំសិក្សា២០០០-២០០១ ដល់២០០៦-២០០៧ ចំនួនកុមារដែលចូលសិក្សានៅថ្នាក់មត្តេយ្យបានកើនពីចំនួន៩៥.៧៩៨នាក់ ដល់១៣០.២៨៨នាក់ កុមារីមានចំនួន៦៥.៤៥៤នាក់។ ក្នុងឆ្នាំសិក្សា២០០៦ ២០០៧ មានបុគ្គលិកមត្តេយ្យសាលាចំនួន៤.៩២៣នាក់ ក្នុងនោះស្ត្រីមានចំនួន៤.៦៨០នាក់។ កុមារអាយុ៥ឆ្នាំ ដែលបានឆ្លងកាត់ថ្នាក់មត្តេយ្យកម្រិតខ្ពស់ត្រូវបានចូលរៀននៅថ្នាក់ទី១ នៅសាលាបឋមសិក្សាកើនឡើង៣.០១៣នាក់ ស្មើនឹង៣.៦៥%។

ក្រសួង អ.យ.ក បានលើកទឹកចិត្តដល់ខេត្ត ក្រុងទូទាំងប្រទេស ឱ្យខិតខំជំរុញមត្តេយ្យសិក្សា ដោយហេតុថាតាមរយៈការសិក្សាស្រាវជ្រាវ និងបទពិសោធន៍បង្ហាញថាកុមារដែលបានឆ្លងកាត់ការរៀនសូត្រនៅតាមមត្តេយ្យសិក្សាទំនងជាបន្តការសិក្សាបានវែងឆ្ងាយជាងកុមារដែលមិនបានចូលរៀននៅមត្តេយ្យសាលា។ មានកុមារតែ១៥% អាយុពី៣-៥ឆ្នាំបានទទួលសេវាកម្មអភិវឌ្ឍកុមារតូច នៅឆ្នាំសិក្សា២០០៦-២០០៧។ តាមរយៈកម្មវិធីអប់រំតាមផ្ទះ កុមារបានទទួលការគាំពារ និងថែរក្សាគ្រប់គ្រាន់ ហើយឪពុកម្តាយបានទទួលការអប់រំសម្រាប់មាតាបិតាដើម្បីផ្តល់ការគាំទ្រ និងណែនាំកូន ។

១៤៧-ក្រសួង អ.យ.ក ទទួលស្គាល់នូវសារៈសំខាន់នៃឱកាសសិក្សាកម្រិតមត្តេយ្យរបស់កុមារតូច ប៉ុន្តែដោយសារខ្វះធនធានក្រសួងមិនអាចផ្តល់បានឡើយ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ អំពាវនាវឱ្យបង្កើនការគាំទ្រពីផ្នែកឯកជន សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ ដើម្បីជួយឱ្យកុមារជាច្រើនទទួលបានផលប្រយោជន៍ពីឱកាសរៀនសូត្រតាំងពីតូច។ ក្រសួងប្រមើលមើលការបែងចែកការទទួលខុសត្រូវកិច្ចការអនុវត្តផ្នែកកុមារតូចជាមួយនឹងថ្នាក់ឃុំ ដើម្បីកំណត់ស្តង់ដាសម្រាប់គ្រប់គ្រងមត្តេយ្យសិក្សា។ ការិយាល័យអប់រំគ្រប់ថ្នាក់បានផ្តល់គោលនយោបាយណែនាំ និងជំនួយបច្ចេកទេសដល់ឃុំសម្រាប់កម្មវិធីកុមារតូច។ ការងារនេះស្របទៅតាមផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ដែលទាមទារឱ្យមានការចូលរួមឱ្យបានច្រើនពីសំណាក់ថ្នាក់ឃុំ ដើម្បីផ្តល់សេវាគាំទ្រ ដល់កុមារអាយុពី៣-៥ឆ្នាំ។

១៤៨-ដោយមានការគាំទ្រពីក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា និងមហាផ្ទៃ ចាប់ពីចុងឆ្នាំ២០០៤ មានឃុំចំនួន១៦៣ បានចាប់ផ្តើមផ្តល់សេវាកម្មអភិវឌ្ឍកុមារតូច។ ដំណើរការនេះគាំទ្រផងដែរដល់យុទ្ធសាស្ត្រថ្មី នៃវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយក្រុមប្រឹក្សាឃុំក្នុងការស្នើ និងផ្តល់សេវាសង្គមដល់កុមារ។

## ១.២- ការអប់រំនៅបឋមសិក្សា

១៤៩-ផ្នែកទី៤.២ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០ បានផ្តោតលើការពង្រឹងការចុះឈ្មោះនៅគ្រប់កម្រិតបឋមសិក្សា(ពីថ្នាក់ទី១-ទី៦) និងការបន្តការសិក្សារហូតចប់កម្រិតបឋមសិក្សា ព្រមទាំងធានាឱ្យការបង្រៀនប្រកបដោយគុណភាព។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងខិតខំធានាឱ្យមានសមធម៌ក្នុងការចុះឈ្មោះចូលរៀននៅបឋមសិក្សាតាមរយៈការកាត់បន្ថយគម្លាតយេនឌ័រ ស្ថានភាពសង្គម ទីប្រជុំជន និងជនបទ ហើយផ្តោតលើការថែរក្សាសុខភាព អនាម័យ និងបរិស្ថាន តាមរយៈសាលាកុមារមេត្រី។

១៥០-នៅឆ្នាំសិក្សា២០០៦-០៧ មានសាលារៀនបឋមសិក្សាសរុបទូទាំងប្រទេសចំនួន៦.៣៦៥។ សិស្សដែលបានចុះឈ្មោះសរុបមានប្រហែល២.៥លាននាក់ ក្នុងនោះ៤៧%គឺសិស្សស្រី។ បុគ្គលិកសិក្សាសរុបមានចំនួន៥៩.៨៨៩នាក់ ក្នុងនោះបុគ្គលិកស្រីមានចំនួន២៣.២៦១នាក់។ ក្នុងចំណោមបុគ្គលិកសរុបនោះ បុគ្គលិកមិនបង្រៀនមានចំនួនស្មើ២០%។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងរិះរកវិធានការដើម្បីធានាឱ្យផលធៀបរវាងបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀនមានលក្ខណៈកាន់តែប្រសើរឡើងជាលំដាប់ ។

អត្រានៃការសិក្សានៅបឋមសិក្សាមានភាពប្រសើរឡើង ហើយបង្ហាញនូវការធ្លាក់ចុះសន្ទឹម១នូវគម្លាតយេនឌ័រ។ ក្នុងឆ្នាំសិក្សា២០០៦-២០០៧ អត្រាពិតនៃការសិក្សានៅបឋមសិក្សាគឺ៩២,១% ធៀបនឹង៨៧%ក្នុងឆ្នាំសិក្សា២០០១-២០០២។ អត្រារួមនៃការបញ្ចប់បឋមសិក្សានៅឆ្នាំសិក្សា២០០៦-២០០៧ មានចំនួន៩០,០៨% (សិស្សស្រី៨៩,៧៥% និងសិស្សប្រុស៩០,៤១%) ដែលអាចរៀនដល់ថ្នាក់បញ្ចប់នៃកម្រិតបឋមសិក្សា។

១៥១-អត្រាពិតចូលរៀនថ្មីជាក់ស្តែងធៀបនឹងការចូលរៀនថ្មី ដែលកើតមានក្នុងថ្នាក់ទី១បានកើនពី៨១%នៅឆ្នាំសិក្សា២០០១-២០០២ ដល់៨៥,៧%នៅឆ្នាំសិក្សា២០០៦-២០០៧។ អត្រាគង់វង្សពីថ្នាក់ទី១ដល់ទី៥និងទី៦ មានការកើនឡើងតិចតួច។ ពីឆ្នាំសិក្សា២០០៣ ដល់២០០៦ អត្រាត្រួតថ្នាក់ជាមធ្យមសម្រាប់ថ្នាក់ទី១ មាន២៤% (២២%សិស្សស្រី) ហើយថ្នាក់ទី៣ មាន១៣% (១១%សិស្សស្រី)។ ទន្ទឹមនឹងភាពប្រសើរមួយចំនួនដែលត្រូវបានមើលឃើញចន្លោះពីឆ្នាំ២០០០-២០០៥ អត្រាឡើងថ្នាក់ទាប និងអត្រាបោះបង់ការសិក្សាខ្ពស់ពីថ្នាក់ទី១ ដល់ទី៣នៅបឋមសិក្សា នៅតែជាបញ្ហាធ្ងន់ធ្ងរ ដូចមានក្នុងក្រាហ្វិកខាងក្រោម ÷






១៥២-នៅឆ្នាំ២០០១ អាយុជាមធ្យមនៃការចូលរៀននៅបឋមសិក្សាយឺតបំផុតគឺ៧ឆ្នាំ៦ខែ បើប្រៀបនឹងអាយុដែលត្រូវចូលរៀនគឺ៦ឆ្នាំ។ បញ្ហានេះគួបផ្សំជាមួយអត្រាត្រួតថ្នាក់ខ្ពស់ ធ្វើឱ្យការបញ្ចប់បឋមសិក្សាមានការលំបាកសម្រាប់កុមារ ជាពិសេសសិស្សស្រី។

១៥៣-កត្តាផ្សេងទៀតដែលនាំឱ្យការបោះបង់ការសិក្សាមានអត្រាខ្ពស់ រួមមាន ភាគរយខ្ពស់នៃសាលាបឋមសិក្សាដែលមិនមានគ្រប់ថ្នាក់។ ក្នុងឆ្នាំសិក្សា២០០៦-២០០៧ ប្រហែល២៣.៦%នៃសាលាបឋមសិក្សាមិនមានគ្រប់ថ្នាក់ទាំង៦។

## ១.៣- ការអប់រំនៅមធ្យមសិក្សាបឋមភូមិ

១៥៤-ចំណុច៤.៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ ជំរុញការចុះឈ្មោះនៅគ្រប់កម្រិតក្នុងមធ្យមសិក្សាបឋមភូមិ (ពីថ្នាក់ទី៧-ទី៩) និងលើកទឹកចិត្តឱ្យសិស្សបន្តការសិក្សាទៅមធ្យមសិក្សាទុតិយភូមិ។ ចំណុចដៅនៅឆ្នាំ២០១០ គឺបង្កើនចំនួនសិស្សចុះឈ្មោះនៅកម្រិតមធ្យមសិក្សាបឋមភូមិឱ្យបានដល់១.២០០.០០០នាក់ (៧៨៣.៩១០នាក់ ក្នុងឆ្នាំ២០០៦) ដែលមាន៤៥%ជាកុមារី ៨០%មកពីជនបទ និង១៥%មកពីគ្រួសារក្រីក្រ។ ចំណុចដៅគឺបង្កើននូវអត្រាពិតចូលរៀនក្នុងមធ្យមសិក្សាបឋមភូមិឱ្យដល់៧៥% ហើយអត្រាគង់វង្សដល់៧៦%។

១៥៥-ខណៈអត្រាពិតនៃការសិក្សា និងគម្លាតយេនឌ័រក្នុងមធ្យមសិក្សាបឋមភូមិបានប្រសើរឡើងពី១៧% (១៣.៧% សិស្សស្រី ហើយ១៩.៥%សិស្សប្រុស) ឆ្នាំសិក្សា២០០០-២០០១ ដល់៣៣.៧% ឆ្នាំសិក្សា២០០៦-២០០៧ (៣៣.១% សិស្សស្រី ហើយ៣៤.៣%សិស្សប្រុស) កុមារដែលបញ្ចប់ពីសាលាបឋមសិក្សាចូលមធ្យមសិក្សា នៅមានកម្រិតទាប។ ចំនួនសាលាអនុវិទ្យាល័យបានកើនពី៤៨៦ ឆ្នាំសិក្សា២០០៣-២០០៤ ដល់៨៤៦ ឆ្នាំសិក្សា២០០៦-២០០៧។ ទោះបីជាមានការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់ថ្នាក់ទី៧ដល់ ថ្នាក់ទី៩ ក្នុងឆ្នាំថ្មីៗនេះ នៅតែមិនអាចឆ្លើយតបបាននូវសេចក្តីត្រូវការ នៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ពីព្រោះ ក្នុងចំណោមឃុំ១.៦២១ មានតែ៨១១ (ឆ្នាំសិក្សា២០០៦-២០០៧) មានអនុវិទ្យាល័យ។

១៥៦-ប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សាបឋមភូមិ ទាមទារកិច្ចខិតខំបន្ថែមដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការរៀនសូត្រ ដើម្បីឆ្លើយតបតាមទិសដៅការអប់រំសម្រាប់ទាំងអស់គ្នាមុនឆ្នាំ២០១៥។ អត្រាឡើងថ្នាក់សម្រាប់ថ្នាក់ទី៧ ដល់ទី៩ពុំសូវមានការប្រែប្រួលក្នុងចន្លោះឆ្នាំសិក្សា១៩៩៩-២០០០ ទៅ២០០៥-២០០៦ ខណៈដែលអត្រាបោះបង់ចោលការសិក្សាពុំសូវប្រែប្រួលក្នុងរយៈពេលដូចគ្នានេះដែរ។ អត្រាឡើងថ្នាក់សម្រាប់គ្រប់ថ្នាក់ក្នុងមធ្យមសិក្សាបឋមភូមិនៅតែតិចជាងចំណុចដៅ។ អត្រាបោះបង់ចោលការសិក្សាធ្លាក់ចុះចន្លោះឆ្នាំសិក្សា១៩៩៩-២០០០ និង២០០១-២០០២ និន្នាការនេះបានដើរបញ្ច្រាសចន្លោះឆ្នាំសិក្សា២០០២-២០០៣ និង២០០៥-២០០៦។

១៥៧-សិស្សពូកែមធ្យមសិក្សាបឋមភូមិចំនួន៦នាក់ ត្រូវបានក្រសួងបញ្ជូនទៅចូលរួមប្រកួតប្រជែងជ្រើសរើសជ័យលាភីអ្នកវិទ្យាសាស្ត្រវ័យក្មេងអន្តរជាតិ បានទទួលលទ្ធផលមេដាយទាំង៦នាក់ (ប្រាក់២ សំរិទ្ធ៤)។ ឆ្នាំ២០០៦-២០០៧នេះដែរ បេក្ខជនប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិថ្នាក់ជាតិបានទទួលលទ្ធផលល្អប្រសើរ ជាប់បាន៩៤,០៧%។

**អត្រាលំហូររបស់សិស្សទាំងពីរភេទ (ថ្នាក់ទី៧-៩)**

| ឆ្នាំសិក្សា | អត្រាឡើងថ្នាក់ | | | អត្រាបោះបង់ចោលការសិក្សា | | |
|---|---|---|---|---|---|---|
| | ថ្នាក់ទី ៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ |
| ១៩៩៩-២០០០ | ៧៧,២ | ៧៨,៧ | ៦២,៧ | ២១,១ | ១៩,៩ | ២៨,៤ |
| ២០០០-២០០១ | ៨២,៩ | ៨៥,៧ | ៦៥,៥ | ១៥,០ | ១២,៥ | ២៥,០ |
| ២០០១-២០០២ | ៨០,៤ | ៨៤,០ | ៦០,១ | ១៧,១ | ១៤,០ | ២៥,០ |
| ២០០២-២០០៣ | ៧៦,៧ | ៨០,៦ | ៦២,៦ | ២០,៩ | ១៧,៣ | ២៦,២ |
| ២០០៣-២០០៤ | ៧៧,៩ | ៧៩,៦ | ៦០,១ | ១៩,៩ | ១៨,៦ | ២៨,១ |
| ២០០៤-២០០៥ | ៧៦,៤ | ៧៧,៨ | ៦៩,០ | ២១,៦ | ២០,៤ | ២៥,៨ |
| ២០០៥-២០០៦ | ៧៥,៥ | ៧៧,០ | ៦៩,៧ | ២២,៥ | ២១,៦ | ២៥,២ |

*ប្រភព : អាំងឌីកាទ័រ និងស្ថិតិអប់រំឆ្នាំសិក្សា២០០០-២០០១ ដល់ ២០០៦-២០០៧*

## ១.៤- ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ

១៥៨-ចំណុច៤.៤ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៦-២០១០ ផ្នែកមធ្យមសិក្សាទុតិយភូមិត្រូវបានយកចិត្តទុកដាក់ ដើម្បីបង្កើនចំនួនសិស្សចុះឈ្មោះនៅថ្នាក់ទី១០-១២ ពិសេសសិស្សក្រីក្រ និងសិស្សស្រី តាមរយៈការផ្តល់អាហារូបករណ៍ផ្អែកលើគុណសម្បត្តិ និងលទ្ធផលនៃការសិក្សា និងលក្ខណៈវិនិច្ឆ័យនៃការទទួលឱ្យចូលរៀននៅសាលាមធ្យមសិក្សាទុតិយភូមិនៅតាមខេត្ត ក្រុងទាំងអស់។ ចំណុចដៅនៅឆ្នាំ២០១០ ចំនួនសិស្សមធ្យមសិក្សាទុតិយភូមិសរុប គឺ៣០០.០០០នាក់ (២៤១.៥០៣នាក់ ក្នុងឆ្នាំ២០០៦) ក្នុងនោះសិស្សស្រី៤០% និងសិស្ស២០% មកពី

គ្រួសារក្រីក្របំផុត ដើម្បីបង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិឱ្យបានដល់២៥% និងផ្តល់អាហារូបករណ៍ដល់និស្សិតចំនួន១.០០០នាក់ ក្នុងមធ្យមសិក្សាទុតិយភូមិ។ ៦០% នៃអ្នកទទួលអាហារូបករណ៍ជាសិស្សស្រី។

១៥៩-អត្រាពិតនៃការសិក្សាក្នុងមធ្យមសិក្សាទុតិយភូមិបានកើនពី៧,៧% ក្នុងឆ្នាំសិក្សា២០០០-២០០១ (៥,៤% ជាសិស្សស្រី ១០%ជាសិស្សប្រុស) ដល់១២,៥%។ ក្នុងឆ្នាំសិក្សា២០០៦-២០០៧ (១១,៣% ជាសិស្សស្រី១៣,៦% ជាសិស្សប្រុស) ក៏ប៉ុន្តែនៅតែទាបជាងចំណុចដៅ(១៥%) ហើយគម្លាតយេនឌ័រនៅតែជាបញ្ហា។ ភាពក្រីក្រ តម្រូវការទីផ្សារពលកម្មក្នុងផ្នែកវាយនភ័ណ្ឌ កង្វះខាតអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រីមកពីតំបន់ដាច់ស្រយាលជាដើមនាំឱ្យមានអត្រានៃការសិក្សារបស់សិស្សស្រីមានកម្រិតទាប ក្នុងមធ្យមសិក្សាទុតិយភូមិ។ មកដល់ឆ្នាំ២០០៦-២០០៧ ក្នុងចំណោមស្រុក ខណ្ឌ ទាំង១៨៥របស់ប្រទេសកម្ពុជា មានស្រុក ខណ្ឌចំនួន១៥២ ដែលមានវិទ្យាល័យ។

១៦០-ការបង្កើនអត្រាប្រឡងជាប់បញ្ចប់ថ្នាក់ទី១២ ជាពិសេសសម្រាប់សិស្សមកពីតំបន់ជនបទ និងតំបន់ដាច់ស្រយាល គឺជាអាទិភាពមួយរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្នុងការធ្វើឱ្យមានប្រសិទ្ធភាពនូវសេវាអប់រំមធ្យមសិក្សាទុតិយភូមិ។ អត្រាឡើងថ្នាក់នៅមធ្យមសិក្សាទុតិយភូមិ ពិសេសថ្នាក់ទី១២ គឺបានបន្តតាមនិន្នាការអវិជ្ជមានចន្លោះឆ្នាំសិក្សា១៩៩៩-២០០០ និង២០០៥-២០០៦។ ឧទាហរណ៍ អត្រាឡើងថ្នាក់ក្នុងថ្នាក់ទី១២ ចុះថយពី៧៦%ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់៧១,៦% ក្នុងឆ្នាំសិក្សា២០០៥-២០០៦ ទោះបីជាការប្រសើរឡើងត្រូវបានមើលឃើញក្នុងចន្លោះឆ្នាំសិក្សា២០០៣-២០០៤ និង២០០៥-២០០៦ អត្រាឡើងថ្នាក់ក្នុងថ្នាក់ទី១២ កើនពី៤៥% ដល់៧១,៦% ក្នុងរយៈពេលនៃរបាយការណ៍នេះ (មជ្ឈមណ្ឌលប្រព័ន្ធគ្រប់គ្រងអប់រំឆ្នាំ២០០៦-២០០៧)។ អត្រាបោះបង់ចោលការសិក្សាបានធ្លាក់ពី៣៦,៦% ក្នុងឆ្នាំសិក្សា២០០៣-២០០៤ ទៅ១៩,៥%ក្នុងឆ្នាំសិក្សា២០០៥-២០០៦ (១៥,១% សម្រាប់សិស្សស្រី)។ ក្នុងឆ្នាំសិក្សា២០០០-២០០១ ចំនួនសិស្សប្រលងបញ្ចប់មធ្យមសិក្សាទុតិយភូមិបានកើនគួរឱ្យកត់សម្គាល់ ទោះបីជាអត្រាប្រឡងជាប់នៅតែមានកម្រិតទាបគឺ៤០%។ ក្នុងឆ្នាំសិក្សា២០០៦-២០០៧ អត្រាប្រឡងជាប់បានកើនដល់៧២,៧៦% ស្មើនឹង៤១.៩៦៤នាក់ (របាយការណ៍ថ្វាយព្រះមហាក្សត្រឆ្នាំ២០០៦-២០០៧)។

### ១.៥ **ការងារអប់រំក្រៅប្រព័ន្ធ**

១៦១-ចំណុច៤-៥ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ ផ្នែកការងារអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តោតលើការជួយសិស្សថ្នាក់ទី៣ ដល់ទី៩ ដែលបានបោះបង់ការសិក្សាឱ្យបានចូលរៀនវិញ ហើយចូលរៀនក្នុងការអប់រំក្រៅប្រព័ន្ធ និងផ្តោតលើការពង្រីកភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ក្នុងការអនុវត្តកម្មវិធីអក្ខរកម្មមនុស្សពេញវ័យនៅតាមតំបន់ព្រំដែន និងតំបន់ជនបទ។ ចំណុចដៅមុនឆ្នាំ២០១០ សិស្សសរុបចំនួន១២០.០០០នាក់ នឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធអប់រំក្នុងប្រព័ន្ធវិញ កុមារមិនបានចូលសិក្សារយៈពេល៣ឆ្នាំចំនួន១៥០.០០០នាក់ នឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីការអប់រំក្រៅប្រព័ន្ធ និងកុមារចំនួន៤០០.០០០នាក់ នឹងត្រូវឱ្យចុះឈ្មោះក្នុងកម្មវិធីអក្ខរកម្ម។

១៦២-អត្រាអក្ខរកម្មប្រជាជនចាប់ពីអាយុ១៥ឆ្នាំឡើងទៅបានកើនពី៦៧% ក្នុងឆ្នាំ១៩៩៨ (៥៧%ជាស្ត្រី និង៨០%ជាបុរស) ដល់៧៤%(៦៤%ជាស្ត្រី និង៨៥%ជាបុរស)ក្នុងឆ្នាំ២០០៤ ដល់៨៣% ក្នុងឆ្នាំ២០០៥ ដែលទាបជាងចំណុចដៅ (៩០%ក្នុងឆ្នាំ២០០៥)។ ឆ្នាំសិក្សា២០០៦-២០០៧ មានប្រជាជនចំនួន៣៩២.៩០៤នាក់ ស្រី២៥១.៤៣២នាក់ បានចុះឈ្មោះចូលរៀនកម្មវិធីអក្ខរកម្មវិជ្ជាជីវៈរំដោះរួចពីភាពចេះអក្សរ ហើយគម្លាតយេនឌ័រក្នុងអក្ខរកម្មផ្លាស់ប្តូរតិចតួចនៅក្នុងឆ្នាំកន្លងទៅ។

១៦៣-ក្រសួងអប់រំបានអនុវត្តទម្រង់ការអប់រំនៅក្រៅប្រព័ន្ធជាច្រើនបែប រាប់បញ្ចូលកម្មវិធីដាក់បញ្ចូលកុមារក្នុងសាលាក្រៅប្រព័ន្ធចូលទៅក្នុងអប់រំក្នុងប្រព័ន្ធតាមរយៈការសិក្សាឡើងវិញ ហើយកម្មវិធីបន្ទុសម្រាប់កុមារដែលបោះបង់ចោលសាលាតិចជាង៣ឆ្នាំ។ ក្រសួងអប់រំបានកំពុងបង្កើនកំណើនអក្ខរកម្មតាមរយៈថ្នាក់អក្ខរកម្ម និងកម្មវិធីក្រោយអក្ខរកម្ម រាប់បញ្ចូលការបង្កើតមជ្ឈមណ្ឌលរៀនសូត្រក្នុងសហគមន៍ដើម្បីរក្សាកម្រិតអក្ខរកម្ម ហើយពង្រីងបំណិនជីវិត តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីអប់រំក្រៅប្រព័ន្ធបានជួយផងដែរដល់កុមារពេញវ័យដែលគ្មានជំនាញ ជាពិសេសយុវជនមិនបានរៀនសូត្រឱ្យទទួលបានការបណ្តុះបណ្តាលក្រោមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងអប់រំបានសហការជាមួយអង្គការអន្តរជាតិ ដើម្បីជួយក្នុងការធានានូវគុណភាព និងបរិមាណនៃការអប់រំក្រៅប្រព័ន្ធ។ ក្រសួងកំពុងធ្វើកិច្ចខំប្រឹងប្រែង ដើម្បីស្ថាបនាប្រព័ន្ធគ្រប់គ្រងព័ត៌មានអំពីការអប់រំក្រៅប្រព័ន្ធ ដើម្បីធានានូវការអនុវត្តដ៏មានប្រសិទ្ធភាពនៃកម្មវិធីផ្សេងៗ ដែលជួយការអប់រំក្រៅប្រព័ន្ធរបស់កុមារកុមារពេញវ័យតាមមូលដ្ឋាន ដែលមិនទាន់បានទទួលជំនាញសាមញ្ញសម្រាប់បង្កើតចំណូលគាំទ្រគ្រួសាររបស់ពួកគេ។

## ១.៦- បុគ្គលិកសិក្សា និងការអភិវឌ្ឍគ្រូបង្រៀន

១៦៤-ក្នុងឆ្នាំសិក្សា២០០៦-២០០៧ នៅបឋមសិក្សាផលធៀបសិស្ស-គ្រូស្មើនឹង៥១,៣% (៣៧,៣%នៅតំបន់ប្រជុំជន ៥៤,៨%នៅជនបទ ៦១,៦%នៅជនបទដាច់ស្រយាល) គឺខ្ពស់ជាងចំណុចដៅ(៥០%)។ នេះអាចមកពីលទ្ធផលនៃការពង្រាយគ្រូបង្រៀនមិនទាន់បានសមស្របតាមតម្រូវការ និងកង្វះខាតគ្រូបង្រៀន។ នៅមធ្យមសិក្សាផលធៀបសិស្ស-គ្រូមាន៣០,៦% ក្នុងមធ្យមសិក្សាបឋមភូមិ និង៣៣,២%ក្នុងមធ្យមសិក្សាទុតិយភូមិ។ គ្រូបង្រៀននៅបឋមសិក្សាក្នុងតំបន់ដាច់ស្រយាលប្រមាណ៤% និងគ្រូនៅតំបន់ជនបទប្រមាណ៣% មិនបានទទួលការបណ្តុះបណ្តាល (១%ក្នុងតំបន់ប្រជុំជន)។ គ្រូបង្រៀនបឋមសិក្សាដែលមានកម្រិតវប្បធម៌ត្រឹមបឋមសិក្សា នៅតំបន់ដាច់ស្រយាលមាន៣២% តំបន់ជនបទមាន៧,២% និងនៅតំបន់ទីប្រជុំជនមាន៦%។ ក្រសួងអប់រំបន្តយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជួយដល់គ្រូបង្រៀន ដែលកំពុងជួបប្រទះការលំបាកពាក់ព័ន្ធសមត្ថភាពកម្រិតវប្បធម៌ និងវិធីសាស្ត្របង្រៀន ដើម្បីធានា ថាការផ្តល់សេវាអប់រំដល់កុមារកម្ពុជាគ្រប់រូបប្រកបដោយគុណភាពល្អ និងប្រសិទ្ធភាពខ្ពស់។

## ១.៧- ការផ្គត់ផ្គង់សៀវភៅសិក្សា

១៦៥-ក្រសួងអប់រំបានផ្គត់ផ្គង់សៀវភៅសិក្សា ដោយឥតគិតថ្លៃតាមនិយាមសិស្សម្នាក់ សៀវភៅសិក្សាមុខវិជ្ជាគោលមួយ

ក្បាលសម្រាប់បឋមសិក្សា។ សម្រាប់មធ្យមសិក្សាសិស្សពីរនាក់ទទួលបានសៀវភៅមួយក្បាល ដោយឡែកចំពោះសិស្សនៅតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល សិស្សមួយនាក់ទទួលបានសៀវភៅសិក្សាមួយក្បាល។ ក្រសួងអប់រំបានផ្តល់សៀវភៅសម្រាប់គ្រូបង្រៀនក្នុងមួយនាក់មួយក្បាលសម្រាប់គ្រប់មុខវិជ្ជា។ សៀវភៅសិក្សាត្រូវបានចែកយ៉ាងទូលំទូលាយទូទាំងប្រទេស ក្នុងឆ្នាំសិក្សា២០០៦-២០០៧។ នៅក្នុងឆ្នាំសិក្សាដដែល២៤% នៃសាលាបឋមសិក្សាហើយ៣%នៃមធ្យមសិក្សា បឋមភូមិទទួលបានសម្ភារៈសម្រាប់បង្រៀន។

### ១.៨- ការអភិវឌ្ឍកន្លែងសិក្សា

១៦៦-គោលដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំគឺត្រូវធានាថាគ្រប់ភូមិទាំងអស់ ត្រូវមានសាលាបឋមសិក្សាមួយដែលមានពីថ្នាក់ទី១ដល់ទី៦នៅជិតសហគមន៍ ដូច្នេះកាត់បន្ថយសាលាបឋមមិនមានគ្រប់ថ្នាក់ ហើយបំពេញបន្ថែមថ្នាក់រៀន និងផ្តល់កន្លែងសិក្សាសម្រាប់មធ្យមសិក្សាក្នុងតំបន់ ដែលសេវាកម្មអប់រំពុំទាន់បានគ្រប់គ្រាន់ ឬសាលាដែលមានចំនួនសិស្សច្រើនលើសលុប។ ជាលទ្ធផល សាលាបឋមសិក្សាមិនគ្រប់កម្រិតបានថយចុះពី២.៤៨៤សាលា ឆ្នាំសិក្សា២០០០-២០០១ មក១.៧១៩សាលា ឆ្នាំសិក្សា២០០៥-២០០៦ ហើយនៅសល់តែ១.៤៩៩សាលា ឆ្នាំសិក្សា២០០៦-២០០៧។

### ១.៩- ថវិកា

១៦៧-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ឆ្នាំ២០០៦-២០១០) ត្រូវបានអនុវត្តដើម្បីកែទម្រង់វិស័យអប់រំធ្វើឱ្យប្រសើរនូវគុណភាពអប់រំ ហើយពង្រីកទំហំសកម្មភាពរបស់ផ្នែកនេះ។ ការបែងចែកថវិការបស់រាជរដ្ឋាភិបាលដល់ផ្នែកអប់រំដែលជាសកម្មភាពមួយមានអាទិភាពបានកើនពី១៧,៣%នៃថវិកាជាតិសរុបក្នុងឆ្នាំ២០០៤ ទៅដល់១៨,៣% ក្នុងឆ្នាំ២០០៦ ហើយត្រូវដល់២០%នៅឆ្នាំ២០០៩ ហើយថវិកាដែលបានអនុម័តសម្រាប់ឆ្នាំ២០០៧ គឺ១៩,២%។ ប្រហែល៦០%នៃថវិកាដែលបានផ្តល់គឺសម្រាប់ការអប់រំជាមូលដ្ឋាន ដែលការផ្តោតត្រូវបានធ្វើលើការចំណាយជួយអ្នកក្រីក្រ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់ថវិកាគ្រប់គ្រាន់ និងតាមពេលកំណត់នៅតែមានបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់។

## ២- ការរីកចម្រើន និងផលប៉ះពាល់លើយេនឌ័រ

១៦៨-អត្រានៃការសិក្សារបស់សិស្សស្រី នៅបឋមសិក្សាបានកើនឡើងពី៨២% ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់៩១% ក្នុងឆ្នាំសិក្សា២០០៦-២០០៧។ អាត្រានៃការសិក្សាសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បានកើនពី ១១,៦% និង៦,៨% ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់៣៣,១% និង១១,៣%ក្នុងឆ្នាំសិក្សា២០០៦-២០០៧ ដោយឡែក១ពីគ្នា។ គម្លាតរវាងអាត្រានៃការសិក្សារបស់សិស្សប្រុស និងសិស្សស្រី-០,១% ក្នុងឆ្នាំសិក្សា២០០៦-២០០៧ ក្នុងមធ្យមសិក្សាបឋមភូមិទាំងក្នុងតំបន់ទីក្រុង និងតំបន់ដាច់ស្រយាល។ មានតែ០,៦%នៃសិស្សស្រី និង០,៧%នៃសិស្សប្រុសពីតំបន់ដាច់ស្រយាល បន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ បញ្ហាកាត់បន្ថយគម្លាតយេនឌ័រក្នុងការអប់រំមូលដ្ឋាននៅតែជាឧបសគ្គ ជាពិសេសក្នុងការអប់រំមធ្យមសិក្សាបឋមភូមិ។ ផលធៀបរបស់សិស្សប្រុស-ស្រី

បានកើនពី៨៧%ក្នុងឆ្នាំ២០០១ ដល់៨៩%ក្នុងឆ្នាំ២០០៥។ ក្នុងការអប់រំមធ្យមសិក្សាមបឋមភូមិផលធៀបរបស់សិស្សប្រុស-ស្រីក្នុងបឋមសិក្សាបានកើនពី៦៣%ទៅ៧២%នៅក្នុងរយៈពេលដដែល។ ផលធៀបយេនឌ័រនៅមធ្យមសិក្សាទុតិយភូមិ បានកើនពី៤៨%ក្នុងឆ្នាំ២០០១ ដល់៥៧%ក្នុងឆ្នាំ២០០៥។

**តារាងទី៣ : គម្លាតយេនឌ័រនៃអត្រាពិតនៃការសិក្សាតាមតំបន់ទាំងអស់**

| | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|
| ១៩៩៩-២០០០ | ស្រី | ប្រុស | គម្លាត | ស្រី | ប្រុស | គម្លាត | ស្រី | ប្រុស | គម្លាត |
| តំបន់ក្រុង | ៨៧.១ | ៩៤.៧ | ៧.៦ | ២៣.៣ | ២៨.០ | ៤.៧ | ២១.៣ | ៣៣.៥ | ១២.២ |
| តំបន់ជនបទ | ៨១.៦ | ៨៩.០ | ៧.៤ | ៩.១ | ១៥.១ | ៦.០ | ២.៨ | ៦.៥ | ៣.៧ |
| តំបន់ដាច់ស្រយាល | ៤៩.៣ | ៥៦.៤ | ៧.១ | ០.៩ | ១.៣ | ០.៤ | ០.០ | ០.០ | ០.០ |
| ថ្នាក់ជាតិ | ៨១.៧ | ៨៩.១ | ៧.៤ | ១១.៦ | ១៧.១ | ៥.៥ | ៦.៨ | ១១.៩ | ៥.១ |
| ២០០៦-២០០៧ | | | | | | | | | |
| តំបន់ក្រុង | ៩២.៦ | ៩៣.៨ | ១.២ | ៥៣.៦ | ៥៣.៥ | -០.១ | ៣១.៧ | ៣៤.៨ | ៣.១ |
| តំបន់ជនបទ | ៩១.១ | ៩៣.២ | ២.១ | ៣០.០ | ៣១.៤ | ១.៤ | ៧.០ | ៩.៣ | ២.៣ |
| តំបន់ដាច់ស្រយាល | ៨២.៨ | ៨៩.០ | ៦.២ | ៩.០ | ៨.៩ | -០.១ | ០.៦ | ០.៧ | ០.១ |
| ថ្នាក់ជាតិ | ៩១.០ | ៩៣.២ | ២.២ | ៣៣.១ | ៣៤.៣ | ១.២ | ១១.៣ | ១៣.៦ | ២.៣ |

**តារាង ៤: អត្រាបញ្ចប់ភូមិសិក្សា (EMIS, ២០០៦-២០០៧)**

| **២០០៥-២០០៦** | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|
| | ស្រី | ប្រុស | គម្លាត | ស្រី | ប្រុស | គម្លាត | ស្រី | ប្រុស | គម្លាត |
| តំបន់ក្រុង | ៩៤.៨៦ | ១០៣.១៧ | ៨.៣១ | ៧០.១១ | ៨១.៤៥ | ១១.៣៤ | ៣៣.០៧ | ៤៦.១៧ | ១៣.១ |
| តំបន់ជនបទ | ៩០.៤៧ | ៨៩.៦២ | -០.៨៥ | ២៩.៥០ | ៤៣.២៥ | ១៣.៧៥ | ៦.៦១ | ១១.២៧ | ៤.៦៦ |
| តំបន់ដាច់ស្រយាល | ៥២.១៥ | ៥២.៦៦ | ០.៥១ | ១១.៨១ | ១៦.១២ | ៤.៣១ | ០.៣៩ | ០.៨៦ | ០.៤៧ |
| ថ្នាក់ជាតិ | ៨៩.៧៥ | ៩០.៤១ | ០.៦៦ | ៣៥.២០ | ៤៨.៨៤ | ១៣.៦៤ | ១១.៧០ | ១៧.៧២ | ៦.០២ |

## ២.១- ផលប៉ះពាល់លើកុមារក្រីក្រ ជួបការលំបាក និងកុមារជនជាតិភាគតិច

១៦៩-អាហារូបករណ៍សិស្សថ្នាក់ទី៧-៩ បានផ្តោតទៅលើកុមារមកពីគ្រួសារក្រីក្របំផុត និងក្រុមជួបការលំបាកផ្សេងៗទៀត ដូចជាសិស្សស្រី និងសិស្សជនជាតិភាគតិច។ នេះត្រូវបានអនុវត្តដោយមានការព្រមព្រៀងពីសាលាសហគមន៍ និងក្រុមប្រឹក្សាឃុំក្នុងវិស័យនីមួយៗ។ កន្លងមកមានប្រភពផ្តល់កម្មវិធីអាហារូបករណ៍ចំនួនពីរ គឺជំនួយ

ជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រអនុវត្តនៅក្នុងខេត្ត-ក្រុងចំនួន២១។ រដ្ឋាភិបាលប៊ែលហ្ស៊ិកបានផ្តល់ការគាំទ្រដល់ខេត្តបីដែលនៅសល់។

១៧០-ក្នុងចន្លោះឆ្នាំសិក្សា២០០៣-២០០៤ និង២០០៥-២០០៦ ក្រសួងអប់រំបានផ្តល់អាហារូបករណ៍តាមរយៈគម្រោងសម្ភាពអាទិភាពដល់និស្សិតសរុបចំនួន២១.៥៧៥នាក់ មកពីគ្រួសារក្រីក្រ និងគ្រួសារជួបការលំបាក។ ជំនួយជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រក្នុងចន្លោះឆ្នាំសិក្សា២០០៣-២០០៦ បានផ្តល់អាហារូបករណ៍សម្រាប់រយៈពេល២ឆ្នាំដល់សិស្សចំនួន១៥.០៨៧។ មានសិស្សទទួលអាហារូបករណ៍៣% បោះបង់ការសិក្សាក្នុងចំណោមនិស្សិតចំនួន៦.៥៣៥នាក់ ដែលទទួលបានអាហារូបរណ៍ពីជំនួយជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រក្នុងចន្លោះឆ្នាំសិក្សា២០០៣-២០០៤ និង២០០៤-២០០៥។ ទិន្នន័យថ្មីស្តីពីការបោះបង់ចោលការសិក្សាមិនទាន់មាននៅឡើយ។

១៧១-ការកែលម្អការទទួលសេវាអប់រំដែលមានគុណភាពខ្ពស់ប្រកបដោយសមធមិសម្រាប់សិស្សជនជាតិភាគតិច នៅតែជាសមាសភាពដ៏សំខាន់មួយក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ។ ក្នុងឆ្នាំសិក្សា២០០៦-២០០៧ នៅខេត្តមណ្ឌលគីរី អត្រាពិតចូលរៀនថ្មីរបស់កុមារីនៅបឋមសិក្សាគឺ៨,៦%ទាបជាងកុមារា។

១៧២-អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សានៅខេត្តរតនគីរី មណ្ឌលគីរី ដែលជាតំបន់មានជនភាគតិចច្រើនជាងគេ នៅមានកម្រិតទាបជាងមធ្យមភាគជាតិឆ្នាំសិក្សា២០០៦-២០០៧ (មើលតារាងទី៥)។ ខេត្តរតនគីរី អត្រាពិតនៃការសិក្សានៅបឋមសិក្សារបស់សិស្សស្រីមានត្រឹមតែ៥៩,៩% និងអត្រាពិតនៃការសិក្សារបស់សិស្សប្រុសមាន៧៤,១% ឆ្នាំសិក្សា២០០៦-២០០៧។ អត្រាពិតនៃការសិក្សាមានកម្រិតទាប ជាពិសេសសម្រាប់សិស្សស្រី ដោយសារការខកខានមិនអនុវត្តតាមអាយុត្រឹមត្រូវសម្រាប់ចូលរៀន ហេតុនេះហើយទើបយុទ្ធសាស្ត្រជាក់លាក់នានា គឺជាការចាំបាច់ដើម្បីធានាឱ្យទទួលបានការចូលរៀន ដោយសមធម៌ក្នុងចំណោមក្រុមជនភាគតិច ដូចជា កម្មវិធីសិក្សាជាពីរភាសា កម្មវិធីអាហារូបករណ៍ និងការបណ្តុះបណ្តាលដល់គ្រូក្នុងតំបន់ជនបទដែលមានជនជាតិភាគតិច។

**តារាង៥: អាំងឌីកាទ័រសំខាន់ៗ សម្រាប់ខេត្តមានជនជាតិភាគតិចឆ្នាំ២០០៦-២០០៧ នៅបឋមសិក្សា**

| ខេត្ត | អត្រាពិតចូលរៀនថ្មី | | | អត្រាពិតនៃការសិក្សា | | ផលធៀប | ផលធៀប | ផលធៀប |
|---|---|---|---|---|---|---|---|---|
| | ស្រី | ប្រុស | គម្លាត | ស្រី | ប្រុស | សិស្ស / ថ្នាក់ | សិស្ស/បន្ទប់រៀន | សិស្ស /គ្រូ |
| មណ្ឌលគីរី | ៧៤,២ | ៨២,៨ | ៨,៦ | ៧៨,៦ | ៨៤,០ | ៤២,៦ | ៤២,៦ | ១៦,០ |
| ព្រះវិហារ | ៨២,១ | ៨២,៦ | ០,៥ | ៩០,០ | ៨៨,២ | ៤៨,១ | ៥១,៣ | ៤៣,៥ |
| រតនគីរី | ៥២,៤ | ៥៥,២ | ២,៨ | ៥៩,៩ | ៧៤,១ | ៤៥,២ | ៦២,៣ | ២៤,០ |
| ស្ទឹងត្រែង | ៨៥,៧ | ៨៦,៤ | ០,៧ | ៨៥,០ | ៨៨,១ | ៤៥,២ | ៦១,០ | ២៨,១ |
| ថ្នាក់ជាតិ | ៨៥,៥ | ៨៥,៩ | ០,៤ | ៩១,០ | ៩៣,២ | ៥០,១ | ៦៥,១ | ៣១,២ |

## ៩- សកម្មភាពបណ្តុះបណ្តាល និងវប្បធម៌

### ១- ការងារកីឡា

១៧៣-មន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ក្រុង បានដឹកនាំធ្វើការប្រកួតកីឡាប្រចាំឆ្នាំ សម្រាប់កុមារនិងសាធារណជនទូទៅ។ មន្ទីរអប់រំបានជួយបង្កើតកន្លែងកីឡា និងបានបំផុសសហគមន៍ឱ្យចូលរួមក្នុងការអភិវឌ្ឍទីលានបាល់ទាត់ បាល់បោះ បាល់ទះ និងមជ្ឈមណ្ឌលអត្តពលកម្ម។ មន្ទីរបានចុះពិនិត្យការងារអប់រំកាយ និងកីឡាជាទៀងទាត់នៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យក្រោមឱវាទរបស់ខ្លួន ហើយក្រសួង អប់រំ យុវជន និងកីឡាបានសហការជាមួយអង្គការសមាគមកីឡា រៀបចំដឹកនាំការប្រកួតនៅថ្នាក់ជាតិជារៀងរាល់ឆ្នាំសម្រាប់សិស្ស និងជ្រើសរើសជើងឯកភូមិភាគទូទាំងប្រទេស និងរៀបចំឱ្យមានការប្រកួតកីឡា មហាជននានា ដើម្បីមិត្តភាព សុខភាព និងការរីករាយសម្រាប់មហាជនទូទៅ។ បច្ចុប្បន្នក្រសួងកំពុងដំណើររៀបចំបញ្ចូលកម្មវិធីកីឡាមួយចំនួនទៅក្នុងកម្មវិធីប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។

១៧៤-នៅខេត្ត/ក្រុងទាំងអស់មានការខ្វះខាតគ្រូបង្ហាត់ដែលមានបច្ចេកទេស និងមានជំនាញដើម្បីបង្ហាត់កីឡាករ និងគ្រូអប់រំកាយ និងកីឡានៅតាមសាលាបឋមសិក្សា។ មន្ទីរអប់រំ យុវជន និងកីឡាក៏ជួបការលំបាកផ្នែកមធ្យោបាយដឹកជញ្ជូនគ្រូកីឡាទៅចូលរួមប្រកួតនៅក្របខ័ណ្ឌទូទាំងប្រទេស។ មានការខ្វះខាតសម្ភារៈកីឡា និងមន្ត្រីជំនាញផ្នែកកីឡាផងដែរ។

### ២- ការងារសិល្បៈ

១៧៥-ក្រសួងអប់រំបានគាំទ្រការប្រឡងប្រជែងប្រចាំឆ្នាំ ដូចជាគំនូរ លើកតម្កើងចម្រៀង បុរាណសម័យ និងរបាំ ប្រពៃណីនៅរៀងរាល់ឆ្នាំ នៅតាមគ្រប់កម្រិតសិក្សាខេត្ត/ក្រុង។ ក្រសួងបានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បង្ហាត់បង្រៀនរបាំដល់សិស្សនៅតាមសាលារៀន និងសហការជាមួយអង្គការ JICA បង្ហាត់បង្រៀនដល់គ្រូសិល្បៈនៃមជ្ឈមណ្ឌលយុវជនរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

### ៣- ការលំបាក

១៧៦-ទោះបីមានការរីកចម្រើនក្នុងវិស័យអប់រំក្តី នៅមានការលំបាកមួយចំនួនដូចខាងក្រោម ÷

- កង្វះខាតអគារសិក្សា នៅតាមតំបន់មួយចំនួន (តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក)
- ដំណើរការកែទម្រង់ប្រព័ន្ធអប់រំ នៅមានសន្ទុះយឺត
- ខ្វះគ្រូបង្រៀន (តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក)
- គ្រូមួយចំនួនបង្រៀនខុសមុខជំនាញ និង មួយចំនួនទៀតខ្វះគរុកោសល្យក្នុងការបង្រៀន
- គ្មានអគារស្នាក់នៅសម្រាប់គ្រូដែលត្រូវបានតែងតាំងថ្មីឱ្យទៅធ្វើការ ជាពិសេស នៅក្នុងតំបន់ឆ្ងាយដាច់ស្រយាល និងតំបន់ជួបការលំបាក។

- មត្តេយ្យសាលាមានការកើនឡើងតែនៅទីក្រុង ហើយកុមារភាគច្រើននៅតំបន់ដាច់ស្រយាល មិនបានចូលរៀននៅមត្តេយ្យសាលា
- អត្រាត្រួតថ្នាក់ និងការបោះបង់ការសិក្សានៅតែមានមិនអាចលុបបំបាត់បាន
- ការផ្តល់អាហារូបករណ៍ដល់កុមារក្រីក្រមិនទាន់បានទូលំទូលាយ
- ការបង្រៀនប្រើប្រាស់វិធីសាស្ត្រកុមារមេត្រីនៅមានកម្រិត ដោយសារកង្វះខាតសម្ភារៈបង្រៀន ហើយកម្មវិធីសាលាមេត្រីមិនទាន់បានអនុវត្តទូលំទូលាយ និងមិនទាន់ត្រូវបានផ្សព្វផ្សាយជាទូទៅឱ្យឪពុក-ម្តាយ និងសិស្សានុសិស្សដឹងឮជាសាធារណៈនៅឡើយ ។
- ការងារអក្ខរកម្មនៅមានជាបញ្ហា ដោយសារការខ្វះការចូលរួមរបស់អនក្ខរជន និងខ្វះការសហការរបស់អាជ្ញាធរមូលដ្ឋាន
- ការពង្រាយឡើងវិញនូវបុគ្គលិកដែលមានលើសលប់ឱ្យចូលបង្រៀន នៅតែជាការងារត្រូវបំពេញស្របតាមផែនការរបស់ក្រសួងអប់រំ ហើយលក្ខខណ្ឌមួយចំនួនទាក់ទងដល់ការពង្រាយឡើងវិញត្រូវកែសម្រួល
- នៅតំបន់ខ្ពង់រាបសាលាភាគច្រើននៅឆ្ងាយពីគ្នា ហើយមានការពិបាកក្នុងការធ្វើដំណើរទៅដល់ ដែលធ្វើឱ្យដំណើរការទំនាក់ទំនង និងការប្រមូលព័ត៌មានមានការលំបាក និងយឺតយ៉ាវ ។

## IX. វិធានការការពារពិសេស

### ក- <u>កុមារក្នុងស្ថានភាពគ្រោះថ្នាក់</u>

#### ១- <u>កុមារភៀសខ្លួន</u> ( អនុសញ្ញាមាត្រា ២២)

***អនុសាសន៍គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក- ធ្វើច្បាប់សម្រាប់ការពារសិទ្ធិរបស់កុមារភៀសខ្លួន ឱ្យស៊ីសង្វាក់ជាមួយបទដ្ឋានអន្តរជាតិ ដែលជាប់ពាក់ព័ន្ធ។

ខ- អភិវឌ្ឍនីតិវិធីជួបជុំគ្រួសារឡើងវិញដើម្បីជួយកុមារភៀសខ្លួន ដែលអាចត្រូវបានដាក់ដាច់ដោយឡែកពីគ្រួសាររបស់ពួកគេ។

១៧៧-ទោះបីកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីឋានៈនៃជនភៀសខ្លួន និងពិធីសារទាក់ទងនឹងឋានៈជនភៀសខ្លួនក្នុងឆ្នាំ១៩៩២ក៏ដោយ ក៏កម្ពុជាពុំទាន់មានច្បាប់ការពារសិទ្ធិកុមារជាជនភៀសខ្លួនស្របទៅតាមបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនៅឡើយ ។ ទោះយ៉ាងនេះក្តី កម្ពុជាបានគោរពនិងអនុវត្តតាមបទប្បញ្ញត្តិដែលបានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយបានសហការជាមួយការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន ដើម្បីការពារជនភៀសខ្លួន។ ក្រោមកិច្ចការពាររបស់ការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅឆ្នាំ២០០៤ មានជនភៀសខ្លួន និងជនស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជាចំនួន៦៩៨នាក់ ក្នុងនោះ១៨៤នាក់ជាកុមារ។ ជនទាំងនោះគឺជាក្រុមម៉ុងតាញ៉ា ក្រុមជនស្វែងរកសិទ្ធិជ្រកកោន

និងក្រុមជនភៀសខ្លួន ដែលមកពីវៀតណាម ចិន អាហ្វហ្គានីស្ថាន ស៊ូដង់ ស្រីលង្កា អាល់សេរី សូម៉ាលី ប៊ូរ៉ាន់ឌី កាម៉ារូន និងកុងហ្គូ។ នៅឆ្នាំ២០០៦ មានកុមារជាជនភៀសខ្លួនចំនួន១៨៧នាក់ ដែលស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជា ក្នុងចំណោមនេះ១៦២នាក់ត្រូវបានបញ្ជូនទៅតាំងទីលំនៅក្នុងប្រទេសទី៣ ហើយ២៥នាក់ស្ថិតនៅក្នុងប្រទេសកម្ពុជានៅឡើយ (ក្នុងជំរុំរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន និងតំបន់ជនបទ)។ នៅឆ្នាំ២០០៧ មានចំនួនកុមារជាជនភៀសខ្លួនចំនួន៥៧នាក់ ក្នុងចំណោមជនភៀសខ្លួនចំនួន១៧៩នាក់។

១៧៨-ការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានសហការជាមួយអង្គការយូនីសេហ្វ និងអង្គការសេវាកម្មជនភៀសខ្លួនគ្រីស្តសាសនា Jesuit Refugee Service (JRS) ដើម្បីផ្តល់ការអប់រំចំណេះដឹងផ្នែកភាសាអង់គ្លេស សិទ្ធិកុមារ និងសម្របសម្រួលឱ្យពួកគេបានចូលរៀននៅសាលាដែលមានទីតាំងស្ថិតនៅក្បែរជម្រកស្នាក់នៅ ។

### ២- <u>កុមារស្ថិតក្នុងជម្លោះប្រដាប់អាវុធ</u> (អនុសញ្ញាមាត្រា ៣៨)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក-ប្រកាន់យកនូវវិធានការដែលមានប្រសិទ្ធភាព ដើម្បីកំណត់អត្តសញ្ញាណរំសាយ និងស្តារនីតិសម្បទា ផ្លូវចិត្ត និងសមាហរណកម្មចូលក្នុងសង្គមវិញនូវកុមារជាទាហាន។

ខ-ធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងដល់មន្ត្រីយោធា ដើម្បីបង្ការការជ្រើសរើសកុមារបន្ថែមជាទាហាន។

១៧៩-ច្បាប់ស្តីពីកាតព្វកិច្ចការពារមាតុភូមិ (ឆ្នាំ១៩៨៥) និងច្បាប់ស្តីពីកាតព្វកិច្ចយោធា (ឆ្នាំ២០០៦) បានចែងអំពីអាយុចូលបំរើក្នុងកងទ័ព និងអាយុត្រូវបំពេញកាតព្វកិច្ចយោធា គឺចាប់ពី១៨ ដល់៣០ឆ្នាំ។ ការរំសាយទ័ពក្នុងដំណាក់កាលទី១ ត្រូវបានធ្វើឡើងនៅឆ្នាំ២០០០ ដែលមានទាហានចំនួន១.៥០០នាក់នៃខេត្តចំនួន៤ ត្រូវបានរំសាយក្នុងចំណោមនោះ មិនមានទាហានអាយុក្រោម១៨ឆ្នាំឡើយ។

### ៣- <u>សកម្មភាពកំចាត់មីន</u>

១៨០-កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសលើពិភពលោក ដែលទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ។ កម្ពុជាបានដាក់ចេញនូវទិសដៅបញ្ចប់ការសំអាតមីននៅគ្រប់តំបន់មុនឆ្នាំ២០១២។ ទោះបីជាមានការប្រសើរឡើងក្តី ចំណុចដៅនេះអាចនឹងមិនសម្រេចបានឡើយ ដូចនេះមជ្ឈមណ្ឌលកំចាត់មីនកម្ពុជាបានកំណត់ចំណុចដៅឡើងវិញដែលនឹងសម្រេចនៅមុនឆ្នាំ២០១៥។

១៨១-មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា បានធ្វើការបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ដោយសារមីន ហើយកាត់បន្ថយបញ្ហាគ្រោះថ្នាក់ពាក់ព័ន្ធនឹងមីន និងគ្រាប់មិនទាន់ផ្ទុះ។ ក្រុមចល័តត្រូវបានបង្កើតឡើងដើម្បីបង្កើនការយល់ដឹងដល់ប្រជាជនរស់នៅតំបន់គ្រោះថ្នាក់ខ្លាំង ហើយកិច្ចខិតខំបំផ្លាញមីនកំពុងធ្វើជាបន្តបន្ទាប់ ដើម្បីសំអាតចំការមីន និង

កំចាត់ចោលគ្រាប់មិនទាន់ផ្ទុះ។ ករណីគ្រោះថ្នាក់កើតដោយសារមីនមិនទាន់មានការប្រែប្រួលឡើយក្នុង៥ឆ្នាំកន្លងទៅនេះ ជារៀងរាល់ឆ្នាំជាមធ្យមមានជនរងគ្រោះប្រហែល៨០០នាក់។ នៅឆ្នាំ២០០០ ក្នុងចំណោមជនរងគ្រោះទាំងអស់មាន២៤២នាក់ជាកុមារ (ប្រុស១៨៩នាក់ និងស្រី៥៣នាក់) ហើយនៅឆ្នាំ២០០៥មានកុមាររងគ្រោះចំនួន២៦៧នាក់ (ប្រុស២១៥នាក់ និងស្រី៥២នាក់)។ ក៏ប៉ុន្តែ ចំនួនកុមាររងគ្រោះបានថយចុះមកត្រឹម១៤០នាក់ (ប្រុស១០៩នាក់ ស្រី៣១នាក់)នៅឆ្នាំ២០០៦ និង១៣៨នាក់(ប្រុស១១៩នាក់ ស្រី១៩នាក់) នៅឆ្នាំ២០០៧។

១៨២-កត្តាមួយដែលនាំឱ្យមានការកើតឡើងនៃអត្រាខ្ពស់ចំពោះអ្នករងគ្រោះដោយសារមីន គឺដោយសារលំនៅដ្ឋានរបស់ប្រជាជននៅក្បែរចំការមីន។ បញ្ហាសំខាន់មួយផ្សេងទៀត គឺបណ្តាលមកពីការដោះគ្រាប់មិនទាន់ផ្ទុះ និងការស្វែងរកលោហៈធាតុដើម្បីលក់។

## ៩- យុត្តិធម៌អនីតិជន

### ១- ការគ្រប់គ្រងកិច្ចការយុត្តិធម៌អនីតិជន (អនុសញ្ញាមាត្រា ៤០)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក-បង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនដោយពិចារណាលើគោលការណ៍ និងបទប្បញ្ញត្តិរបស់អនុសញ្ញាជាពិសេស មាត្រា៥ ៣៧ , ៣៩ និង៤០ និងបទដ្ឋានពាក់ព័ន្ធផ្សេងទៀតរបស់អង្គការសហប្រជាជាតិក្នុងវិស័យនេះ។

ខ-ធ្វើគោលនយោបាយលំអិត និងកម្មវិធីទាក់ទងដល់ស្ថានភាពរបស់កុមារដែលទំនាស់នឹងច្បាប់ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់ស្ថានភាពរបស់កុមារដែលត្រូវបានដកនូវសេរីភាព និងផ្តោតលើការទប់ស្កាត់ការប្រព្រឹត្តិល្មើសរបស់កុមារ។

១៨៣-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១បានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ បច្ចុប្បន្ន កម្ពុជាបានបង្កើតនិងកំពុងពង្រឹងយន្តការច្បាប់ឱ្យបានសមស្របសម្រាប់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់ការពារសិទ្ធិកុមារ។

១៨៤-ច្បាប់របស់កម្ពុជា ដែលអនុវត្តចំពោះកុមារទំនាស់នឹងច្បាប់ កំពុងត្រូវបានរៀបចំឱ្យស្របតាមបទដ្ឋាន ដែលបានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់បង្ការបទឧក្រិដ្ឋ ដែលបង្កឡើងដោយអនីតិជន(គោលការណ៍ណែនាំ Riyadh) បទដ្ឋានរបស់អង្គការសហប្រជាជាតិសម្រាប់ការពារកុមារដែលត្រូវបានដកហូតសេរីភាព និងបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង)។

១៨៥-ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧÷

- មាត្រា១០០ បានចែងអំពីអនីតិជនដែលត្រូវឃាត់ខ្លួន

- មាត្រា២១៣ និង២១៤ បានចែងអំពីថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ និងបទមជ្ឈឹមទាក់ទងនឹងអនីតិជនអាយុពី១៤-១៨ឆ្នាំ។

១៨៦-ចំណុចដែលបានចែង ក្នុងសេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ និងក្រមព្រហ្មទណ្ឌ ÷

- អាយុអប្បបរមានៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ
- នីតិវិធីដោយឡែកស្តីពីយុត្តិធម៌អនីតិជន
- ការផ្តន្ទាទោសដោយឡែក ដែលផ្តល់ជម្រើសឱ្យស្ថាប័នគ្រប់គ្រងថែរក្សាកុមារ
- ការបង្វែរកុមារចេញពីប្រព័ន្ធតុលាការ មុនពេលកាត់សេចក្តី
- លក្ខខណ្ឌសម្រាប់ដាក់កុមារក្នុងការឃុំឃាំង
- ការស៊ើបអង្កេតឯករាជ្យលើបណ្តឹងតវ៉ា
- សេវាកម្មក្រោយពេលដោះលែងឱ្យមានសេរីភាព។

១៨៧-ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារអន្តរក្រសួងស្តីពីយុត្តិធម៌កុមារ ក្នុងខែតុលា ឆ្នាំ២០០៦។ ក្រុមការងារនេះមានសមាសភាព មន្ត្រីក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ (នាយកកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានពន្ធនាគារ និងក្រុមប្រឹក្សានីតិកម្ម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។ ក្រុមការងារមានភារកិច្ចដូចខាងក្រោម ÷

- រៀបចំ និងបង្កើតជាគោលការណែនាំ ស្តីពីរបៀបដោះស្រាយរឿងក្តី ដែលមានជនរងគ្រោះជាកុមារ ឬជនល្មើសជាកុមារតាមរបៀបលក្ខណៈកុមារមេត្រី
- រៀបចំ និងបង្កើតនូវពិធីសាររួមរវាងបណ្តាក្រសួងដែលពាក់ព័ន្ធ ស្តីពីការជួយគាំពារកុមារទាំងច្បាប់ និងទាំងផ្នែកសង្គមកិច្ច។
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- រៀបចំ និងបង្កើតគោលនយោបាយផ្សេងៗទៀតដែលពាក់ព័ន្ធនឹងយុត្តិធម៌កុមារ ព្រមទាំងបន្តតាមដាន និងវាយតម្លៃរាល់គោលនយោបាយនានាដែលបានដាក់ចេញ។

១៨៨-ទិន្នន័យអំពីកុមារនៅក្នុងពន្ធនាគារត្រូវបានបង្កើត ដែលអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ បានប្រមូលទិន្នន័យនេះរៀងរាល់ខែពីពន្ធនាគារទាំង២៥ទូទាំងប្រទេស។ ទិន្នន័យនេះជួយតាមដានជាប្រចាំនូវចំនួនទណ្ឌិតទាំងអស់នៅកម្ពុជា រួមទាំងភេទ អាយុ ទីតាំង និងស្ថានភាពផ្លូវច្បាប់របស់ពួកគេ។ មកដល់ឆ្នាំ២០០៧ មានកុមារជាប់ពន្ធនាគារចំនួន៦៣០នាក់(កុមារី១១នាក់) ដែលក្នុងនោះ១៩០នាក់ ជាពិរុទ្ធជន និង៤៤០នាក់(ស្រី១១នាក់) ជាទណ្ឌិត។

១៨៩-ការការពារតាមផ្លូវច្បាប់សម្រាប់កុមារទំនាស់នឹងច្បាប់ ត្រូវបានយកចិត្តទុកដាក់អនុវត្តល្អជាងមុន។ ប៉ុន្តែ នៅមានចំណុចខ្សោយមួយចំនួន ដែលក្នុងករណីខ្លះ ការការពារទាំងនេះមិនបានឆ្លើយតបទាំងស្រុងទៅនឹងនិយាម ដែលបាន

កំណត់ដោយអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីណែនាំអំពីការបង្ការបទល្មើសដោយកុមារ (គោលការណ៍ណែនាំ Riyadh) បទវិធានអប្បបរមារបស់ អ.ស.ប សម្រាប់គ្រប់គ្រងយុត្តិធម៌អនីតិជន (វិធាន Beijing)។ ការបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនដែលមានប្រព័ន្ធយុត្តិធម៌សម្រាប់កុមារវ័យជំទង់ បទប្បញ្ញត្តិពិសេសសម្រាប់វិនិច្ឆ័យ និងប្រព័ន្ធដោយឡែកសម្រាប់ឃុំកុមារនៅតែជាបញ្ហាដ៏សំខាន់មួយ ដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់។ បច្ចុប្បន្នក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារយុត្តិធម៌កុមារមួយ ដែលមានសមាសភាពមកពីក្រសួងពាក់ពន្ធ័ កំពុងធ្វើការពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ និងព្រាងលិខិតបទដ្ឋានទាក់ទងនឹងដំណើរការក្តីយុត្តិធម៌អនីតិជន។ ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌ បានបំពាក់សម្ភារៈវីដេអូសម្រាប់ធ្វើការសម្ភាសន៍កុមារនៅតាមតុលាការខេត្ត/ក្រុងចំនួន ៥ (ខេត្តកណ្តាល បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងក្រុងព្រះសីហនុ) សម្រាប់កម្មវិធីសាកល្បងក្នុងដំណើរការកាត់ក្តីកុមារ ។ ទោះជាយ៉ាងណាក្តី ក៏នៅមិនទាន់មានមេធាវី ឬចៅក្រមជំនាញដោយឡែក សម្រាប់ដោះស្រាយរឿងក្តីកុមារនៅឡើយ។

## ២- កុមារដែលត្រូវបានគេដកសិទ្ធិសេរីភាព រាប់បញ្ចូលរាល់ទម្រង់នៃការឃុំឃាំង ឬការដាក់ក្នុងពន្ធនាគារ (អនុសញ្ញាមាត្រា ៣៧)

### - ស្ថានភាពកុមារនៅក្នុងពន្ធនាគារ

១៩០-នៅមជ្ឈមណ្ឌលអប់រំកែប្រែទី២ (ព្រៃស) កុមារីស្នាក់នៅក្នុងអគារជាមួយស្ត្រីពេញវ័យ ឯកុមារាស្នាក់នៅអគារដោយឡែក។ ដោយសារកង្វះអគារនៅតាមពន្ធនាគារខេត្តមួយចំនួន កុមារត្រូវស្នាក់នៅជាមួយមនុស្សពេញវ័យ។

១៩១-នៅតាមពន្ធនាគាមួយចំនួនដូចជា មណ្ឌលកែប្រែទី២ ពន្ធនាគារខេត្តបាត់ដំបង សៀមរាប និងកណ្តាល អគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ បានសហការជាមួយនាយកដ្ឋានយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) និងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ធ្វើការបណ្តុះបណ្តាលអក្សរសាស្ត្រ ភាសា ជំនាញជួសជុលម៉ូតូ កាត់សក់ តន្ត្រីបូរាណ ការបណ្តុះផ្សិត គំនូរ កាច់ផ្កា កាត់ដេរ និងសំណង់ដល់កុមារវ័យជំទង់ ក្នុងពន្ធនាគាទាំងនោះ។ ទន្ទឹមនឹងនេះដែរ ក្រសួងមហាផ្ទៃក៏បានសហការជាមួយក្រសួងសុខាភិបាល កាកបាទក្រហមអន្តរជាតិ ដើម្បីផ្តល់ការអប់រំសុខភាព និងអនាម័យកុមារវ័យជំទង់។

១៩២-ក្រសួង ស.អ.យ ក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត កំពុងអនុវត្តកម្មវិធីផ្តល់អាហារូបត្ថម្ភដល់កុមារនៅជាមួយម្តាយជាពិរុទ្ធជន នៅមណ្ឌលកែប្រែទី២ព្រៃស និងក្នុងពន្ធនាគារក្នុងខេត្តចំនួន៣ទៀត។ ទឹកដោះគោ មី ត្រីខ សម្លៀកបំពាក់ក្មេង សាប៊ូ ត្រូវបានផ្តល់ឱ្យកុមាររៀងរាល់ខែ។ ដោយមានការឧបត្ថម្ភពីអង្គការយូនីសេហ្វ ក្រសួង ស.អ.យ បានផ្តល់ និងដំណើរការថ្នាក់មត្តេយ្យពីរកន្លែង នៅក្បែរមណ្ឌលកែប្រែទី២ព្រៃស និងពន្ធនាគាខេត្តសៀមរាប ដើម្បីផ្តល់ការអប់រំដល់កុមារដែលនៅជាមួយម្តាយ។

១៩៣-ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

បានអនុវត្តប្រកាសអន្តរក្រសួងលេខ ៨៦៣ ស.ក.ប.យ ចុះ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០១ ស្តីពីការអប់រំកែប្រែ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ទណ្ឌិត។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តគម្រោងស្តីពីការស្តារនីតិសម្បទា និងសមាហរណកម្មកុមារទំនាស់នឹងច្បាប់នៅពន្ធនាគារចំនួន ៤ ដែលមានកុមារទណ្ឌិត និងកុមារពិរុទ្ធជនចំនួន ៦០៥ នាក់ (ក្នុងឆ្នាំ២០០៧) ដោយបានផ្តល់ថ្នាក់អក្ខរកម្ម និងបានធ្វើការបណ្តុះបណ្តាលជំនាញដូចជា កាត់សក់ ភ្លេងបុរាណខ្មែរ ព្រមទាំងផ្តល់សម្ភារៈលេងកំសាន្តផងដែរ។

### ៣- <u>ការដាក់ទោសទណ្ឌលើកុមារដោយផ្តោតជាពិសេសដល់ការលុបចោលទោសប្រហារជីវិតនិង ទោសដាក់ពន្ធនាគារមួយជីវិត</u> (អនុសញ្ញាមាត្រា៣៧)

១៩៤-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣២ចែងថា ទោសប្រហារជីវិតត្រូវលប់ចោលគ្រប់ទម្រង់នៃការបង្ខិតបង្ខំ ទារុណកម្ម ការប្រព្រឹត្តិ ដែលដាក់ទម្ងន់លើទោសដែលត្រូវបានដាក់លើទណ្ឌិត ឬស្ថានភាពឃុំឃាំងនៃជនជាប់ចោទត្រូវហាមឃាត់។ អ្នកប្រព្រឹត្តិ អ្នកចូលរួមប្រព្រឹត្តិ ហើយអ្នកសមគំនិតត្រូវផ្តន្ទាទោសតាមច្បាប់។

## គ. <u>កុមារដែលស្ថិតនៅក្រោមការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច</u>

### ១- <u>ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច</u> (អនុសញ្ញាមាត្រា ៣២)

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក-អនុវត្តនីបទប្បញ្ញត្តិការងារទាក់ទងអាយុអប្បបរមាសម្រាប់ការទទួលបានការងារ

ខ-បណ្តុះបណ្តាល និងផ្តល់អធិការកិច្ចការងារ នូវមធ្យោបាយដើម្បីតាមដានត្រួតពិនិត្យការងារកុមារ

គ-ទណ្ឌកម្មសមស្របត្រូវប្រកាន់យកចំពោះអ្នករំលោភបទប្បញ្ញត្តិ

ង-ធ្វើច្បាប់ការពារក្មេងពីការងារមានគ្រោះថ្នាក់

ច-ផ្តល់សច្ចាប័នលើសន្ធិសញ្ញាលេខ១៨២ ឆ្នាំ១៩៩៩ របស់អង្គការការងារអន្តរជាតិ ទាក់ទងការហាមឃាត់ និងសកម្មភាពជាបន្ទាន់ ដើម្បីលុបចោលនូវប្រភេទការងារមិនល្អរបស់កុមារ។

១៩៥-ភាពក្រីក្រជាកត្តាចម្បង ដែលធ្វើឱ្យកុមារចូលរួមក្នុងកម្លាំងពលកម្ម។ អាស្រ័យដោយជីវភាពខ្វះខាត បានបង្ខំឱ្យកុមារជួយធ្វើការគ្រួសារ ដើម្បីជួយរកចំណូលបន្ថែម។ ក្នុងឆ្នាំ២០០១ មានកុមារធ្វើការចំនួន១,៥លាននាក់ អាយុចន្លោះពី៥-១៤ឆ្នាំ ក្នុងនោះមានកុមារចំនួន២៥០.០០០នាក់ បានចូលរួមក្នុងការងារទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ[២៥]។

---

[២៥] អង្កេតអំពីពលកម្មកុមារ (វិទ្យាស្ថានស្ថិតិជាតិ ២០០១)។

១៩៦-ការលុបបំបាត់ពលកម្មកុមារគឺជាកិច្ចការដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ក្នុងចំណោមកិច្ចការចាំបាច់ជាច្រើនទៀត ដើម្បីកសាងប្រទេសជាតិ និងលើកស្ទួយជីវភាពប្រជាពលរដ្ឋ ជាពិសេសការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការកាត់បន្ថយចំនួនកុមារធ្វើការងារពី១៦,៥% នៅឆ្នាំ១៩៩៩ មកត្រឹម១៣% នៅឆ្នាំ២០០៥ និងនៅសល់៨%មុនឆ្នាំ២០១៥។ ការប្តេជ្ញាចិត្តនេះត្រូវបានបង្ហាញនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតនាយកដ្ឋានការងារកុមារ ដោយផ្តោតទៅលើការងារសំខាន់ៗរួមមាន ១)- លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងកាត់បន្ថយពលកម្មកុមារ តាមរយៈការដកហូតកុមារពីការងារប្រកបដោយគ្រោះថ្នាក់ ផ្តល់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ ។ ២)-សហការជាមួយសង្គមស៊ីវិល និងប្រយុទ្ធប្រឆាំងការជួញដូរកុមារនិងស្ត្រី។ ដោយមានការឧបត្ថម្ភថវិកាពីអង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (ILO/IPEC) នាយកដ្ឋានបានរៀបចំ សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ(២០០៨-២០១២)។ ផែនការជាតិនេះនឹងត្រូវប្រើជាក្របខណ្ឌគោលនយោបាយរួមមួយ ដើម្បីផ្តួចផ្តើមកម្មវិធី និងគម្រោងនានាសម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា។ សេចក្តីព្រាងផែនការនេះបានឆ្លងកិច្ចប្រជុំអន្តរក្រសួង នៃទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ។ ទន្ទឹមនឹងនេះ នាយកដ្ឋានក៏បានអនុវត្តគម្រោងសាកល្បង ដែលឧបត្ថម្ភដោយក្រសួងការងារសហរដ្ឋអាមេរិក តាមរយៈអង្គការ ILO/IPEC។ ចាប់ពីពេលអនុវត្តគម្រោងក្រសួង បានដកហូតកុមារពីការងារប្រកបដោយគ្រោះថ្នាក់ចំនួន៤.២៧៥នាក់ ពីឆ្នាំ២០០១ ដល់២០០៤ នៅវិស័យ**នេសាទ ផលិតកម្មអំបិល និងចំការកៅស៊ូ**។ លើសពីនេះទៀត នាយកដ្ឋានបានបន្តអនុវត្តកម្មវិធីតាមកាលកំណត់ (Time Bound Programe) ពីឆ្នាំ ២០០៤ ដល់២០០៨ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជាបន្ទាន់ ។ កម្មវិធីនេះផ្តោតលើពលកម្មកុមារនៅតាមវិស័យ និងតំបន់ភូមិសាស្ត្រដូចខាងក្រោម ÷

- កុមារបម្រើតាមផ្ទះនៅក្រុងភ្នំពេញ
- កុមារធ្វើការក្នុងវិស័យនេសាទ (ខេត្តកំពត ក្រុងកែប ក្រុងព្រះសីហនុ)
- កុមារធ្វើការក្នុងវិស័យផលិតអំបិល (ខេត្តកំពត)
- កុមារធ្វើការក្នុងចំការកៅស៊ូ (ខេត្តកំពង់ចាម)
- កុមារធ្វើការក្នុងវិស័យឡឥដ្ឋ (ខេត្តសៀមរាប ខេត្តកំពង់ចាម)
- កុមារធ្វើការជាកម្មករលីសែង នៅតំបន់ព្រំដែនថៃ-ប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ)

តាមរយៈកម្មវិធីនេះ ក្រសួងមានគោលដៅដកហូតកុមារចំនួន១៦.០០០នាក់ រហូតដល់ដំណាច់ឆ្នាំ២០០៨ ពីការងារប្រកបដោយគ្រោះថ្នាក់ ដើម្បីឱ្យកុមារទាំងនេះទទួលបានការរៀនសូត្រ ការបណ្តុះបណ្តាលជំនាញ ការបង្កើតមុខរបរដល់កុមារ និងការផ្តល់ឥណទានដល់ក្រុមគ្រួសាររបស់កុមារដែលធ្វើពលកម្មចំនួន៣.១០០គ្រួសារ

នៅតាមវិស័យនេសាទសមុទ្រ ផលិតកម្មអំបិល សិប្បកម្ម ឡឥដ្ឋ និងកុមារបម្រើតាមផ្ទះ នៅក្នុងខេត្ត ក្រុង គោលដៅទាំង៧ខាងលើ ។ គម្រោងនេះសម្រេចបាន៩០% និងដកហូតកុមារលើសពីផែនការ ២.០០០នាក់ ។

១៩៧-អនុគណៈកម្មការជាតិស្ដីពីពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀតមកលើកុមារ ត្រូវបានបង្កើតឡើង មានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។ អនុគណៈកម្មការនេះមានតួនាទីត្រួតពិនិត្យតាមដានការអនុវត្តកម្មវិធី ដែលពាក់ព័ន្ធទៅនឹងការលុបបំបាត់ពលកម្មកុមារ ដោយផ្ដោតកិច្ចខិតខំប្រឹងប្រែងលើការលើកកម្ពស់ការយល់ដឹងអំពី សិទ្ធិកុមារ ។

១៩៨-តាមរយៈការពិគ្រោះយោបល់ស្ដីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រាជរដ្ឋាភិបាលបានអនុវត្ត វិធានការដោយផ្ទាល់ក្នុងផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្មដែលបានប្រើប្រាស់កម្មករកុមារ ។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានកំណត់នូវផ្នែកអាទិភាពដូចជា សេវាកម្មកសិកម្ម សិប្បកម្ម ការជីកយករ៉ែ និងការបំបែកថ្ម។ សកម្មភាពដែលត្រូវបានផ្ដោតការយកចិត្តទុកដាក់មានដូចខាងក្រោម ÷

ក- កុមារធ្វើការតាមផ្ទះ

ខ- កុមារធ្វើការនៅកន្លែងវាយថ្ម/យកខ្សាច់ សិប្បកម្មផលិតឥដ្ឋ លីសែង (នៅតាមព្រំដែន និងកំពង់ផែ) ភោជនីយដ្ឋាន កន្លែងខារ៉ាអូខេ ចំការកៅស៊ូ ការដ្ឋានផលិតអំបិល កន្លែងជីកយករ៉ែ រើសសំរាម សុំទាន ។

ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការពលកម្មអន្តរជាតិ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានធ្វើសកម្មភាពជាមួយសមាគមនិយោជក សហជីព អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងទិសដៅលុបបំបាត់ការធ្វើអាជីវកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មលើស្ត្រីនិងកុមារ បានអប់រំការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈការកាត់បន្ថយភាពងាយរងគ្រោះ ។ សកម្មភាពនេះបានអនុវត្តជាមួយជនដែលកំពុងរស់នៅកន្លែងគ្រោះថ្នាក់ជាងគេបំផុត ដែលអាចធ្វើឱ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះដោយមិនដឹងខ្លួន ដោយប្រាប់ឱ្យពួកគេដឹងមុនអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដែលគ្មានពត៌មានច្បាស់លាស់ និងមិនបានរៀបចំទុកជាមុន ។ ក្រសួងបានផ្ដោតការយកចិត្តទុកដាក់ចំពោះកុមារ និងស្ត្រីដែលមានជីវភាពខ្សត់ខ្សោយ ខ្វះការអប់រំ រៀនសូត្រ ដែលងាយរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម ។ គម្រោងបានឧបត្ថម្ភគាំទ្រដល់កម្មវិធីជួយកុមារ និងស្ត្រីវ័យ ក្មេងងាយរងគ្រោះ ដើម្បីកែលំអគុណភាពជីវិតរបស់ពួកគេ ។ សកម្មភាពសំខាន់ៗរបស់គម្រោងដែលផ្ដោតជាមូលដ្ឋានលើកុមាររួមមាន ការធ្វើអន្តរាគមន៍ពហុថ្នាក់ (ថ្នាក់ជាតិរហូតដល់មូលដ្ឋាន) កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ការចែករំលែកព័ត៌មាន ការបញ្ច្រាបយេនឌ័រ ចូលរួមរៀបចំផែនការជាតិ និងផែនការខេត្ត បង្កើត និងពង្រឹងយន្តការការពារក្រុមកុមារងាយរងគ្រោះ ការកសាងសមត្ថភាព លើកកម្ពស់ការយល់ដឹង វេទិកាកុមារ យុវជន ការអប់រំក្រៅប្រព័ន្ធ ការបណ្ដុះបណ្ដាលជំនាញទៅដល់ជនបទ ឥណទាន បង្កើនប្រាក់ចំណូល ការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ខេត្ត ការពិនិត្យតាមដាន និងវាយតម្លៃលើសកម្មភាពគម្រោង ដោយមានការចូលរួម ការសិក្សាស្រាវជ្រាវប្រមូលព័ត៌មានទិន្នន័យអំពីការជួញដូរ និងការផ្សព្វផ្សាយ ។

១៩៩-បញ្ហាកុមារបម្រើការងារតាមផ្ទះគឺជាបញ្ហាមួយធ្ងន់ធ្ងរ ព្រោះវានាំឱ្យមានអំពើហិង្សា ហើយកុមារមិនអាចរៀនសូត្របាន។ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនឹងជួយលុបបំបាត់ការងារតាមផ្ទះរបស់កុមារដោយប្រយោល។ ដើម្បីលុបបំបាត់ការងារតាមផ្ទះ រដ្ឋាភិបាលបានពង្រឹងការអនុវត្តច្បាប់ ដាក់ពិន័យដល់ជនដែលបង្ខំឱ្យកុមារបម្រើការតាមផ្ទះ ព្រមទាំងធ្វើការផ្សព្វផ្សាយទូលំទូលាយ និងចំទិសដៅអំពីគ្រោះថ្នាក់នៃពលកម្មតាមផ្ទះរបស់កុមារ។

២០០-ច្បាប់ស្តីពីការងារមាត្រា១៧៧ បានចែងអំពីអាយុអប្បបរមាអាចចូលបម្រើការងារត្រូវបានកំណត់ត្រឹម១៥ឆ្នាំ។ ដើម្បីការពារផលប៉ះពាល់នៃពលកម្មកុមារពាក់ព័ន្ធនឹងប្រភេទការងារ លក្ខខណ្ឌការងារ កម្រិតគ្រោះថ្នាក់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញលិខិតបទដ្ឋានមួយចំនួនដូចខាងក្រោម ÷

- សារាចរលេខ០១២ សកបយ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារនៅសិប្បកម្មផលិតឥដ្ឋ
- ប្រកាសលេខ១២៤ សកបយ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម
- ប្រកាសលេខ១០៦ សកបយ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់
- ប្រកាសលេខ៣០៥ កប.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការងារនេសាទសមុទ្រ
- ប្រកាសលេខ៣០៦ កប.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងចំការ
- ប្រកាសលេខ៣០៧ កប.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌអនាម័យ និងសន្តិសុខការងារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង
- ប្រកាសលេខ៣០៨ កប.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសស្រែអំបិល
- ប្រកាសលេខ៣០៩ កប.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ
- ប្រកាសលេខ០០២ កប.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៨ ស្តីពីការកំណត់ប្រភេទមុខរបរ និងការងារស្រាល ដែលអនុញ្ញាតឱ្យកុមារធ្វើការងារចាប់ពីអាយុពី១២ ដល់១៥ឆ្នាំ។

**២- ថ្នាំញៀន ( អនុសញ្ញាមាត្រា ៣៣)**

២០១-របាយការណ៍សិក្សាស្រាវជ្រាវឆ្នាំ២០០២ របស់ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀនស្តីពីស្ថានភាពគ្រឿងញៀននៅកម្ពុជាបានឱ្យដឹងថា មានកំណើននៃការប្រើគ្រឿងញៀនខុសច្បាប់ ជាពិសេស ម៉េតាហ្វេតាមីនក្នុងចំណោមយុវវ័យក្នុងទីប្រជុំជន។ គ្រោះថ្នាក់បន្ថែមទៀតគឺការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈការប្រើប្រាស់គ្រឿងញៀន ដោយការចាក់បញ្ចូលតាមសសៃឈាម ក៏ដូចជាតាមរយៈការរួមភេទដែលគ្មានសុវត្ថិភាព

ក្រោមឥទ្ធិពលនៃគ្រឿងញៀន ដែលទាំងនេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំង[២៦] ។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់អប់រំ និងស្តារនីតិសម្បទាយុវជន និងកុមារដែលបានប្រើប្រាស់គ្រឿងញៀន ដោយបានបង្កើតមណ្ឌលអប់រំចំនួន ១០កន្លែង (ភ្នំពេញ២កន្លែង ខេត្តបាត់ដំបង២កន្លែង បន្ទាយមានជ័យ២កន្លែង កោះកុង១កន្លែង សៀមរាប ១កន្លែង កំពង់ចាម១កន្លែង និងក្រុងព្រះសីហនុ១កន្លែង) ។ គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០០៧ អ្នកប្រើប្រាស់គ្រឿងញៀនមានចំនួន៣៥៧នាក់ ដែលចូលមកក្នុងមណ្ឌលទទួលការព្យាបាល ក្នុងនោះកុមារមានចំនួន១១៣នាក់ ។ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនទាំងនោះមាន៩នាក់ បានស្ម័គ្រចិត្តចូលមកក្នុងមណ្ឌលដើម្បីទទួលការព្យាបាល ១៦៤នាក់បានបញ្ជូនមកដោយអាជ្ញាធរមានសមត្ថកិច្ច និង១៨៤នាក់បានបញ្ជូនមកដោយគ្រួសារ ។ ក្នុងកំឡុងស្នាក់នៅក្នុងមណ្ឌលអប់រំ ជនទាំងនោះត្រូវបានហ្វឹកហាត់ អប់រំកាយសម្បទា និងអប់រំចិត្តសាស្ត្រ ។

**តារាងបែងចែកអាយុអ្នកប្រើប្រាស់គ្រឿងញៀន ដែលបានទទួលការព្យាបាលនៅក្នុងមណ្ឌល**

| **អ្នកប្រើប្រាស់គ្រឿងញៀនបែងចែកតាមអាយុ** | **ចំនួនអ្នកប្រើប្រាស់គ្រឿងញៀន** | **ភាគរយ** |
|---|---|---|
| អាយុ១២ឆ្នាំ ឬក្រោម | ៥នាក់ | ១% |
| អាយុ១៣ឆ្នាំ ដល់១៥ឆ្នាំ | ២៣នាក់ | ៦% |
| អាយុ១៦ឆ្នាំ ដល់១៨ឆ្នាំ | ៨៥នាក់ | ២៤% |
| អាយុ១៩ឆ្នាំ ដល់២៥ឆ្នាំ | ១៧៤នាក់ | ៤៩% |
| អាយុ២៦ឆ្នាំ ដល់៤៩ឆ្នាំ | ៧០នាក់ | ២០% |
| **សរុប** | **៣៥៧នាក់** | **១០០%** |

២០២-ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ÷

- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទឆ្នាំ១៩៨៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០០៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៥ ។
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកត/០៥០៥/០១០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៥ ។

[២៦] របាយការណ៍ប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៧ស្តីពីកុមារតំបន់អាស៊ីបូព៌ា ប៉ាស៊ីហ្វិក (២៣-២៤ មិនា ២០០៥ នៅសៀមរាប)

- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ ២០០៥។
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០១៩៧ /០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ហើយបានធ្វើវិសោធនកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៤ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៥។

• មាត្រា៣៥-២ ថ្មី : ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១-៥ឆ្នាំ ចំពោះជនណាលួចដាក់គ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងអាហារ ក្នុងភេសជ្ជៈ ឬក្នុងសម្ភារៈផ្សេងៗទៀត ដោយមិនឱ្យអ្នកបរិភោគ ឬអ្នកប្រើប្រាស់ដឹង។ ក្រៅពីដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលទោសពិន័យជាប្រាក់ពី២លានរៀល ដល់ ១០លានរៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥-១៥ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០លានរៀល ដល់២០លានរៀល ក្នុងករណីដូចខាងក្រោម :

ក- បានប្រព្រឹត្តបទល្មើសច្រើនដង

ខ- ចំពោះមនុស្សច្រើន

គ- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌

• មាត្រា ៨៦ ថ្មី :

១- ជនដែលដឹងច្បាស់ហេតុផល ហើយនៅតែផ្តល់ឱ្យអនីតិជនហិត ស្រូប នូវជាតិគីមីពុលណាមួយ ដែលចុះក្នុងបញ្ជីកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១-៥ឆ្នាំ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលនូវទោសពិន័យជាប្រាក់ពី២លានរៀល ដល់១០លានរៀល។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ដល់១០ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០លានរៀល ដល់២០ លានរៀល ក្នុងករណីដូចខាងក្រោម :

ក- ប្រព្រឹត្តល្មើសច្រើនដង។

ខ- ចំពោះជនរងគ្រោះច្រើននាក់។

គ- បណ្តាលឱ្យមានជំងឺគ្រោះថ្នាក់ធ្ងន់ធ្ងរ។

- សេចក្តីព្រាងច្បាប់ស្តីពីថ្នាំជក់ ដែលហាមប្រាមមិនឱ្យលក់ថ្នាំជក់ដល់កុមារអាយុក្រោម ១៨ឆ្នាំឡើយ។ សេចក្តីព្រាងច្បាប់នេះបានប្រជុំឆ្លងទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ។

២០៣-លិខិតបទដ្ឋានផ្សេងៗទៀត ÷

- ព្រះរាជក្រិត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួល

ព្រះរាជក្រិត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

- សារាចរលេខ០៣ សរ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តនីតិវិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។
- ប្រកាសលេខ៣០៣ សកបយ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្តារយុវនីតិសម្បទា ។

## ៣- <u>ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (អនុសញ្ញាមាត្រា ៣៤)</u>

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក-ពិនិត្យឡើងវិញនូវច្បាប់ ដើម្បីអនុវត្តន៍។

ខ-ក្នុងខណៈឥឡូវនេះ អនុវត្តន៍ឱ្យបានពេញលេញ ច្បាប់ដែលមានស្រាប់ប្រឆាំងអាជីវកម្មផ្លូវភេទ ។

គ-អនុវត្តន៍ឱ្យបានពេញលេញនូវផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (២០០០-២០០៤) ហើយផ្តល់ធនធានគ្រាប់គ្រាន់ទាំងបុគ្គលិក និងថវិកាដើម្បីអនុវត្តន៍ផែនការ។

ឃ-ពង្រឹង និងពង្រីកសេវាកម្មសង្គម ដើម្បីស្តារនីតិសម្បទារបស់កុមាររងគ្រោះដោយអំពើអាជីវកម្មផ្លូវភេទ

ង-កាត់ទោសអ្នករំលោភបទប្បញ្ញត្តិ។

ច-ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាពិសេសជាមួយប្រទេសជិតខាង ហើយបង្កើនការត្រួតពិនិត្យព្រំដែន។

២០៤-កម្ពុជាមានផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(២០០០-២០០៤)។ សកម្មភាពជាច្រើនត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងអង្គការនានា ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការដៃគូសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ ដែលសម្រេចបានលទ្ធផលសំខាន់ៗជាច្រើន។

### ៣.១- <u>ការពិនិត្យឡើងវិញ និងការអនុវត្តច្បាប់</u>

២០៥-ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស(១៩៩៦) មានកង្វះធាតុសំខាន់ៗជាច្រើន ហើយផ្តល់និយមន័យមិនគ្រប់គ្រាន់ទាក់ទងទៅនឹងប្រធានបទ។ ច្បាប់ថ្មីស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដែលរៀបចំដោយក្រសួងយុត្តិធម៌ ត្រូវបានអនុម័តដោយរដ្ឋសភានៅខែធ្នូ ឆ្នាំ២០០៧ ។ ច្បាប់ស្តីពីសុំកូនអន្តរប្រទេសដែលរៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយដែលមានការចូលរួមមតិពីក្រសួងនិងអង្គការពាក់ព័ន្ធ ត្រូវបានបញ្ជូនជាថ្មីម្តងទៀតទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅខែវិច្ឆិកា ឆ្នាំ២០០៧។ ច្បាប់ជាច្រើនស្ថិតនៅក្នុងការពិនិត្យឡើងវិញរបស់ក្រសួងយុត្តិធម៌ ហើយបានកំណត់កត្តាទាក់ទងនឹងការជួញដូរមនុស្ស ជារួមមានដូចជា ក្រមព្រហ្មទណ្ឌ ។

២០៦-ការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជាបានជួបប្រទះនូវការលំបាកដូចជា ការយល់ដឹងអំពីច្បាប់ ធនធាន សម្ភារៈ និងសមត្ថភាពមិនមានគ្រប់គ្រាន់។ សេវាកម្មច្បាប់ និងតំណាងជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានផ្តល់ដោយគណៈមេធាវីរបស់កម្ពុជា។ រាជរដ្ឋាភិបាលបានផ្តល់ថវិកាដល់ការប្រព្រឹត្តិទៅរបស់គណៈមេធាវី ដើម្បីធានាឱ្យអ្នកក្រីក្រទទួលបាននូវការការពារតាមច្បាប់ដោយមិនបង់ថ្លៃ។ ជំនួយនេះត្រូវបានផ្តល់ផងដែរដោយអង្គការមិនមែនរដ្ឋាភិបាលដូចជាគម្រោងការពារក្តីកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់កម្ពុជា។ តុលាការមួយចំនួនក្នុងប្រទេសកម្ពុជា ជាពិសេសតុលាការខេត្តកណ្តាលបានបង្កើនការប្រើប្រាស់កាសែតវីដេអូ ជាភស្តុតាងសម្រាប់ការស៊ើបអង្កេតរឿងក្តី ដែលពាក់ព័ន្ធនឹងកុមារ និងមិនទាមទារឱ្យកុមាររងគ្រោះបង្ហាញខ្លួននៅមុខតុលាការឡើយ។ អង្គការអន្តរជាតិទេសន្តប្រវេសន៍ដោយមានការគាំទ្រ ផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអ៊ីតាលី បានអនុវត្តកម្មវិធីគាំទ្រគោលនយោបាយ និងច្បាប់ ក្នុងខេត្តក្រុងចំនួន៥ ដើម្បីពង្រឹងសមត្ថភាពរបស់ភ្នាក់ងារអនុវត្តច្បាប់ និងតុលាការតាមខេត្តក្នុងការចាត់ចែងរឿងក្តីទាក់ទងការជួញដូរមនុស្ស។

២០៧-ដោយមានការឧបត្ថម្ភពីគម្រោង "កិច្ចសហប្រតិបត្តិការប្រចាំតំបន់អាស៊ីទប់ស្កាត់ការជួញដូរមនុស្ស (ARCPPT)" ក្រសួងយុត្តិធម៌បានបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា នគរបាល និងកងរាជអាវុធហត្ថ អំពីច្បាប់ទាក់ទងទៅនឹងការជួញដូរមនុស្ស និងជំនាញក្នុងការស៊ើបអង្កេត។ ដើម្បីពង្រឹងការអនុវត្តច្បាប់ ក្រសួងយុត្តិធម៌បានចេញសេចក្តីណែនាំលេខ៩៧៨ព្រ.ទ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍បង្ក្រាបអំពើល្មើសច្បាប់មួយចំនួន និងសេចក្តីណែនាំលេខ៧០០កយព្រ.ទ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសជនប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។

២០៨-អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៦៣អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ បានចែងពីការដាក់ពិន័យដល់ជនដែលបញ្ចាំង កាត់ត តម្លើងរូបភាព ថតចម្លង បញ្ចូលសម្លេង ជួល លក់ និងចែកចាយវីដេអូអាសអាភាស (មាត្រា២៨) និងការដាក់ពិន័យដល់ចារី និងសហចារីដែលផលិតវីដេអូអាសអាភាស(មាត្រា២៩)។ ដើម្បីអនុវត្តអនុក្រឹត្យនេះ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ១០សសរស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងមួយដែលមានតំណាង៧ក្រសួងចូលរួម និងដឹកនាំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ គណៈកម្មការនេះបានសហការជាមួយអាជ្ញាធរដែនដីគ្រប់ខេត្ត/ក្រុង ទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មចំពោះជនដែលលក់និងបញ្ចាំងកាសែតវីដេអូ វីស៊ីឌី ឌីវីឌី និងទស្សនាវដ្តីអាសអាភាសជាច្រើនលើក។

២០៩-តាមសេចក្តីប្រកាសលេខ១០៥១ប្រ.ក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ ក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មាធិការសម្របសម្រួល លើកគម្រោងការពារផ្លូវច្បាប់ប្រឆាំងអាជីវកម្មផ្លូវភេទលើកុមារ និងបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន តាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២។ បន្ទាប់មកក្រសួងបានចេញប្រកាសលេខ២១៥៤ប្រ.ក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់រចនាសម្ព័ន្ធ និងភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ នាយកដ្ឋាននេះ មាន

ការិយាល័យជំនាញចំនួន៥នៅថ្នាក់កណ្តាល ការិយាល័យនៅតាមខេត្ត/ក្រុងចំនួន១៧ និងផ្នែកជំនាញនៅតាមខេត្ត/ក្រុងចំនួន៧។ អង្គភាពទាំងនោះមានភារកិច្ចអនុវត្តច្បាប់ ដោយគោរពតាមនីតិវិធីក្នុងការស៊ើបអង្កេត ប្រមូលភស្តុតាង ស្វែងរកចាប់ជនល្មើស។

២១០-នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរបស់ក្រសួងមហាផ្ទៃ បានសហការជាមួយគណៈកម្មាធិការសម្របសម្រួល អង្គការយូនីសេហ្វ ទស្សនៈពិភពលោក ទេសន្តប្រវេស្សន៍អន្តរជាតិ សង្គ្រោះកុមារន័រវេស៍ និងអង្គការ UNCOHCHR អនុវត្តកម្មវិធីស្តីពីការងារអនុវត្តច្បាប់ប្រឆាំងនឹងការរំលោភផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរស្ត្រី និងកុមារ (LEASETC) ដោយបានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់ស្នងការរងមន្ត្រីនគរបាលជំនាញ និងមន្ត្រីនគរបាលឈរជើងនៅតាមព្រំដែននៃខេត្ត/ក្រុងចំនួន១៣ សរុបមានចំនួន៦០០នាក់ មន្ត្រីប៉ូលីសយុត្តិធម៌ចំនួន១.៥០០នាក់ និងមន្ត្រីនគរបាលពិសេសចំនួន២៩៤នាក់។ ការបណ្តុះបណ្តាលនេះសំដៅបង្កើនជំនាញស៊ើបអង្កេត ការស្វែងរកភស្តុតាង ការជួយសង្គ្រោះ នីតិវិធីក្នុងការសំភាសន៍ និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ទន្ទឹមនេះដែរ ក៏បានផលិតខ្សែភាពយន្តដែលមានចំណងជើងថា **"ជនរងគ្រោះ"** ហើយធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍។ នាយកដ្ឋានមានទូរស័ព្ទពិសេស២៤ម៉ោង លើ២៤ម៉ោង (Hotline) ដែលទទួលការហៅចូលបានពីរភាសា គឺខ្មែរ និងអង់គ្លេស ហើយបានទទួលការហៅចូលជាង៨០០លើកក្នុងមួយឆ្នាំៗ។ លើសពីនេះទៀត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានបានរៀបចំបន្ទប់សម្ភាសសម្រាប់កុមារ (Child friendly interview room) ដោយប្រើម៉ាស៊ីនថតរូបភាព (Camara Video) នៅតាមស្នងការដ្ឋាននគរបាលខេត្ត/ក្រុងចំនួន១០ ក្នុងគោលដៅបញ្ចៀសការភ័យខ្លាចដល់កុមាររងគ្រោះនៅពេលធ្វើសម្ភាសន៍។

២១១-នាយកដ្ឋានបានជំរុញអង្គភាពជំនាញតាមខេត្ត/ក្រុងឱ្យអនុវត្តផែនការលេខ០២៣របស់ក្រសួង ដែលក្នុងនោះមានវិធានការធំៗចំនួន៤គឺ ១)-ការគ្រប់គ្រង និងតាមដានសភាពការណ៍ ២)-ការបង្ការទប់ស្កាត់ ៣)-ការបង្ក្រាប ៤)-ការពង្រីកនិងពង្រឹងធនធានមនុស្ស។ ដោយមានកិច្ចសហការល្អជាមួយអង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ អាជ្ញាធរដែនដី ក្នុងការផ្សព្វផ្សាយដល់សិស្ស និងប្រជាពលរដ្ឋឱ្យយល់អំពីច្បាប់ ល្បិចកល និងសកម្មភាពរបស់ជនល្មើស ពួកគេបានសហការផ្តល់ព័ត៌មានទាន់ពេលដើម្បីចាប់ខ្លួនជនល្មើស។ ក្នុងករណីជនល្មើសជាបរទេស នាយកដ្ឋានបានសហការជាមួយស្ថានទូត ឬស្ថានកុងស៊ុលប្រចាំនៅកម្ពុជាដើម្បីនាំជននោះមកផ្តន្ទាទោស។

២១២-នៅខែសីហា ឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមការងារបានចេញសេចក្តីសម្រេចលេខ២៨១៥ ស.ស.រ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧ បង្កើតលេខាធិការដ្ឋានមួយ ដែលមានសមាសភាពពីក្រសួងពាក់ព័ន្ធ ហើយដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិមួយរូប។ លេខាធិការដ្ឋាននេះ មានភារកិច្ចជំនួយឱ្យក្រុមការងារថ្នាក់ជាតិក្នុងការតាមដានចាត់

តាំងការអនុវត្តផែនការយុទ្ធនាការ តាមដានការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង សម្របសម្រួល និងសហការជាមួយតំណាងអង្គការជាតិ-អន្តរជាតិ ជំរុញការផ្សព្វផ្សាយផែនការយុទ្ធនាការសម្របសម្រួលជាមួយស្ថាប័នតុលាការ និងធ្វើរបាយការណ៍រាល់៣ខែជូនក្រុមកាងារថ្នាក់ជាតិ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានចេញលិខិតលេខ ១៧៤៨ សជណ.អរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧ ដោយបានចាត់ទុកថ្ងៃ១២ ធ្នូ ជាទិវាប្រឆាំងការជួញដូរមនុស្ស។

២១៣-ការស៊ើបអង្កេតករណីរំលោភបំពានលើកុមារ ការការពារតាមផ្លូវច្បាប់ដល់ជនរងគ្រោះ និងការផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធក៏ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដោយអង្គការមិនមែនរដ្ឋាភិបាល មានសម្ព័ន្ធអង្គការកូសេកា ជាដើម។

### ៣.២- ការទប់ស្កាត់ និងការបណ្តុះបណ្តាល

២១៤-ក្រសួងកិច្ចការនារីបានសហការជាមួយក្រសួង និងអង្គការពាក់ព័ន្ធអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹង ការផ្តល់ព័ត៌មានគួរឱ្យទុកចិត្តបានពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដល់ក្រុមដែលងាយរងគ្រោះ។ ចាប់ពីឆ្នាំ ២០០៤ដល់២០០៦ ដោយមានការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលប្រទេសហ្វាំងឡង់ និងមានកិច្ចសហការជាមួយអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ ( IOM ) ក្រសួងអនុវត្តសកម្មភាពសំខាន់៧គឺ ÷

១-បណ្តុះបណ្តាលច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងការធ្វើអាជីវកម្មលើមនុស្សដល់មន្ត្រីនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងខេត្ត ក្រុងចំនួន១៨ ដែលមានអ្នកចូលរួមចំនួន៣.២៤០នាក់ ។

២-ស្វែងរកមតិគាំទ្រនៅថ្នាក់ជាតិ អំពីការផ្តល់សច្ចាប័នលើពិធីសាររបស់អង្គការសហប្រជាជាតិ ការអនុម័តច្បាប់ប្រឆាំងការជួញដូរមនុស្ស ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយសារអំពើជួញដូរ។

៣-ធ្វើការផ្សព្វផ្សាយនៅក្នុងខេត្ត/ក្រុងចំនួន៦ ដែលមានអ្នកចូលរួមប្រមាណ១១២.៣៤០នាក់ តាមរយៈការបញ្ចាំងវីដេអូ ការសំដែងរឿងកំប្លែង ការធ្វើសំណួរ ការប្រជុំដោយមានចែកឯកសារ និងសម្ភារៈ ព្រមទាំងទម្រង់សម្រាប់មេភូមិប្រើប្រាស់នៅពេលមានហេតុការណ៍ក្នុងករណីជួញដូរមនុស្សកើតឡើង។ ទន្ទឹមនេះដែរក៏មានការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាបន្តបន្ទាប់។

៤-អនុវត្តដកពិសោធន៍នូវកម្មវិធីមូលនិធិភូមិ ក្នុងភូមិចំនួន១០ នៃស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ មូលនិធិនេះមាន៣ផ្នែកគឺ មូលនិធិសង្គ្រោះបន្ទាន់ មូលនិធិភូមិ( ប្រាក់កម្ចី) និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្រុមគ្រួសារ ដែលជាមុខសញ្ញាងាយរងគ្រោះដោយការជួញដូរ។ ចាប់ពីឆ្នាំ២០០៣ដល់២០០៦ ដោយមានការឧបត្ថម្ភថវិកាពីកម្មវិធីអភិវឌ្ឍន៍របស់សហរដ្ឋអាមេរិក(USAID)និងមានកិច្ចសហការជាមួយអង្គការ(IOM) ក្រសួងបានអនុវត្តគម្រោងផ្សព្វផ្សាយដើម្បីប្រយុទ្ធប្រឆាំងការជួញដូរស្ត្រីនិងកុមារ នៅក្នុងស្រុកចំនួន៧០ នៃ១៨ខេត្តដែលមានអ្នកចូលរួមចំនួន៣០៥.០០០នាក់។

ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ ដោយមានការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលប្រទេសហ្វាំងឡង់ និងមានកិច្ចសហការជាមួយអង្គការទេសន្តប្រវេសន៍អន្តរជាតិ(IOM) ក្រសួងបានបន្តកម្មវិធីដោយធ្វើសកម្មភាពក្នុងខេត្តគោលដៅចំនួន៥ ផ្តោតលើផ្នែកសំខាន់ៗចំនួន៣ ÷

- ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ដោយគាំទ្រដល់ការបង្កើត និងការអនុវត្តរបស់ក្រុមការងារថ្នាក់ជាតិ និងជំរុញការផ្សព្វផ្សាយនិងការអនុវត្តច្បាប់ជួញដូរថ្មី។
- សកម្មភាពទាក់ទងជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ការកាត់បន្ថយភាពក្រីក្រក្នុងភូមិចំនួន១៣៥នៃឃុំចំនួន២៧ ក្នុងស្រុកចំនួន៩ នៃខេត្តគោលដៅទាំង៥ និងបន្តអនុវត្តសកម្មភាពដែលមានពីមុន។

២១៥-ក្រសួងស.អ.យ ដោយមានការឧបត្ថម្ភពីអង្គការយូនីសេហ្វបានបង្កើតកម្មវិធី បណ្តាញការពារកុមារតាមសហគមន៍ នៅខេត្ត ក្រុងចំនួន៥ គឺភ្នំពេញ ខេត្តព្រៃវែង ស្វាយរៀង បាត់ដំបង និងបន្ទាយមានជ័យ។ បច្ចុប្បន្នកម្មវិធីនេះកំពុងអនុវត្តនៅ២ខេត្ត គឺព្រៃវែងនិងស្វាយរៀង និងជាបទពិសោធន៍សម្រាប់ពង្រីកទូទាំងប្រទេស។ កម្មវិធីនេះធ្វើឱ្យភ្នាក់ងារ អាជ្ញាធរដែនដី និងសហគមន៍បានធ្វើការរួមគ្នាដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ ហើយតាមដានសកម្មភាពជនទាំងនោះ។ ទន្ទឹមនេះដែរ កុមាររងាយរងគ្រោះមួយចំនួននៅតាមសហគមន៍ក៏ទទួលបានសេវាសង្គម ហើយមូលនិធិសង្គមកិច្ចត្រូវបានបង្កើតឡើង ដើម្បីសង្គ្រោះបន្ទាន់ដល់កុមារងាយរងគ្រោះនៅក្នុងភូមិគោលដៅចំនួន៤០៨ នៃខេត្តទាំង២។ បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិចំនួន១៤.០៣៩ នៃ១៨៤ស្រុកទូទាំងប្រទេសលើប្រធានបទចំនួន៣គឺ ១)-ការចុះអត្រានុកូលដ្ឋាន ២)-ការប្រឆាំងការរំលោភបំពានផ្លូវភេទ ៣)-ការប្រឆាំងការវាយដំលើកុមារ។

២១៦-ក្រសួង ស.អ.យ បានចេញប្រកាសលេខ២១៧សអយ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ដែលផ្តោតលើការថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះដែលពុំស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត បច្ចុប្បន្នក្រសួងមានមណ្ឌលចំនួន២០នៅតាមខេត្ត-ក្រុង។

២១៧-ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការផ្សព្វផ្សាយអំពីការជួញដូរមនុស្សដល់សិស្សសាលា តាមរយៈកម្មវិធីសិក្សាក្នុងនិងក្រៅប្រព័ន្ធ និងមានកម្មវិធីពិនិត្យតាមដានសុវត្ថិភាពកុមារតាមសាលា លើកកម្ពស់ការយល់ដឹងដល់សហគមន៍ឱ្យមានស្មារតីប្រុងប្រយ័ត្នការពារកុមាររួចផុតពីការជួញដូរ។ ក្រៅអំពីការបណ្តុះបណ្តាលនិងយុទ្ធនាការផ្សព្វផ្សាយ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួង ដោយមានការគាំទ្រពីកម្មវិធីអន្តរភ្នាក់ងារនៃអង្គការសហប្រជាជាតិ (UNIAP) បានផលិតសៀវភៅចំនួន២ក្បាលសម្រាប់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធ ដែលមានអត្ថន័យផ្តោតទៅលើអនុសញ្ញាសិទ្ធិកុមារ ការលុបបំបាត់ការជួញដូរនិងអាជីវកម្មផ្លូវភេទ។ គ្រូបង្រៀនចំនួន៥៦នាក់អញ្ជើញមកពីខេត្ត/ក្រុងចំនួន៥ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីវិធីសាស្ត្រក្នុងការបង្រៀននៅឆ្នាំ២០០២។ គ្រូបង្វឹកទាំងនោះបានចែកសៀវភៅចំនួន៥០០០ក្បាល ដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស និងអ្នកភូមិចំនួន១.២០០នាក់ ដែលបាន

ទទួលការបណ្តុះបណ្តាល។ សៀវភៅទាំងនោះត្រូវបានប្រើប្រាស់ក្នុងការបណ្តុះបណ្តាលអក្សរសាស្ត្រ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល។

២១៨-សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia-Acts) មាន១១អង្គការជាសមាជិក បានអនុវត្តកម្មវិធីបណ្តាញភូមិសុវត្ថិភាព ដោយបានជំរុញកុមារឱ្យចូលរៀន លុបបំបាត់អំពើហិង្សា ល្បែងស៊ីសង កម្មវិធីនេះបានផ្តល់ប្រាក់កម្ចី ដើម្បីឱ្យប្រជាជនបង្កើតមុខរបរ ហើយមានកម្មវិធីផ្សេងៗទៀតដូចជា ជំរុញការអនុវត្តច្បាប់ អប់រំសហគមន៍ឱ្យយល់ដឹងពីការជួញដូរ មិត្តអប់រំមិត្ត និងស្រង់ព័ត៌មាននិងទិន្នន័យ។

២១៩-អង្គការដែលជាសមាជិកនៃសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា (COSECAM) ដែលមាន២២អង្គការជាសមាជិក បាននិងកំពុងអនុវត្តកម្មវិធីចម្បង ៣ ៖

- បានធ្វើការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទដល់កុមារ និងប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍មួយចំនួននៃខេត្ត/ក្រុងចំនួន៩ ដល់បុគ្គលិកជំនាញនៃស្ថាប័នរដ្ឋាភិបាល និងអង្គការ មួយចំនួនដល់សិស្សនៅតាមសាលាក្នុងនិងក្រៅប្រព័ន្ធ តាមរយៈបណ្ណាល័យចល័ត ការប្រជុំផ្សព្វផ្សាយ ការចែកខិតប័ណ្ណ ការបញ្ចាំងវីដេអូ ការផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍ ។
- បានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារក្រីក្រក្នុងសហគមន៍មួយចំនួន ដើម្បីឱ្យពួកគេមានមុខរបរ និងដើម្បីកុំឱ្យធ្លាក់ក្នុងភាពរងគ្រោះនៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។
- អង្គការមួយចំនួនបានរៀបចំឱ្យមានបណ្តាញការពារកុមារនៅតាមសហគមន៍ ដែលខ្លួនបានអនុវត្តកម្មវិធី និងមានការត្រួតពិនិត្យតាមដាន។

២២០-គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) ដែលមាន៤៦អង្គការជាសមាជិក បានរៀបចំពិធីផ្សេងៗ ក្នុងទិសដៅផ្សព្វផ្សាយបញ្ហាជួញដូរផ្លូវភេទ តាមរយៈការផលិតបដា កម្មវិធីសម្តែងរឿងខ្លីៗ សំណួរ-ចម្លើយ និងចែកចាយខិតប័ណ្ណ ផ្ទាំងរូបភាព ដែលផលិតដោយអង្គការសមាជិក។ ក្រៅពីនេះ គ.អ.ស.ក បានសហការជាមួយបណ្តាញអ៊ិកផាត(ECPAT) និងកូសេកាំ (COSECAM) លើការចងក្រងទិន្នន័យរួមគ្នាស្តីពីការរំលោភ និងជួញដូរផ្លូវភេទនៅកម្ពុជា។

២២១-អង្គការអប់រំពិភពលោក និងអង្គការជាដៃគូ ដូចជាអង្គការខេប(KAPE) មិត្តសំឡាញ់ និងមូលនិធិអាស៊ីបានចុះអនុស្សរណៈជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តកម្មវិធីអ៊ុបសិន នៅក្នុងខេត្តព្រៃវែង កំពង់ចាម បន្ទាយមានជ័យ និងភ្នំពេញ ដោយបានបង្កើននិងជំរុញការអប់រំប្រកបដោយសមធម៌ចំពោះកុមារីដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងការធ្វើអាជីវកម្មផ្លូវភេទតាមរយៈកម្មវិធីអប់រំក្នុងនិងក្រៅប្រព័ន្ធ។ បានផ្សព្វផ្សាយនៅតាមសហគមន៍អំពីការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងជំរុញឱ្យមានការកែប្រែឥរិយាបថដើម្បីឱ្យកុមារ ជាពិសេសកុមារីក្នុងគ្រួសារដែលប្រឈមនឹងបញ្ហាជីវភាពក្រីក្របានចូលរៀន។ អង្គការនេះបានរៀបចំផែនការនៅថ្នាក់ឃុំ សង្កាត់ ដើម្បីអនុវត្ត និងត្រួតពិនិត្យកិច្ចអន្តរាគមន៍គ្រប់លំដាប់ថ្នាក់។

២២២-អង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ គម្រោងអនុតំបន់មេគង្គប្រឆាំងការជួញដូរកុមារនិងស្ត្រី(ILO/IPEC-TICW) បានធ្វើសកម្មភាពជាមួយស្ថាប័នរដ្ឋាភិបាល សមាគមនិយោជក សហជីព អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងទិសដៅលុបបំបាត់ការធ្វើអាជីវកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មលើស្ត្រីនិងកុមារ លើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈការកាត់បន្ថយភាពងាយរងគ្រោះ។ សកម្មភាពនេះបានអនុវត្តជាមួយជនដែលកំពុងរស់នៅកន្លែងគ្រោះថ្នាក់ជាងគេបំផុត ដែលអាចធ្វើឱ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះដោយមិនដឹងខ្លួន ដោយប្រាប់ឱ្យពួកគេដឹងមុនអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដែលគ្មានព័ត៌មានច្បាស់លាស់ និងមិនបានរៀបចំទុកជាមុន។ បានជួយគាំទ្រស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ដើម្បីអភិវឌ្ឍ និងរក្សាការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ បានផ្តោតការយកចិត្តទុកដាក់ចំពោះកុមារ (កុមារា និងកុមារី) និងស្ត្រី ដែលមានជីវភាពខ្សត់ខ្សោយ ខ្វះការអប់រំរៀនសូត្រ ដែលងាយរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទនិងពលកម្ម។ គម្រោងបានឧបត្ថម្ភគាំទ្រដល់កម្មវិធីជួយកុមារនិងស្ត្រីវ័យក្មេងងាយរងគ្រោះ ដើម្បីកែលំអគុណភាពជីវិតរបស់ពួកគេ។

### ៣.៣- ការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើទេសចរណ៍

២២៣-សារាចរណែនាំរបស់ក្រសួងទេសចរណ៍ចំនួន១១ (លេខ០៩សរណន. ០៥សរណន. ០៨សរណន. ១០សរណន. ១១សរណន. ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០១ និងសារាចរលេខ ០០១ សរណន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ ហើយនិងសារាចរលេខ ០០១ សរណន. ០០២ សរណន. ០០៣ សរណន. ០០៤ សរណន. ០០៥ សរណន. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ) ស្តីពីការគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍ អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅ អាជីវកម្មវង្គសាលឱស្ថតែក អាជីវកម្មដឹកជញ្ជូនទេសចរទស្សនាកម្សាន្តតាមផ្លូវគោក អាជីវកម្មសេវាកម្មម៉ាស្សា អាជីវកម្មភោជនីយដ្ឋាន អាជីវកម្មខារ៉ាអូខេ អាជីវកម្មកីឡាទេសចរណ៍និងការកម្សាន្ត អាជីវកម្មមគ្គុទេសក៍ទេសចរណ៍ អាជីវកម្មទេសចរ អាជីវកម្មដឹកជញ្ជូនទេសចរទស្សនាកម្សាន្តតាមផ្លូវទឹក និងអាជីវកម្មរមណីដ្ឋានទេសចរណ៍ បានដាក់បញ្ចូលនូវការហាមឃាត់ដាច់ខាតរាល់សកម្មភាពធ្វើអាជីវកម្មជួញដូរគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងអំពើព្យោចារគ្រប់ប្រភេទ ហើយតម្រូវឱ្យរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ចនូវរាល់បាតុភាពមិនប្រក្រតី ដែលកើតមានក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន។

២២៤-ក្រសួងទេសចរណ៍បានបង្កើតគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅឆ្នាំ២០០១ ដែលមានបណ្តាញនៅគ្រប់ខេត្ត/ក្រុង ក្នុងគោលបំណងរួមចំណែកទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានក្នុងវិស័យទេសចរណ៍ ពិសេសទេសចរណ៍ផ្លូវភេទលើកុមារ និងស្ត្រីវ័យក្មេង។ គណៈកម្មាធិការនេះបានសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធមួយចំនួន ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត/ក្រុង និងថ្នាក់មូលដ្ឋានជូនដល់មន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរដែនដី ស្រុក ឃុំ ភូមិ មន្ទីរពាក់ព័ន្ធ និយោជិត និយោជកនៅតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ គ្រូបង្រៀន សិស្សសាលា អំពីការលើកកម្ពស់សុវត្ថិភាព

កុមារក្នុងវិស័យទេសចរណ៍ ដោយបានពន្យល់អំពីនយោបាយទេសចរណ៍កម្ពុជា និងការចូលរួមចំណែកទប់ស្កាត់ អំពីរបៀបទំនាក់ទំនងមកក្រសួងមានសមត្ថកិច្ច ដើម្បីជួយជនរងគ្រោះឱ្យទាន់ពេលវេលា និងចាត់វិធានការទៅតាមផ្លូវច្បាប់។ ពីឆ្នាំ២០០១ ដល់២០០៦ បានធ្វើការបណ្តុះបណ្តាលអំពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដល់កុមារចំនួន ៤.០៦៥នាក់ និងមនុស្សចាស់ចំនួន ១.៥៦៥នាក់ និងក្នុងឆ្នាំ២០០៧ បានបណ្តុះបណ្តាលដល់កុមារចំនួន ៥.៩៧០នាក់ និងមនុស្សចាស់ចំនួន ៥.១៨៤នាក់ ទន្ទឹមនឹងនេះដែរ បានផលិតសម្ភារៈផ្សព្វផ្សាយដូចជា ស្លាកបិទ សៀវភៅតូច ផ្ទាំងរូបភាពខ្នាតតូច ធំ ដើម្បីចែកផ្សព្វផ្សាយតាមសហគមន៍ទេសចរណ៍ និងរមណីយដ្ឋាននៅតាមបណ្តាខេត្ត/ក្រុង សំខាន់ៗមួយចំនួន។

២២៥-ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការពលកម្មអន្តរជាតិខាងការងារនៅឆ្នាំ២០០៦ ក្រសួងបានកសាង និងបោះពុម្ពសៀវភៅផែនការយុទ្ធសាស្ត្រ (២០០៧-២០០៩) ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារនិងស្ត្រី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងឧស្សាហកម្មទេសចរណ៍កម្ពុជា បានបោះពុម្ពសៀវភៅគោលការណ៍ប្រតិបត្តិ សៀវភៅបណ្តុះបណ្តាល និងសៀវភៅឧបករណ៍សម្របសម្រួលសម្រាប់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

២២៦-គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (ECPAT) ដែលមាន២៧អង្គការជាសមាជិក បានចូលរួមអនុវត្តកម្មវិធីលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ជាមួយក្រសួងទេសចរណ៍។ បានសម្របសម្រួលសកម្មភាពលុបបំបាត់ពេស្យាចារកុមារ រូបភាពអាសអាភាសកុមារ លើកកម្ពស់ការយល់ដឹង ការតស៊ូមតិ ការត្រួតពិនិត្យតាមដាន ការចែកចាយព័ត៌មានដល់ស្ថាប័នពាក់ព័ន្ធ បានធ្វើនិងវិភាគស្ថិតិដែលមានសុពលភាព និងអាចជឿទុកចិត្តបាននៃកំណត់ត្រាករណីរំលោភសេពសន្ថវៈនិងជួញដូរ ត្រួតពិនិត្យតាមដានការរីកចម្រើនការផ្លាស់ប្តូរក្នុងរយៈកាលប៉ុន្មានឆ្នាំខាងមុខ។

### ៣.៤- ការថែទាំជំនួស និងសមាហរណកម្មជនរងគ្រោះ

២២៧-អង្គការមិនមែនរដ្ឋាភិបាលបានដើរតួយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីថែទាំជំនួស សម្រាប់កុមាររងគ្រោះដោយសារការជួញដូរ ដោយបានផ្តល់ជម្រករយៈពេលខ្លីនិងវែងដល់ជនរងគ្រោះដែលត្រូវបានសង្គ្រោះ និងបានផ្តល់សេវាផ្សេងៗទៀតដូចជា ការព្យាបាលសុខភាពរាងកាយនិងផ្លូវចិត្ត ការបណ្តុះបណ្តាលវិជ្ជាជីវៈ រៀនអក្សរ បំណិនជីវិត ។ល។ ទន្ទឹមនេះអង្គការបានបណ្តុះបណ្តាលបុគ្គលិកនៃក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន អំពីការស្តារសម្បទាដល់ជនរងគ្រោះ តួនាទីឪពុកម្តាយ ការគ្រប់គ្រងស្ថាប័ន ការគ្រប់គ្រងកម្មវិធី ការស៊ើបអង្កេត ការផ្តល់ប្រឹក្សាយោបល់ ការព្យាបាលផ្លូវចិត្ត ការដោះស្រាយជម្លោះ និងការតស៊ូមតិ។ កម្មវិធីទាំងនេះត្រូវបានដំណើរការដោយអង្គការ COSECAM, Cambodia ACTs, AFESIP, VCAO អាដហុក លីកាដូ និងអង្គការផ្សេងៗទៀត។

២២៨-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) បានធ្វើសមាហរណកម្មជនរងគ្រោះដោយសារ

ការជួញដូរពីប្រទេសថៃចំនួន១.២៧៦នាក់ ដែលក្នុងនោះរួមទាំងកុមារផង(ឆ្នាំ២០០០ដល់២០០៦)។ ជនទាំងនោះត្រូវបានធ្វើការបញ្ជូនទៅតាមបណ្តាអង្គការជាដៃគូដើម្បីស្តារសម្បទា និងបានផ្តល់សេវាផ្សេងៗទៀត។ កម្មវិធីធ្វើមាតុភូមិនិវត្តន៍នារីវៀតណាមដែលរងគ្រោះដោយការជួញដូរ ពីប្រទេសកម្ពុជាឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញបានចំនួន៩៣នាក់។ កម្មវិធីនេះឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ថវិកាពីអង្គការយូនីសេហ្វ និងអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM)។

២២៩-ក្នុងឆ្នាំ២០០៦ ក្រសួង ស.អ.យ បានបង្កើតការិយាល័យសមាហរណកម្ម និងប្រឆាំងការជួញដូរមនុស្ស ដែលមានភារកិច្ចកំណត់អត្តសញ្ញាណ ការពារ ស្វែងរក វាយតម្លៃ សមាហរណកម្ម បញ្ជូន និងប្រព័ន្ធគាំទ្រសម្រាប់ជនរងគ្រោះដោយសារការជួញដូរ អាជីវកម្ម និងហិង្សា ការបំពារបំពានគ្រប់ទម្រង់ផ្សេងទៀត ព្រមទាំងប្រមូលទិន្នន័យ ស្តីពីការជួញដូរ និងសមាហរណកម្មជនរងគ្រោះ។ កម្មវិធីនេះសហការជាមួយអង្គការទេសន្តប្រវេសន៍អន្តរជាតិ និងមានការគាំទ្រពីយូនីសេហ្វ។

## ៣.៥- ការបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

២៣០-ដោយមានយុទ្ធនាការជំរុញសកម្មប្រឆាំងនឹងការជួញដូរ ការបំពារបំពាន និងអាជីវកម្មលើផ្លូវភេទ ព្រមទាំងសេវាកម្មរាយការណ៍ជាបន្ទាន់ជូនដល់នគរបាល ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានបង្ក្រាបជនល្មើស និងសង្គ្រោះជនរងគ្រោះ ដែលមានលទ្ធផលដូចខាងក្រោម ÷

| ឆ្នាំ | បង្ក្រាប | ចាប់ជនសង្ស័យ | សង្គ្រោះជនរងគ្រោះ |
|---|---|---|---|
| ២០០៤ | ១០៦ ករណី | ១១៥ នាក់ | ៣៦៣ នាក់ (កុមារ៨៩ នាក់) |
| ២០០៥ | ១៤៩ ករណី | ១៩៧ នាក់ | ៥៣២ នាក់ (កុមារ៩៤ នាក់) |
| ២០០៦ | ១១៤ ករណី | ១៤៨ នាក់ | ២៧២ នាក់ (កុមារ១៤២ នាក់) |
| ២០០៧ | ៧៥ ករណី | ១១៨ នាក់ | ៣០៣ នាក់ (កុមារ៩២ នាក់) |

*(ប្រភព : ទិន្នន័យនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)*

## ៣.៦- កិច្ចសហប្រតិបត្តិការ

២៣១-ការជួញដូរស្ត្រីនិងកុមារឆ្លងព្រំដែនគឺជាកង្វល់មួយនៅកម្ពុជា។ ភាពក្រីក្រគួបផ្សំជាមួយនឹងកង្វះការអប់រំរបស់គ្រួសារ និងចំណេះដឹងក្នុងចំណោមសហគមន៍ជាកត្តាជំរុញនាំឱ្យមានការជួញដូរកុមារ។ ការវាយតម្លៃភាពក្រីក្ររបស់កម្ពុជាបានសន្និដ្ឋានថា មួយភាគបីនៃប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រ ដែលធ្វើឱ្យកុមារ និងស្ត្រីសម្រេចចាកចេញទៅរកការងារធ្វើនៅប្រទេសជិតខាង ហើយនាំឱ្យពួកគេងាយទទួលរងគ្រោះដោយសារអំពើជួញដូរ និងទេសន្តប្រវេសន៍គ្មានសុវត្ថិភាព។

២៣២-កុមារនៅតែជាកម្មវត្ថុដែលត្រូវបានជួញដូរយកទៅប្រទេសថៃ វៀតណាម និងប្រទេសមួយចំនួនទៀត។ ស្ត្រី និងក្មេងស្រីជាទូទៅ ត្រូវបានគេជួញដូរយកទៅធ្វើអាជីវកម្មផ្លូវភេទ មួយចំនួនទៀតក៏ត្រូវបានជួញដូរយកទៅធ្វើជាអ្នកសុំទាន ឬអ្នកធ្វើការងារក្នុងផ្ទះ។ វិសាលភាពនៃបញ្ហាតម្រូវឱ្យមានកិច្ចសហប្រតិបត្តិជិតស្និទ្ធជាមួយប្រទេសដទៃទៀត ជាពិសេសប្រទេសក្នុងតំបន់ទន្លេមេគង្គ។

២៣៣-នៅខែឧសភា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ។ នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារដើម្បីអនុវត្តអនុស្សរណៈនេះ។

២៣៤-នៅខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និងបានបង្កើតក្រុមកាងារកម្ពុជាដើម្បីអនុវត្តក្នុងខែកក្កដា ឆ្នាំ២០០៥ ។ ក្រុមការងារកម្ពុជារួមជាមួយក្រុមការងារនៃបណ្តាប្រទេសនៅមហាអនុតំបន់បានរៀបចំ និងអនុវត្តផែនការសកម្មភាពអនុតំបន់៣ឆ្នាំលើកទី១ (២០០៤-២០០៧)។ ក្នុងខែធ្នូ ឆ្នាំ២០០៧ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ក្រុមការងារទាំង៦ប្រទេស បានអនុម័តលើផែនការសកម្មភាពអនុតំបន់៣ឆ្នាំលើកទី២ និងរដ្ឋមន្ត្រីនៃប្រទេសទាំង៦ បានចុះហត្ថលេខាលើសេចក្តីប្រកាសរួម COMMIT ។

២៣៥-នៅខែតុលា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។ អនុស្សរណៈស្រដៀងគ្នានេះដែរ កំពុងស្ថិតនៅក្នុងដំណើរការចរចារជាមួយប្រទេសម៉ាឡេស៊ី។ អនុស្សរណៈស្តីពីគម្រោងសហប្រតិបត្តិការក្នុងទ្វីបអាស៊ី ដើម្បីបង្ការការជួញដូរមនុស្ស ត្រូវបានចុះហត្ថលេខាក្នុងខែវិច្ឆិកា ឆ្នាំ២០០៣ រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃប្រទេសកម្ពុជាជាមួយប្រទេសអូស្ត្រាលី។ កម្ពុជាបានចុះហត្ថលេខាផងដែរ លើកិច្ចព្រមព្រៀងស្តីពីការធ្វើបត្យាប័នជាមួយប្រទេសឡាវ ថៃ និងចិន។

២៣៦-ដោយមានការគាំទ្រពីអង្គការទេសន្តប្រវេសន៍អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានកសាងមណ្ឌលបណ្តោះអាសន្នក្នុងឃុំប៉ោយប៉ែតជាកន្លែងដែលកុមារត្រូវបានបញ្ជូន និងធ្វើមាតុភូមិនិវត្តពីប្រទេសថៃ។ កុមារទទួលបានជម្រកបណ្តោះអាសន្ន និងត្រូវបានបញ្ជូនឱ្យទៅរស់នៅជាមួយគ្រួសារ ឬអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការគាំទ្ររយៈពេលយូរអង្វែង។

២៣៧-ក្រុមពហុផ្នែកប្រចាំព្រំដែនសម្រាប់ការពារកុមារនៅក្នុងតំបន់ឆ្លងដែនប៉ោយប៉ែត ដើម្បីបង្អាក់កុមារដែលគ្មានអ្នកអមដំណើរដែលត្រូវបានចាប់បញ្ជូនពីប្រទេសថៃ ហើយបញ្ជូនទៅជម្រកបណ្តោះអាសន្នដើម្បីជួយសង្គ្រោះ។ សមាជិកក្រុមនេះរួមមានបុគ្គលិករបស់ក្រសួងសង្គមកិច្ច នគរបាលប្រឆាំងការជួញដូរមនុស្ស ការិយាល័យសម្របសម្រួល

ព្រំដែនកម្ពុជា-ថៃ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៧ ជម្រកបណ្ដោះអាសន្ន និងក្រុមព្រំដែននឹងត្រូវរំលាយបញ្ចូលគ្នា ហើយនឹងដំណើរការក្រោមការគ្រប់គ្រងរបស់ការិយាល័យសមាហរណកម្ម និងប្រឆាំងអំពើជួញដូររបស់ក្រសួងសង្គមកិច្ច។

### ៣.៧- លទ្ធផលនៃការប៉ាន់ប្រមាណលើការអនុវត្តផែនការជាតិ

២៣៨-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០ ដែលមានភារកិច្ចសម្របសម្រួលកិច្ចសហការរវាងក្រសួង ស្ថាប័ន និងអង្គការនានាក្នុងការអនុវត្តផែនការជាតិ និងបានធ្វើការប៉ាន់ប្រមាណវាយតម្លៃលើការអនុវត្តផែនការជាតិនៅពាក់កណ្ដាលអណត្តិ (២០០២) និងចប់អាណត្តិ(២០០៤)។ តាមការប៉ាន់ប្រមាណវាយតម្លៃបានបង្ហាញថា កម្ពុជាបានធ្វើឱ្យប្រសើរឡើងក្នុងការដោះស្រាយទប់ស្កាត់បញ្ហាជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារដែលទទួលស្គាល់ដោយសហគមន៍អន្តរជាតិ។

២៣៩-សមិទ្ធិផលដែលគួរឱ្យកត់សម្គាល់ រួមមាន ÷

- ការបង្កើតអង្គភាពប៉ូលីសជំនាញមុនគេនៅតំបន់អាស៊ីអាគ្នេយ៍ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ គឺនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ នាយកដ្ឋាននេះ បានពង្រឹងការងារតាមខេត្តនានា និងកំពុងតែបោះជំហានទៅមុខផ្នែកកិច្ចសហការជាមួយនឹងដៃគូក្នុងតំបន់។
- ការបង្កើតឱ្យមានបណ្ដាញទូរស័ព្ទពិសេសដំណើរការ២៤ម៉ោង ដើម្បីសម្រួលដល់ការរាយការណ៍ពីអំពើជួញដូរ និងរំលោភផ្លូវភេទ។
- ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងចំណោមអ្នកតាក់តែងគោលនយោបាយ និងសាធារណជនទូទៅ។
- ផ្ដល់ឱកាសដល់ជនរងគ្រោះដោយសារអំពើជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ ឱ្យបានចូលរួមដោយស្ម័គ្រចិត្តដើម្បីផ្ដល់យោបល់ក្នុងការកសាងគោលនយោបាយ ការធ្វើសេចក្ដីសម្រេចផ្សេងៗ ដែលពាក់ព័ន្ធនឹងបញ្ហា ជួញដូរ។
- ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ដ៍ ស្ដីពីកិច្ចសហប្រតិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ និងកិច្ចព្រមព្រាងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារ និងជួយដល់ជនរងគ្រោះដោយសារការ ជួញដូរ។
- កម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការបង្កើតអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស និងសម្របសម្រួលគំនិតផ្ដួចផ្ដើមថ្នាក់រដ្ឋមន្ត្រីនៃប្រទេសមហាអនុតំបន់ទន្លេមេគង្គប្រឆាំងនឹងការជួញដូរមនុស្ស។ ផែនការសកម្មភាពថ្នាក់អនុតំបន់ ព្រមទាំងយន្តការវាយតម្លៃ និងពិនិត្យតាមដាន ត្រូវបានបង្កើតឡើង។

- គំនិតផ្តួចផ្តើមបង្កើតភាពជាដៃគូរវាងរដ្ឋាភិបាល ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឧស្សាហកម្មទេសចរណ៍ដើម្បីចាប់ផ្តើមប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ។
- វិធានការដើម្បីរៀបចំកម្មវិធីសុវត្ថិភាពទេសន្តប្រវេសន៍ រួមមានការបង្កើនឱកាសសម្រាប់ទេសន្តប្រវេសន៍ស្របច្បាប់ដែលជាការជួយកាត់បន្ថយឱកាសចំពោះក្រុមឈ្មួញទុច្ចរិត ។
- ការអភិវឌ្ឍសេវាកម្មគ្រប់ប្រភេទសម្រាប់ជួយជនរងគ្រោះ រួមទាំងប្រព័ន្ធបំពេញសំណុំបែបបទធ្វើមាតុភូមិនិវត្តន៍រវាងកម្ពុជានិងថៃលើកទី១ក្នុងតំបន់ និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារជួយគាំពារជនរងគ្រោះ និងទីភ្នាក់ងារអនុវត្តច្បាប់នានាដែលមានបំណងរកយុត្តិធម៌ជូនជនរងគ្រោះ ។
- បង្កើតភាពជាដៃគូជាមួយផ្នែកឧស្សាហកម្មទេសចរណ៍ ដើម្បីសហការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ។

២៤០-បើទោះជាមានភាពជឿនលឿនយ៉ាងដូច្នេះក៏ដោយ ក៏គេឃើញមានភស្តុតាងតិចតួចដែលបញ្ជាក់ថា បញ្ហាការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារកំពុងថយចុះ ។ ការប៉ាន់ប្រមាណវាយតម្លៃទៅលើផលប៉ះពាល់នៅមានកម្រិតទាបនៅឡើយ ។ តម្រូវការចាំបាច់ឱ្យមានវិធីសាស្ត្រថ្មី ដែលមានលក្ខណៈប្រសើរឡើង និងត្រូវបានដាក់បញ្ចូលគ្នា ។ ការកសាងផែនការជាតិលើកទី២ ផ្តល់ឱកាសដ៏ល្អបំផុតដើម្បីពិចារណាហ្មត់ចត់អំពីស្ថានភាពបច្ចុប្បន្ន ស្របទៅនឹងអទិភាពទាំងឡាយដើម្បីធ្វើសកម្មភាពទៅអនាគត ហើយជាទូទៅត្រូវរៀបចំផែនការការងារ ដែលត្រូវធ្វើនៅពេលក្រោយសម្រាប់វិធីសាស្ត្រថ្មីនេះ ។

២៤១-ទោះបីមានការរីកចម្រើនពាក់ព័ន្ធនឹងការទប់ស្កាត់អំពើជួញដូរកុមារក្តី ក៏នៅមានបញ្ហាខ្វះខាតមួយចំនួន ដែលរាជរដ្ឋាភិបាលនឹងប្រឈមមុខដោះស្រាយ គឺការធានាធ្វើយ៉ាងណាឱ្យការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធិភាព ជាពិសេសលិខិតបទដ្ឋានពាក់ព័ន្ធនឹងការហាមឃាត់ការផ្សព្វផ្សាយរូបអាសអាភាស ស្របជាមួយនឹងការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីគ្រោះថ្នាក់នៃការជួញដូរ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការផ្តល់សេវាកម្មពិគ្រោះយោបល់ដល់ជនរងគ្រោះ និងការបង្កើតមជ្ឈមណ្ឌលសង្គ្រោះឱ្យបានសមស្របតាមបរិមាណជាក់ស្តែងនៃជនរងគ្រោះ ។

២៤២-ផែនការទី១បានចប់អាណត្តិ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកសាងសេចក្តីព្រាងផែនការជាតិទី២ ដោយផ្តោតលើកម្មវិធីចំនួន៥គឺ គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ កិច្ចបង្ការទប់ស្កាត់ យុត្តិធម៌ព្រហ្មទណ្ឌ កិច្ចការពារ ការស្តារសម្បទា និងសមាហរណកម្ម ព្រមទាំងកម្មវិធីពិសេសដែលពាក់ព័ន្ធបញ្ហាកាត់បន្ថយតម្រូវការឥរិយាបទសង្គម អំពើហិង្សាលើស្ត្រី/កុមារ ការសេពគ្រឿងញៀន និងរូបភាពអាសអាភាស ។

## X. ការផ្សព្វផ្សាយរបាយការណ៍ដំបូង

***អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប***

ក- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណៈជនទូទៅនូវរបាយការណ៍ដំបូង និងសេចក្តីឆ្លើយតបជាលាយលក្ខអក្សរ ដាក់ពិនិត្យដោយរដ្ឋជាភាគី ។

ខ- ពិចារណាការបោះពុម្ពផ្សាយនូវរបាយការណ៍ជាមួយកំណត់ហេតុសង្ខេបពាក់ព័ន្ធ និងសេចក្តីសង្កេតចុងក្រោយធ្វើឡើងដោយគណៈកម្មាធិការ ។

២៤៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.ក) ដោយមានការឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស បានធ្វើកម្រងឯកសារចងក្រងឯកសារពាក់ព័ន្ធនឹងរបាយការណ៍ ស្តីពីការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។ ឯកសារនេះមានរបាយការណ៍ដំបូង របាយការណ៍ឆ្លើយតបនឹងសំណួរដែលពាក់ព័ន្ធនឹងរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជា សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៦២៩ កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៦៣០ របាយការណ៍សិក្ខាសាលាស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយ ដែលរៀបចំដោយ ក.ជ.ក.ក លទ្ធផលសិក្ខាសាលាស្តីពីអនុសាសន៍របស់ អ.ស.ប លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ដែលរៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធកុមារ ។ ឯកសារទាំងអស់នេះត្រូវបានចងក្រងជាភាសាខ្មែរ និងអង់គ្លេស និងបានបែងចែកផ្សព្វផ្សាយជូនអ្នកធ្វើការពាក់ព័ន្ធក្នុងវិស័យសិទ្ធិកុមារ ។ សេចក្តីសង្កេតចុងក្រោយបានត្រូវដាក់ក្រោមការពិភាក្សាយ៉ាងហ្មត់ចត់ក្នុងចំណោមអ្នកធ្វើការពាក់ព័ន្ធ ដើម្បីរិះរកវិធីអនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការឱ្យបានប្រសិទ្ធភាព ។

~~~~~~~~~~~~
~~~~~~~~~~~~

# អត្ថបទយោង


១- ការប៉ាន់ប្រមាណអំពីស្ថានភាពកុមារទំនាស់នឹងច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា

២- ឯកសារអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០

៣- របាយការណ៍ដំបូងប្រចាំឆ្នាំ២០០៥ អំពីការអង្កេតផ្នែកសុខាភាព និងប្រជាសាស្ត្រកម្ពុជា របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៥

៤- ឯកសារអង្កេតចន្លោះជំរឿន ឆ្នាំ២០០៤

៥- ឯកសារគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣

៦- ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា របស់ធានាគាពិភពលោក ឆ្នាំ២០០៦

៧- របាយការណ៍ប្រទេសកម្ពុជាសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រ លើកទី៧ ស្តីពីកុមារតំបន់អាស៊ីបូពា និងប៉ាស៊ីហ្វិក ពីថ្ងៃទី២៣-២៤ ខែមិនា ឆ្នាំ២០០៥ នៅខេត្តសៀមរាប

៨- ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤

៩- របាយការណ៍ស្តីពីការអង្កេតអំពីពលកម្មកុមារ ឆ្នាំ២០០១ (វិទ្យាស្ថានជាតិស្ថិតិ )

១០- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០

១១- វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៥

១២- របាយការណ៍កែសម្រួលទី១ នៃគម្រោងប្រជាជន សម្រាប់រយៈពេល ១៩៩៨-២០២០

១៣- ទិន្នន័យរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការថែទាំក្នុងលំនៅដ្ឋាន ឆ្នាំ២០០៦

១៤- របាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០០០

១៥- ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០០៤-២០០៨ ទំព័រ៥៧

១៦- គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៦ (វិទ្យាស្ថានជាតិស្ថិតិ )

១៧- ឯកសារសន្និបាតជាតិ លើកទី២ ឆ្នាំ២០០១

១៨- ការប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គមរបស់ហ៊ីវ/អេដស៏ លើគ្រួសារមានកុមារតូច និងកុមារជំទង់នៅកម្ពុជា ទំព័រទី៤

១៩- ស្ថិតិរបស់ក្រសួងមហាផ្ទៃ ឆ្នាំ២០០១

២០- ទិន្នន័យស្តីពីចំនួនកុមារដែលត្រូវបានសុំទៅរស់នៅបរទេស ពីឆ្នាំ២០០០-២០០៧

២១- ឯកសារឆ្ពោះទៅរកយុទ្ធសាស្ត្រស្តីពី ប្រជាជន ឆ្នាំ២០០២


-ឧបសម្ព័ន្ធអំពីស្ថិតិ

១-អាំងឌីការទ័រសេដ្ឋកិច្ច

២-ផ្នែកសុខភាព

៣-ផ្នែកអប់រំ